01500884

E1/264.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jun-2017, 15:53
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី២៤៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ែន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ័ង

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី

*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ត្រាវិស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

លោកស្រី ទូច វរល័ក្ស

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍** *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល | បារាំង |
| លោក ត្រាវិស ហ្វារ | អង់គ្លេស |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ស្បូន វិសាល | ខ្មែរ |
| លោក ឡៅ ជុនធី | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ភ្នៅ យ៉ារ (2-TCW-934) | ខ្មែរ |
| លោក សៅ ហ៊ាន (2-TCW-807) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឡៅ យ៉ាច** (2-TCW-934)

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ....................ទំព័រ ៣
សួរដោយលោក ឡៅ ជុនធី ផ្ដើមពី....................ទំព័រ ៣១
សួរដោយលោក សួន វិសាល ផ្ដើមពី....................ទំព័រ ៤២
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី....................ទំព័រ ៤៥
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី....................ទំព័រ ៥១
សួរដោយលោក គង់ សំអុន ផ្ដើមពី....................ទំព័រ ៥៣

**ការសួរសំណួរទៅសាក្សី៖ លោក សៅ ហ៊ាន** (2-TCW-807)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី....................ទំព័រ ៦៧
សួរដោយលោក ត្រាវិស ហ្វារ ផ្ដើមពី....................ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ភ្មៅ យ៉ាវ។

ក្រឡាបញ្ជីសវនាការ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក ភ្មៅ យ៉ាវ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

រីឯសាក្សីបម្រុងសម្រាប់សវនាការនៅថ្ងៃនេះដែរ មានរហស្សនាម 2-TCW-807។ សាក្សីរូបនេះ បានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះ នឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែក នៅវេលាម៉ោងដប់ព្រឹកនេះ មុនពេលមកផ្ដល់សក្ខីកម្ម។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ លោកស្រី សែ កុលវុឌ្ឍី។ ឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់លោក នួន ជា ។ អង្គជម្រះ បានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងសវនាការ -- ក្នុងបន្ទប់សវនាការនេះ របស់លោក នួន ជា ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលបញ្ជាក់ថា លោកមានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បី

មានលទ្ធភាពចូលរួមសវនាការនាពេលខាងមុខ ឲ្យមានប្រសិទ្ធភាព។ ហើយខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅក្នុងអំឡុងសវនាការថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៥។ ហើយមេធាវីការពារក្ដីរបស់គាត់បានជម្រាបប្រាប់គាត់ អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់នឹងភស្ដុតាងក្នុងការបង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៦:៣១]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះ និង វិលមុខ ពេលអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ហើយផ្អែកលើមូលដ្ឋាននេះ យោងតាមបទបញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ បង្គាប់ឲ្យផ្នែកបុគ្គលិកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាកិច្ចបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីសួរដេញដោលសាក្សី ភ្នៅ យ៉ាវ មុនភាគីដទៃទៀតនៃរឿងក្ដី ដោយផ្អែកលើបទបញ្ញត្តិវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក ។

[០៩:០៨:០៤]

ហើយអង្គជំនុំជម្រះ សូមបញ្ជាក់ថាសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានរយៈពេលកន្លះថ្ងៃ គឺចាប់ពីនេះទៅ រហូតដល់សម្រាកថ្ងៃត្រង់។

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទសូមអរគុណ ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម និង ភាគីទាំងអស់ សាធារណជន។

**ស៖** បាទជម្រាបសួរ លោកសាក្សី ខ្ញុំឈ្មោះ លោក វ៉ាំងសង់ វ៉ាយដ៍ ហើយខ្ញុំនឹងចោទសំណួរឱ្យលោកជួសមុខឱ្យការិយាល័យសហព្រះរាជអាជ្ញា រហូតដល់ម៉ោងដប់មួយ ហើយបន្ទាប់មកទៀតមេធាវីដើមបណ្តឹងរដ្ឋប្បវេណី<នឹង>ចោទសំណួរបន្តរហូតដល់ពេលសម្រាកស្រស់ស្រូបអាហារថ្ងៃត្រង់។

ឥឡូវនេះ ខ្ញុំនឹងចោទសំណួរទៅលោក ទាក់ទងទៅនឹងអតីតកាលរបស់លោក គឺមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ ខ្ញុំចង់សួរលោកថា តើលោកបានទៅសាលារៀនដល់អាយុប៉ុន្មាន ហើយ<ធ្លាប់> ទទួលសញ្ញាបត្រ<ដែរ ឬទេ>?

[០៩:០៩:២០]

**លោក ភ្នៅ យ៉ាវ ៖**

**ឆ៖** ខ្ញុំរៀនបានថ្នាក់ទី៩ ខ្មែរ លោកប្រធាន បាទ។

**ស៖** តើថ្នាក់ទី៩នេះ <ពេលហ្នឹងលោកអាយុប៉ុន្មានដែរ? តើពេលណា>លោកឈប់រៀន<ទៅចាប់ផ្តើម>ធ្វើ<ស្រែ>?

**ឆ៖** ខ្ញុំកាលនោះ ខ្ញុំឈប់រៀន ខ្ញុំបួសជាព្រះសង្ឃ បាទ។

**ស៖** តើលោកអាចជម្រាបបានទេថា នៅពេលដែលលោកទៅបួសជាព្រះសង្ឃហ្នឹងលោកអាយុប៉ុន្មានអង្កាល់នុ៎ង?

**ឆ៖** ខ្ញុំបួសជាព្រះសង្ឃវាអាយុ១៨ឆ្នាំ ខ្ញុំចូលបួសជាព្រះសង្ឃបាទ។

**ស៖** បាទ សូមអរគុណ។ លោកបាននិយាយថា លោកបានចូលទៅ -- ចូលរួមក្នុងចលនាបដិវត្តន៍ តើលោកបានចូលក្នុងចលនាបដិវត្តន៍នេះចាប់ពីពេលណាដែរ?

**ឆ៖** ចូលរួមចលនាបដិវត្តន៍ឆ្នាំ៧០គត់ លោកប្រធាន។

**ស៖** បាទ សូមអរគុណ។ នៅក្នុងកំណាត់ហេតុស្តាប់ចម្លើយរបស់លោកដោយសហចៅក្រម

ស៊ើបអង្កេតហ្នឹង គឺមានលេខ E3/5515 លោកបាននិយាយដូច្នេះ ឆ្លើយតបនឹងសំណួរទី២ "ប្រធានភូមិឈ្មោះ តាសិទ្ធ ត្រូវបានគេនាំយកទៅសម្លាប់នៅឆ្នាំ១៩៧២ ឬក៏ឆ្នាំ១៩៧៣ ហើយបន្ទាប់មកទៀតលោកបាននិយាយថា មេឃុំតាខែម ហ្នឹងត្រូវបានសម្លាប់នៅឆ្នាំ១៩៧៩។ តើលោកដឹងទេថា ហេតុអ្វីបានជា តាសិទ្ធ ត្រូវបានគេនាំយកទៅសម្លាប់នៅឆ្នាំ១៩៧២ ឬ៧៣នេះ?

[០៩:១១:៤៨]

**ឆ៖** តាសិទ្ធ ហ្នឹងគាត់មានវិបត្តិរឿងកុម្ម៉ង់ដូ តាមការខ្ញុំដឹងទៅបាទ។

**ស៖** បាទ លោកចង់និយាយថា ដោយសារគាត់មានបញ្ហាវិន័យ ឬក៏មកពីមូលហេតុអ្វីផ្សេង?

**ឆ៖** បាទ មូលហេតុនេះមកពីគាត់ កុម្ម៉ង់ដូគាត់មកនៅផ្ទះគាត់ កាលនោះគាត់ធ្វើមេភូមិ គាត់មកនៅផ្ទះគាត់ហ្នឹង បែបមានស្រលាញ់កុម្ម៉ង់ដូហ្នឹងបានគេយកគាត់ទៅសម្លាប់បាទ។ អ៊ីចឹង ជម្រាបខ្លីប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ នៅមុន<>ខែមេសា ឆ្នាំ១៩៧៥ ដដែល តើសហករណ៍ថ្នាក់ភូមិហ្នឹងចាប់ដំណើរការហើយ ឬនៅ តើលោកដឹងថាប្រហែលនៅឆ្នាំណាទេ?

**ឆ៖** បាទ សហករណ៍ភូមិប៉ែនមាស ចាប់ផ្ដើមនៅឆ្នាំ១៩៧៥ បាទ។

**ស៖** បាទ លោកនិយាយពីសហករណ៍ប៉ែនមាស ឃុំសំរោង ស្រុកត្រាំកក់ នៅក្នុងខេត្តតាកែវ លោកចង់និយាយពីសហករណ៍ហ្នឹង ឬក៏យ៉ាងម៉េច ប៉ែនមាសហ្នឹង?

**ឆ៖** បាទ ខ្ញុំនិយាយពីសហករណ៍ភូមិប៉ែនមាសខ្ញុំហ្នឹង ចាប់ដំណើរការឆ្នាំ១៩៧៥ហ្នឹង ចាប់ផ្ដើមបាយរួម បាទលោកប្រធាន។

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមចូលមកនិយាយអំពីរយៈពេលបន្ទាប់មកទៀត គឺថាចន្លោះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់៧៦ ព្រោះថា នៅឆ្នាំ៧៦នោះ លោកបាននិយាយថា មាននៅក្នុងឃុំសំរោងហ្នឹងមានបីអង្គភាព។ អ៊ីចឹងឃើញថា អង្កាល់ណោះសហករណ៍នៅក្នុងឃុំហ្នឹងត្រូវបានបែងចែកជាបី។ ទាក់ទងទៅនឹងការហូបចុករួម តើចាប់ពីពេលណាលោកញ៉ាំ ស្រស់ស្រូបអាហារនៅក្នុងសហករណ៍នៅរោងបាយរួមហ្នឹង?

**ឆ៖** ចាប់ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៨ បាទ បាយរួមរហូតបាទ។

[០៩:១៥:០០]

**ឆ៖** ចាប់ពីឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ១៩៧៨ ទៅ បាយរួមរហូតបាទ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** តើកាលនោះគឺថាចាប់ផ្ដើមមុនពេលដែលដណ្ដើមបានភ្នំពេញ ឬក៏ក្រោយពេលដណ្ដើមបានភ្នំពេញ?

**ផៈ** បាទ បែកភ្នំពេញហើយហ្នឹង លោកប្រធាន បានគេបាយរួមបាទ។

**សៈ** តើប្រជាជនមូលដ្ឋាននៅក្នុងភូមិរបស់លោក ឬក៏នៅឃុំសំរោងនោះ គេមានបញ្ចេញប្រតិកម្មយ៉ាងម៉េចដែរ នៅពេលដែលគេប្រាប់ថា ចាប់ពីពេលនេះទៅត្រូវហូបចុករួម? តើលោក រូបលោកផ្ទាល់នោះ លោកយល់ស្របនឹងការហូបចុករួមនេះទេ?

**ផៈ** បាទ បើយើងមិនយល់ស្រប ហ្នឹងវាមានមូលហេតុ គេយកយើងទៅសម្លាប់ បើថាយើងអត់តាមស្ដាប់គេ យើងទំនាស់គេ លោកប្រធានបាទ។

**សៈ** តើនៅឆ្នាំ១៩៧៥ កាលណោះតើលោកមានសិទ្ធិ<បន្ត>រស់នៅផ្ទះសម្បែងរបស់ខ្លួនដែរឬទេ?

**ផៈ** បាទកាលហ្នឹងមានសិទ្ធិរស់នៅតាមផ្ទះដែរហ្នឹង លោកប្រធាន អត់អីទេ អត់ទាន់ រើរុះទៅកងទេ។

**សៈ** តើអង្កាល់នោះលោកមានសិទ្ធិដាំបន្លែ ដាំ ឬក៏បេះផ្លែឈើអីដែលលោកដាំខ្លួនឯងនៅជុំវិញផ្ទះខ្លួនឯងទេ?

**ផៈ** ផ្លែឈើ បេះមិនបានទេ លោកប្រធាន។ បើថាដូងអីៗគេដាក់រួមអស់ហើយ។ គ្រាន់តែ ៧៥ គេដាក់រួមអស់តែម្ដង។ តាំងពីចាន ឆ្នាំង គោ ក្របី អីរួមទាំងអស់ បាទ។

**សៈ** លោកបាននិយាយថា ឆ្នាំ៧៥ នេះគឺជាឆ្នាំដែលលោកចាប់ផ្ដើមហូបចុករួម។ អ៊ីចឹងថានៅពេលហ្នឹងហើយ ដែលគេយកទ្រព្យសម្បត្តិទាំងអស់ដាក់ជារួមនៅក្នុងសហករណ៍ហ្នឹង?

**ផៈ** បាទ នៅឆ្នាំ១៩៧៥ ហ្នឹង គេដាក់រួមអស់ហើយ លោកប្រធាន មិនមាននៅអីទេ បាទ។ យើងនៅតែកូនស្បោងមួយតូច កម្មសិទ្ធិសមរម្យ បាទ។

[០៩:១៨:០៥]

**សៈ** តើកាលណោះនោះ មានអ្នកណាហ៊ានជំទាស់នឹងវិធានការនេះទេ? អត់មានអ្នកណាហ៊ាននិយាយថា អ្ហែ! ការធ្វើអ៊ីចឹង មិនសមរម្យទេ ដាក់រួមទាំងអស់ហ្នឹង? <សូម្បីតែមេក៏មិនហ៊ាននិយាយដែរឬ?>

**ផៈ** បាទ អត់មានគេហ៊ានជំទាស់ទេ លោកប្រធាន បើថាជំទាស់ត្រូវតែបាត់ខ្លួនតែម្ដងទាន។

**ស៖** ក្រៅពីការហូបចុករួម ហើយនិងការបំបាត់កម្មសិទ្ធិផ្ទាល់ខ្លួន តើមានការប្រែប្រួលអីផ្សេងទៀតដែលប៉ះពាល់ដល់លក្ខខណ្ឌជីវិតរបស់លោកនៅក្នុងរយៈពេលហ្នឹងទេ បើធៀបទៅនឹងសម័យមុន។ ឧទាហរណ៍ដូចជា ផ្នែកវិន័យអីជាដើម។ តើនៅក្នុង -- ក្រោយពីពេលបែកភ្នំពេញហើយហ្នឹង តើមានអ្វីដែលលោកអាចធ្វើបាន អ្វីដែលគេហាមមិនឲ្យលោកធ្វើដែរឬទេ?

**ឆ៖** បាទ បែកភ្នំពេញហើយ ដាក់រួម គេហាមអត់ឲ្យធ្វើទាំងអស់។ បើយើងទៅរកត្រី រកកង្កែប រកក្តាមអី អាហ្នឹងគេអត់ឲ្យរកដែរណ៎ាលោកប្រធាន។ បើរកយកមកដាក់ក្នុងកាស៊ីនសហករណ៍បាទ។

[០៩:១៩:៤០]

**ស៖** តើគឺចាប់ពីពេលហ្នឹងហើយ មានការចាប់ផ្តើមរាយការណ៍ចាក់ចុចអីអំពីកំហុសនៅក្នុងភូមិនោះ ត្រូវបានគេលើកទឹកចិត្តឲ្យធ្វើ។ តើ<ពួកខ្មែរក្រហមមាន>ជំរុញឲ្យរាយការណ៍អីទេកាលនុ៎ង?

**ឆ៖** បាទ គ្មានទេលោកប្រធាន អត់មានឲ្យរាយការណ៍អីទេ បាទ។

**ស៖** តើលោកខ្លាចអី បើសិនជាយើងមិនគោរពវិន័យ ឬក៏បទបញ្ជា? លោកនិយាយអម្បាញ់មិញ ថាភ័យខ្លាចគេយកទៅសម្លាប់ តើមានកត្តាអ្វីជាក់លាក់ដែលធ្វើឲ្យលោកភ័យដែរឬទេ?

**ឆ៖** បាទ ក្នុងរបបហ្នឹងភ័យដែរលោកប្រធាន បើយើងខ្លាចយើងធ្វើខុសទៅ គេយកទៅសម្លាប់ដែរបាទ។

**ស៖** តើលោកធ្លាប់បាន<ឃើញ>មនុស្ស<ត្រូវបាន>គេយកទៅ< ឬក៏អ្នកណាម្នាក់បាន>បាត់ខ្លួននៅរយៈពេលហ្នឹង ដោយសារខ្លួនហ្នឹងមិនបានគោរពវិន័យ?

**ឆ៖** បាទ ក្នុងដែលមូលដ្ឋានខ្ញុំ អត់សូវមានទេ ព្រោះថាការនេះ ខ្ញុំមិនសូវបានឃើញដែរ លោកប្រធាន ខ្ញុំរវល់តែគេប្រើទៅភ្ជួរស្រែ ប្រើទៅរែកដីដំបូក ជីកប្រឡាយ ជីកទំនប់អ៊ីចឹងលោក បាទ អត់សូវបានឃើញដែរ ខ្ញុំ។

[០៩:២១:៣៧]

**ស៖** បាទ ឥឡូវ ខ្ញុំចូលមកនិយាយអំពី ពេលអ្នកដែលគេជម្លៀសពីទីក្រុងផ្សេងៗចូលមកដល់ឃុំសំរោងរបស់លោក។ ហើយលោកបានឆ្លើយតបទៅនឹងសំណួរទី៥ របស់ឯកសារ E3/5515 គឺថា "អ្នកដែលគេជម្លៀសមកពីទីក្រុងភ្នំពេញ មកដល់ក្នុងភូមិនោះ ពួកគេទាំងអស់ត្រូវដាក់ចូលនៅក្នុងសាលារៀនមួយ"។ នៅចម្លើយតបទៅសំណួរទី៦ "តើម្ហូបអាហាររបស់ប្រជាជនថ្មីយ៉ាងម៉េចដែរ? គេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឲ្យពួកគេហូបចុកនៅរោងសហករណ៍ក្នុងភូមិ"។ តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើអ្នកដែលគេជម្លៀសមកពីទីក្រុងភ្នំពេញនោះ ច្រើនប៉ុនណាដែរ? តើមានប៉ុន្មានគ្រួសារដែរ កាលដែលលោកឃើញនោះ?

**ឆ៖** បាទ នៅក្នុងភូមិខ្ញុំមានតិចគ្រួសារដែរ លោកប្រធាន។ មានតែ១០គ្រួសារទេ ដែលមកពី -- ជម្លៀសទៅពីភ្នំពេញ។ បើក្រៅពីនោះចែកទៅតាមភូមិនានា បើចូលនឹងភូមិប៉ែនមាស មានតែ១០គ្រួសារប៉ុណ្ណឹងទេ។ ហ្នឹងជនជាតិចិន លោកប្រធាន។

**ស៖** តើមានអ្នកជម្លៀសដែលគេត្រូវបានជម្លៀសមកពីតាកែវដែរឬទេ?

**ឆ៖** ជម្លៀសពីតាកែវ មានខ្លះដែរលោកប្រធាន ពីរនាក់ដែរ។ បងប្អូននៅក្នុងភូមិប៉ែនមាស នៅជិតផ្ទះខ្ញុំដែរ បាទ។

**ស៖** តើពួកអ្នកដែលគេជម្លៀសទាំងអស់នោះ អ្នកជម្លៀសមកពីភ្នំពេញ ហើយនិងមកពីតាកែវនោះ ពេលមកដល់ហ្នឹង ស្ថានភាព សុខភាពគេយ៉ាងម៉េចដែរ?

**ឆ៖** បាទ គេមកដល់ហ្នឹង សុខភាពអត់សូវអីដែរ លោកប្រធាន សុខភាពអត់មានឈឺស្កាត់អីទេ ប៉ុន្តែមកដល់ហ្នឹង គេឲ្យទៅរែកទំនប់ ហៅថា ទំនប់ដុកខ្សាបនោះបាទ។

**ស៖** លោកបាននិយាយថា មានអ្នកភូមិដែលមានក្រុមគ្រួសារត្រូវបានជម្លៀស<មក>ពីតាកែវ<> តើអ្នកដែលគេជម្លៀសមកពីភ្នំពេញហ្នឹង ពីតាកែវហ្នឹង ត្រូវបានគេចាត់ទុកយ៉ាងដូចម្តេចដែរ កាលនុ៎ង? ឬក៏ពួកគេហ្នឹង តាមពិតអ្នកមានកំណើតនៅក្នុងភូមិលោកទេ ក៏ប៉ុន្តែពេលដែលគេជម្លៀសមកពីទីក្រុងភ្នំពេញ ហើយពីតាកែវហ្នឹង គេចាត់ទុកគាត់យ៉ាងម៉េចដែរ? ពួកគាត់យ៉ាងម៉េចដែរ ជាប្រជាជន<មូលដ្ឋាន> ឬជាប្រជាជនថ្មី <ឬប្រជាជន១៧ មេសា>?

**ឆ៖** បាទ លោកប្រធាន គេចាត់ទុកជាប្រជាជនថ្មី គេហៅថាដែលត្រៀមផ្ញើ ប្រជាជនផ្ញើទាន។

[០៩:២៥:០០]

**ស៖** បាទ សូមអរគុណ។ តើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្រជាជនថ្មី ឬ១៧ មេសា ហ្នឹងត្រូវបានគេដកហូតហើយដាក់នៅក្នុងសម្ភូហភាព ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ទ្រព្យសម្បត្តិដូចជាមាស ប្រាក់អី ដូចគេអត់ឃើញមានយកដែលលោកប្រធាន នៅរបស់គាត់ដែរ។

**ស៖** ក៏ប៉ុន្តែទ្រព្យសម្បត្តិរបស់លោក ផ្ទាល់ខ្លួនរបស់លោកនោះ ត្រូវបានគេដកហូត។ ហើយ

ចំពោះប្រជាជន ១៧មេសា នោះគេអត់ដកហូតអ្វីពីពួកគាត់ទេ ឬក៏ពេលភ្លាមៗនោះ គេអត់ដកហូតទេ ដល់ពេលក្រោយមកបានគេដកហូត?

**ឆ៖** បាទ ហ្នឹងខ្ញុំអត់បានដឹងដែរ លោកប្រធាន ព្រោះថាការងារខ្ញុំវាមមាញឹកខាងធ្វើស្រែចម្ការ ដឹងគេដាក់ថ្មើរម៉ាន អីថ្មើរម៉ាន ខ្ញុំអត់បានដឹងទេ ទាន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំនិយាយអំពីរយៈពេលដដែល។ នៅក្នុងចម្លើយរបស់លោកគឺថា ឯកសារ E3/5515 ចម្លើយទី៩ លោកឆ្លើយថា៖ “ក្មេងៗទាំងអស់រើសអាចម៍គោ ក្រៅពីរើសអាចម៍គោ គេឱ្យពួកគេរៀនសរសេរ រៀនអានពី ពីរទៅបីម៉ោង ក្នុងមួយថ្ងៃ។ បន្ទាប់ពីរៀនហើយ គេឱ្យពួកគេទៅឃ្វាលគោរហូតដល់ម៉ោងប្រាំល្ងាច ទើបឱ្យចូលមកហូបបាយ”។ សំណួរទី១០៖ “តើគេបង្រៀនអ្វីខ្លះទៅក្មេងៗ? ចម្លើយ៖ គេបង្រៀនឱ្យពួកគេរៀនអក្សរ ក ខ គ ឃ ហើយនិងរៀនប្រកបអក្សរ”។ បាទ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងលោកអាចជម្រាបជូនតុលាការបានទេថា តើចាប់ពីពេលណាដែលលោកត្រូវគេឱ្យបង្រៀនទៅក្មេងៗ ឱ្យរៀនអានសរសេរជាដើមនេះ ចាប់ពីពេលណាមក?

[០៩:២៧:២០]

**ឆ៖** បាទ នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំត្រូវទៅនៅតាលាក់ខាងលិច ហៅអង្គពណ្ណរាយនោះ លោកប្រធាន។ ហើយគេឱ្យខ្ញុំបង្រៀនក្មេងនៅពេលហ្នឹងបាទ។

**ស៖** បាទ អ៊ីចឹងនៅពេលដែលលោកនិយាយពីក្មេងនោះ គឺនៅអង្គាល់នោះ សំដៅលើក្មេងៗរបស់អ្នកមូលដ្ឋានទេ ឬក៏លោកសំដៅលើក្មេងៗរបស់ប្រជាជនថ្មី?

**ឆ៖** បាទ ក្មេងៗដែលនៅជាមួយខ្ញុំ គឺសុទ្ធតែមូលដ្ឋានទាំងអស់លោកប្រធាន អត់មានក្មេង កង ៣ មានសុទ្ធតែ កង១ បាទ។

**ស៖** កាលនោះ តើលោកត្រូវបានទទួលការបណ្ដុះបណ្ដាលដើម្បីបង្រៀនក្មេងៗឱ្យរៀន អាន រៀនសរសេរហ្នឹងទេ?

**ឆ៖** បាទ កាលនោះ គេឱ្យខ្ញុំបង្រៀនលោកប្រធាន។ បង្រៀនអានស្រះ រហូតដល់ប្រកប ដល់ ហើយឱ្យសៀវភៅកុមារដ្ឋានអីហ្នឹងមកជួយបង្រៀនក្មេងហ្នឹងដែរ លោកប្រធានបាទ។

**ស៖** បាទ ឥឡូវត្រឡប់មកនិយាយអំពីអ្នកជម្លៀសមកពីភ្នំពេញ មកពីតាកែវវិញ។ ពេលដែលពួកគេទៅដល់ភូមិ លោកនិយាយថា គេយកពួកហ្នឹងទៅដាក់ឱ្យនៅក្នុងសាលាមួយ ហើយសួរថា តើ <ក្រុមគ្រួសារទាំងអស់នោះត្រូវបានគេបង្ខំឱ្យសាងសង់ជម្រកស្នាក់នៅដោយខ្លួនឯង ឬក៏គេប្រគល់

កន្លែងស្នាក់នៅ>ស្រាប់<>?

**ឆ៖** បាទ កាលនោះ អត់មានសង់លំនៅដ្ឋានឲ្យទេ ព្រោះថាកាលនោះ ត្រូវបែងចែកកងគេយក បងប្អូនខាងទៅពីភ្នំពេញទៅយកមកដាក់កង៣ នៅភូមិតាសោមវិញបាទ។

**សៈ** បាទ ឥឡូវយើងនឹងត្រូវមកនិយាយអំពី កង៣ ហ្នឹងនៅពេលក្រោយទៀត។ នៅពេលដែល ពួកគេទៅដល់ តើប្រជាជន ១៧ មេសាហ្នឹង ត្រូវសរសេរប្រវត្តិរូបរបស់ខ្លួនដែរឬទេ?

**ឆ៖** បាទ អត់មានសរសេរប្រវត្តិរូបអីទេលោកប្រធាន ព្រោះទៅដល់គេដឹងថា ប្រជាជន១៧ មេសា ជម្លៀសមកពីភ្នំពេញហើយ ប្រធានភូមិគេដឹងហើយលោកប្រធាន មិនបាច់សរសេរប្រវត្តិរូបអី ទេបាទ។

**សៈ** ពីដំបូង អំមិញលោកនិយាយថា ពីដំបូង -- អ៊ីចឹង១ពេលក្រោយមកទៀត តើគេមានសួរ គេចោទសំណួរទៅលើអ្នកជម្លៀសទាំងអស់ហ្នឹងអំពីអតីតភាពរបស់ពួកគេទេ?

**ឆ៖** បាទ មិនដឹងមេភូមិ គេបានសួរដែរឬអត់លោកប្រធាន ខ្ញុំអត់សូវបាននៅជិតគេដែរទេ។ គ្រាន់តែដឹងថា មកជម្លៀសមកពីភ្នំពេញ ទៅនៅសាលាមួយនៅកណ្ដាលភូមិ បាទ។

[០៩:៣១:១៨]

**សៈ** តើលោកដឹងដែរឬទេថាកម្មាភិបាលក្នុងភូមិ <ឬនៅក្នុងឃុំ> កាលនោះគេ<ស្វែង>រក អតីតយោធា ឬក៏អតីត<អ្នករដ្ឋការ>នៃរបបលន់នល់ នៅក្នុងចំណោមអ្នក<>១៧មេសា<ដែរឬទេ>?

**ឆ៖** សួរ លោកប្រធានសួរម្ដងទៀត ខ្ញុំស្ដាប់អត់បាន។

**សៈ** បាទ ខ្ញុំសួរលោក ថាតើលោកដឹងដែរឬទេថាកម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិ ឬក៏ក្នុងឃុំ លោកហ្នឹង គេស្វែងរកអ្នកដែលគេជម្លៀសមកពីទីក្រុងភ្នំពេញ ពីតាកែវនោះ ក្នុងចំណោមពួកទាំងអស់ ហ្នឹង គឺយោធា ឬក៏អតីតមន្ត្រីរដ្ឋការរបបលន់ នល់។ អ៊ីចឹងខ្ញុំសួរលោកថា លោកដឹងទេ?

**ឆ៖** បាទ លោកប្រធានសួរខ្ញុំ ខ្ញុំបាទសូមឆ្លើយថា គេអត់មានសួរអីទេលោកប្រធាន គ្រាន់តែ មកដល់ហ្នឹង គេឲ្យនៅហ្នឹងទៅ ព្រោះថាអង្គការថ្នាក់លើ គេថាឲ្យប្រជាជននៅ១០គ្រួសារផង ព្រោះអត់ មានកន្លែងនៅទេ ព្រោះនៅភូមិតាសោម។ អ៊ីចឹងគេឲ្យនៅហ្នឹងសិនទៅ។ ហើយបន្ទាប់មកទៀត បានគេ ថា បើអ៊ីចឹងត្រូវប្រមូលកងឲ្យទៅនៅខាង កង៣ ទៀត។ អ៊ីចឹងគេដកចេញពីហ្នឹងទៀតទៅ ទៅនៅ កង ៣ លោកប្រធានបាទ។

**សៈ** បាទ សូមអរគុណ។ យើងនឹងត្រឡប់មកនិយាយអំពី កង១ <កង២> និង កង៣ នេះពេល

ក្រោយ។ ឥឡូវនេះ ដើម្បីបញ្ចប់រយៈពេលចន្លោះ១៧មេសា ឆ្នាំ៧៥ ដល់ឆ្នាំ១៩៧៦ លោកបាននិយាយថា លោកចាប់ផ្តើមបង្រៀនក្មេងឲ្យអានសរសេរហ្នឹងចាប់ពីឆ្នាំ១៩៧៦ ហើយបន្ទាប់មកទៀត លោកធ្វើការកម្លាំងពលកម្មច្រើន គឺទៅលើសែងដី រែកដីជាដើម។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកមានត្រូវបំពេញយ៉ាងម៉េចដែរ ក្នុង១ថ្ងៃត្រូវរែកដីប៉ុន្មានម៉ែត្រគូបជាដើម?

**ឆ៖** បាទ កំណត់ម៉ែត្រមិនឃើញទេលោកប្រធាន។ រែកតាមម៉ោង។ ម៉ោងប្រាំមួយព្រឹកអ៊ីចឹងទៅ ដល់ម៉ោងដប់មួយ ត្រូវចុះមកហូបបាយនៅតាមរោង កាស៊ីនបាយវិញលោកប្រធានបាទ។

**ស៖** ហើយនៅពេលរសៀល តើលោកធ្វើការដល់ម៉ោងប៉ុន្មាន តើលោកធ្លាប់ធ្វើការពេលយប់ដែរឬទេ?

**ឆ៖** បាទពេលរសៀលចាប់ពីម៉ោងពីរដល់ម៉ោងប្រាំល្ងាច ហើយពេលយប់ អត់សូវបានធ្វើដែរលោកប្រធាន ព្រោះពេលយប់គេអត់ឲ្យទៅធ្វើដែរឬទេ ខាងកសិករ។ បើកុមារខាងប្រមូលផ្តុំ ហ្នឹងគេឲ្យធ្វើបាទ។

**ស៖** បាទ នៅសម័យនោះ ពេលដែលលោកធ្វើការរែកដីនោះ តើលោកមានសិទ្ធិពិភាក្សាគ្នានិយាយគ្នា ឬក៏តវ៉ាពីបញ្ហា ឬក៏ត្អូញត្អែរអីទេ?

**ឆ៖** បាន លោកប្រធាន ត្អូញត្អែរអត់បានទេលោកប្រធាន មេកងគេនៅហ្នឹង។ ត្អូញត្អែរមានរឿងហើយលោកប្រធាន គេហៅទៅណែនាំទៅដែល -- ហៅទៅ -- យើងទៅកន្លែងមួយស្ងាត់ៗអ៊ីចឹងគេព្រមានយើង លោកប្រធានបាទ។

[០៩:៣៦:០២]

**ស៖** បាទ សូមអរគុណ។ បាទ ឥឡូវ ខ្ញុំសូមចូលមកនិយាយពីរយៈពេលបន្តមកទៀត លោកបានឆ្លើយតបទៅនឹងសំណួរខ្លះហើយ ទាក់ទងទៅនឹងកងមួយចំនួននៃសហករណ៍ហ្នឹងគឺកង១, កង២ កង៣ហ្នឹង ដែលត្រូវបានបង្កើតឡើងនៅក្នុងឃុំសំរោង។ ហើយអ៊ីចឹងជាការចាប់ផ្តើម ខ្ញុំសូមអានពីអ្វីដែលលោកបានឆ្លើយត្រង់ប្រធានបទនេះ នៅក្នុងចម្លើយរបស់លោកនៅទី១២ គឺឯកសារ E3/5515 លោកបានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “នៅក្នុងឆ្នាំ១៩៧៦ គេបានបែងចែកប្រជាជនឲ្យរស់នៅតាមសហករណ៍។ នៅក្នុងឃុំសំរោងមានបីសហករណ៍ធំៗ។ ការបែងចែកសហករណ៍នោះគឺសំដៅទៅលើប្រជាជនប្រភេទទី១ គេហៅថា កង១ ជាប្រជាជនមូលដ្ឋាន (ដែលគេហៅថាចាស់ពេញសិទ្ធិ) ដែលមានទីតាំងស្ថិតនៅក្នុងភូមិអង្គពណ្ណរាយ ប្រភេទទី២ ឬកងទី២គឺប្រជាជនមូលដ្ឋាន(ហៅត្រៀម) ដូចគ្នា

ដែរ គឺមានបងប្អូនជាប់ពាក់ព័ន្ធ ឬក៏ជាប់និន្នាការជាមួយខ្មាំងដែលមានទីតាំងស្ថិតនៅភូមិប៉ែនមាស។ ចំណែកប្រភេទទី៣ ឬក៏កងទី៣នេះ ជាប្រជាជនដែលជម្លៀសចេញពីភ្នំពេញឬគេហៅថាអ្នក១៧មេសា ឬក៏ប្រជាជនបញ្ញើដែលមានទីតាំងស្ថិតនៅភូមិតាសោម"។ បាទ ខ្ញុំសូមបញ្ចប់ការដកស្រង់។

លោកនិយាយថាហ្នឹងនៅឆ្នាំ១៩៧៦ តើ ខ្ញុំសួរលោក ថាតើលោកចាំទេ ថាតើនៅដើមឆ្នាំ៧៦ឬក៏ពាក់កណ្តាលឆ្នាំ៧៦ ឬក៏ចុងឆ្នាំ៧៦?

[០៩:៣៨:១៤]

**ឆ៖** បាទ កាលគេជម្លៀសប្រជាជនមូលដ្ឋានឱ្យទៅនៅអង្គពណ្ណរាយ គេហៅថាតាលាក់ខាងលិចហ្នឹង ដែលដើមឆ្នាំ១៩៧៦ លោកប្រធានបាទ។

**ស៖** តើលោកបានដឹងឬក៏មានអ្នកណាប្រាប់លោកថាអ្នកណាគេជាអ្នកសម្រេចបែងចែកប្រជាជននៅឃុំសំរោងនេះជាបីប្រភេទដាច់ពីគ្នានេះ? តែប្រសិនជាលោកដឹងឬក៏មានគេប្រាប់លោក តើគេបែងចែកហ្នឹងដោយឈរលើលក្ខណៈវិនិច្ឆ័យអ្វីខ្លះ?

**ឆ៖** បាទ លោកប្រធាន ខ្ញុំអត់បានដឹងដែរព្រោះថាដល់ថ្ងៃហ្នឹង គេប្រាប់ថាតាឯងត្រូវតែនៅអង្គពណ្ណរាយ នៅតាលាក់ខាងលិច កង១។ ហើយត្រូវជម្លៀសពួកខាងហ្នឹងឱ្យមកនៅកង២វិញ។ វាជ្រើសរើសអ៊ីចឹងវាដូរគ្នាលោកប្រធានបាទ។ មិនដឹងថាវាដូរគ្នារឿងអី ខ្ញុំវាអត់បានដឹងដែរលោកប្រធានបាទ។ មិនដឹងអ្នកណាសម្រេចឱ្យដូរទៀតបាទ។

**ស៖** បើអ៊ីចឹង បើខ្ញុំយល់មិនច្រឡំទេ គឺថាលោកចាកចេញពីភូមិប៉ែនមាសរបស់លោកដែលមានកង២នៅទីហ្នឹង លោកៗចេញពីប៉ែនមាសហ្នឹងទៅភូមិអង្គពណ្ណរាយ។ អ៊ីចឹងមែនទេ? ហើយនៅភូមិអង្គពណ្ណរាយហ្នឹង លោករស់នៅកន្លែងណាដែរ?

[០៩:៤០:០២]

**ឆ៖** បាទ ខ្ញុំបាទរស់នៅខាងលិចវត្តអង្គពណ្ណរាយ ឃៀងខាងត្បូងបន្តិចលោកប្រធានបាទ នៅជាមួយកុមារកង១។

**ស៖** បើសិនខ្ញុំយល់មិនច្រឡំទេគឺថា លោកស្នាក់នៅទីនោះដោយសារលោកជាគ្រូបង្រៀនគឺមិនមែនដោយសារលោកជាកុមារទេ មែនទេ?

**ឆ៖** បាទ កាលនោះខ្ញុំគេចាត់ឱ្យមើលក្មេងលោកប្រធាន មិនមែនថាជាគ្រូអីពេញសិទ្ធិអីទេបាទ គេចាត់ឱ្យជួយមើលក្មេងរើសអាចម៍គោ បង្រៀនក្មេងខ្លះៗឱ្យវាចេះអក្សរ ហើយថ្ងៃរសៀលមើលគោអី

អ៊ីចឹងទៅ បាទ១០០ក្បាល ក្មេង១០០នាក់ បាទ។

**ស៖** លោកបាននិយាយថាទាក់ទងនឹងកងទី២នេះគឺៗជាប្រជាជនមូលដ្ឋានហើយគឺជាប្រជាជនមូលដ្ឋាន ដែលជាប់និន្នាការខ្លាំង ទៅរកខ្លាំង។ តើកាលនោះនុ៎ងខ្លាំងជាអ្នកណា? តើខ្លាំងផ្ទៃក្នុងឬក៏ខ្លាំងៗនៅខាងក្រៅ? តើគេធ្លាប់និយាយប្រាប់លោកក្នុងពេលប្រជុំដែរឬទេ ឬក៏លោកធ្លាប់មានឱកាសនិយាយជាមួយកម្មាភិបាលខ្មែរក្រហមអំពីការជាប់និន្នាការ ឬក៏ជាប់ពាក់ព័ន្ធនេះ?

**ឆ៖** បាទ លោកប្រធាន មិនមែនខ្លាំងក្នុងក្រៅអីទេ ព្រោះថាគេជ្រើសរើសនេះជ្រើសរើសដើម្បីធ្វើការងារ ព្រោះថាការងារកាលណាកង១ គេធ្វើលឿន បាទកាលណាវាលឿនទៅគេបានដែលពេញសិទ្ធិជាកង១ អ៊ីចឹងទៅបាទ ហើយដល់កង២ ធ្វើការអត់សូវលឿន អាហ្នឹងគេទុកជាកង២អ៊ីចឹងទៅបាទ បើកង៣ ខាងចេញពីភ្នំពេញមកហ្នឹងគេទុកជាកង៣ហ្នឹង។ អាហ្នឹងខាងដែលកង៣ហ្នឹងដែលចេញមកពីភ្នំពេញ គេហៅថា "ប្រជាជន១៧មេសា"បាទ។ ហើយមកពីខាងត្បូងហ្នឹងទុកជាប្រជាជនកណ្តាលៗកង២បាទ ហើយកង១ខ្ញុំ អាហ្នឹងទុកថាធ្វើការលឿនទៅអាហ្នឹងគេហៅថា "កង១"។ មិនមែនជ្រើសរើសជារបៀបខ្លាំងអីទេ អត់ទេបាទ លោកប្រធានបាទ។

[០៩:៤៣:១២]

**ស៖** តើលោកដឹងដែរឬទេថាការបែងចែកជាបីក្រុម បីប្រភេទនេះនៅក្នុងឃុំសំរោងនោះ មានៗការបែងចែកដូចគ្នាទេនៅឃុំក្បែរៗឃុំសំរោងហ្នឹងនៅក្នុងស្រុកត្រាំកក់ដូចជា ឃុំគុស ឃុំត្រពាំង <តាភេម> ត្រពាំងធំ ស្រែ<រនោង> <ឬជាងទង>។ តើលោកមានដឹងដែរឬទេថា នៅក្នុងឃុំដែលខ្ញុំរៀបរាប់អម្បាញ់មិញនេះ មានការបែងចែកប្រជាជនជាបីប្រភេទអ៊ីចឹងដែរ?

**ឆ៖** បាទ រឿងបែងចែកជាបីប្រភេទហ្នឹង ខ្ញុំបាទបាន -- អត់បានដឹងទេលោកប្រធាន អត់បានសួរគេព្រោះថាកាលនោះ នៅកន្លែងណា កន្លែងហ្នឹងហើយបាទ អត់ប៉ានដើរទៅណាសួរនាំអីទេ នាំតែមានរឿងហេតុអីពិបាក។ នៅធ្វើការនៅអង្គពណ្ណរាយ នៅតែអង្គពណ្ណរាយហ្នឹង បង្រៀនក្មេងនាំក្មេងរើសអាចម៍គោអីអ៊ីចឹងទៅបាទ អត់ប៉ានដើរសួរគេចេះចុះអី ខ្លាចមានទោសពៃបាទ។ មិនថាមូលដ្ឋានក៏គេយកទោសដែរបាទ អត់មានចាំបាច់ ១៧ អីទេបាទ។

**ស៖** តើនៅពេលនោះលោកធ្លាប់<ឮ>កម្មាភិបាលខ្មែរក្រហមក្នុងភូមិ ឬក្នុងសហករណ៍<>កង១នោះ និយាយអំពីអ្នកសុទ្ធ ឬមិនសុទ្ធ ស្អាតស្អំ ហើយនិងមិនស្អាតស្អំដែរឬទេ លោកធ្លាប់ឮគេនិយាយពីរឿងហ្នឹងទេ?

**ឆ៖** បាទ គេនិយាយដែរលោកប្រធាន។ អ្នកស្អាតស្អំហ្នឹង គេយកសំដៅអ្នកមានទ្រព្យអ៊ីចឹងទៅ គេឲ្យទៅខាងត្បូងអ៊ីចឹងទៅ ហើយអ្នកគ្នាអត់សូវមានទ្រព្យកាលពីមុននោះ ហ្នឹងគេអត់ឲ្យទៅទេ គេឲ្យនៅខាងជើង ប៉ុន្តែប៉ែនមាសដូចគ្នាដែរ តែគេឲ្យទៅតែពួកណាដែល ពួកហ្នឹងមានបាទ ទ្រព្យសម្បត្តិហ្នឹងគួរសម ហើយមើលចរិយាអ៊ីចឹងទៅ ហើយគេរើសកងហ្នឹង រើសដើម្បីចូលសិទ្ធិត្រៀមផ្ញើហ្នឹង លោកប្រធាន បាទ។

**ស៖** បាទខ្ញុំមិនយល់ពីការបែងចែករឿងអ្នកស្អាតស្អំ ហើយនិងមិនស្អាតស្អំ។ លោក ខ្ញុំសួរថាតើក្រុមកង១នេះ ដែលៗហៅប្រជាជន<មូលដ្ឋាន>ពេញសិទ្ធិនេះ គេកាលនោះគេចាត់ទុកថា ជាអ្នកស្អាតស្អំ ឬក៏<អ្នក>មិនស្អាតស្អំ?

**ឆ៖** បាទប្រជាជនពេញសិទ្ធិហ្នឹង គេរើសអ្នកស្អាតស្អំលោកប្រធាន បាទ អ្នកស្អាតស្អំ ហើយខាងអង្គពណ្ណរាយត្រូវដូរមកខាងប៉ែកមាសហ្នឹងដែរ បាទ។ ដូរចុះដូរឡើង លោកប្រធាន បាទ។

**ស៖** តើគេមានពន្យល់ប្រាប់លោកដែរឬទេថា តើប្រជាជនចាស់ពេញសិទ្ធិហ្នឹង មានន័យយ៉ាងម៉េចដែរ ធៀបទៅនឹងប្រជាជនត្រៀម? អ៊ីចឹង សួរលោកថា តើលោកធ្លាប់ -- គេមានពន្យល់ពីការ -- ពីភាពខុសគ្នារវាងពាក្យទាំងពីរហ្នឹងទេ?

[០៩:៤៧:១៧]

**ឆ៖** បាទគេមានពន្យល់ដែរ លោកប្រធាន។ គេថា អ្នកដែលត្រៀមហ្នឹង ត្រៀមចូលពេញសិទ្ធិដូចគ្នាដែរ ប៉ុន្តែគេត្រៀមសិន គេកែបានល្អ គេចូលពេញសិទ្ធិទាំងអស់វិញ លោកប្រធានបាទ។

**ស៖** បាទ បើតាមលោកដឹង តើប្រភេទប្រជាជនណាដែលគេចាត់ទុកថា អ្នកដែលស្អាតស្អំជាងគេក្នុងចំណោមប្រភេទទាំងបី? តើកងណា កង -- ចង់និយាយថា តើកង១ កង២ ឬកង៣? កងទាំងបីហ្នឹង កងណា កងស្អាតស្អំ បើតាមការយល់ដឹងរបស់ខ្មែរក្រហម?

**ឆ៖** បាទ បើតាមខ្ញុំយល់ដឹងថា ជ្រើសរើសកង១ ស្អាតជាងគេបំផុត។ កង២ អាហ្នឹងមធ្យម បាទកង៣ ហ្នឹងក្រោមគេបំផុតបាទ។ ខ្ញុំបាទដឹងតែប៉ុណ្ណឹង លោកប្រធាន បាទ។

**ស៖** តើអ្នកធ្វើការនៅកង១ ដែលធ្វើការនៅភូមិអង្គពណ្ណរាយជាមួយលោកនេះ តើមានធ្លាប់មានទេ ដែលគេដកប្រជាជនចេញពី<កង១>ហ្នឹង <>ហើយបញ្ជូនទៅ<កង២ នៅ>ប៉ែនមាសវិញនោះ។ ធ្លាប់មាន កើតមានឡើងទេ?

**ឆ៖** បាទ អត់សូវ អត់មានទេលោកប្រធាន។ តែគេរើសៗហើយលោកប្រធាន គេរើសដូរ

ហើយៗហ្នឹង។ ពេលគេដូរហ្នឹង គេជ្រើសរើសហើយគេដូរចុះដូរឡើងហើយ នៅស្ងៀមហើយ លែងគិតតែពីរឿងការងារវិញហើយបាទ។

[០៩:៤៩:៣៤]

**ស៖** តើលោកដឹងទេថា មានភាព ថាមានភាពខុសគ្នាផ្នែកវិន័យនៅក្នុងកង១ ដែលគេចាត់ទុកថាជាក្រុមស្អាតស្អំជាងគេ ហើយនិងនៅក្នុងកងទី២ ដែលគេចាត់ទុកថា មិនសូវស្អាតស្អំ។ អ៊ីចឹងសួរថា តើលក្ខខណ្ឌការងារ ឬក៏វិន័យ<នៅក្នុង>កង២នេះ តឹងរ៉ឹងជាងកង១ អ៊ីចឹងមែនទេ?

**ឆ៖** បាទ បើតាមការពិតទៅវិន័យដូចគ្នាលោកប្រធាន តែការងារខាងកង១ ហ្នឹងគេលឿនជាងបាទ។ គឺធ្វើស្រែ ឧបមាថា ១០នាក់ហ្នឹងមួយហិកតាឲ្យហើយក្នុងមួយព្រឹក នង្គ័លប្រាំ រនាស់ពីរអ៊ីចឹងទៅបាទ។

**ស៖** បាទ សូមអរគុណ។ តើធ្លាប់មានកើតឡើងដែរឬទេ នៅក្នុងពេលនោះសមាជិកកង៣ គឺបានន័យថា គឺជាប្រជាជនថ្មី ត្រូវបានគេដំឡើងបុណ្យសក្តិ ហើយបញ្ចូលមកកង២ ឬក៏កង១ វិញ ដោយ<សារតែធ្វើ>ការងារល្អ។ ធ្លាប់មានទេ រឿងបែបហ្នឹង?

**ឆ៖** បាទ អត់មានទេលោកប្រធាន។ អត់ទាន់បានបញ្ចូលទេលោកប្រធាន ព្រោះកាលនោះ គេរៀបចំកង២ ហ្នឹងឲ្យចូលមកកង១ វិញ តែរៀបចំដែរ តែវាពេលនេះទៅវាត្រូវអ៊ីចឹងទៅ អត់បានរៀបចំវិញទៅលោកប្រធាន បាទ។

**ស៖** បាទ លោកនិយាយអំពីកង១ កង២ កង៣ តើសម័យនោះ គេនិយាយពីក១, ក២, ក៣ ឬក៏ខ្ញុំយល់មិនត្រឹមត្រូវទេ? យល់បែបនេះនោះ។ កាលនោះ គេហៅ ក១, ក២, ក៣ មួយក៏ កង១, កង២, កង៣?

**ឆ៖** គេហៅ កង១, កង២, កង៣ លោកប្រធាន បាទ។ គេអត់មានហៅ ក១, ក២ លោកប្រធាន។ ហើយគេហៅពេញសិទ្ធិ ត្រៀម ផ្ញើ។ សូមជម្រាបលោកប្រធានប៉ុណ្ណឹង។

[០៩:៥២:២៧]

**ស៖** បាទ ទាក់ទងទៅនឹងលក្ខខណ្ឌការងារ ហើយនិងជីវភាពនៅក្នុងកង១។ បាទ ខ្ញុំសូមអានសម្រង់មួយនៃចម្លើយរបស់លោក គឺ E3/5515 នៅចម្លើយទី១៥ លោកបានឆ្លើយថា៖ “ក្នុង<សហករណ៍>នីមួយៗគេបែងចែក ដូចជា កងពិសេស កងភ្ជួរ(មានប្រុសៗ) កងជីកប្រឡាយ កងដកស្ទូង (ស្រីៗ) កងរទេះ កងអារឈើ កងកុមារ (គឺកុមារា-កុមារី) ហើយនិង<កង>កុមារប្រមូលផ្តុំ”។ នៅ

ចម្លើយទី១៦ លោកឆ្លើយថា៖ “បន្ទាប់ពី<កិនស្រូវរួច គេបែងចែកអង្ករទៅតាមសហករណ៍>។ រាល់ព្រឹក សហករណ៍នីមួយៗ <គឺមនុស្សពីរនាក់មកពីផ្នែកចង្ក្រានបាយ ទៅឃុំ>ដើម្បីយកអង្ករ បន្លែ ប្រហុក ត្រីសាច់ អំបិល សម្រាប់មួយថ្ងៃៗ”។ បាទ សូមបញ្ចប់ការដកស្រង់។ តើស្រូវអង្ករនៅក្នុងឃុំសំរោងនោះ ត្រូវបែងចែកទៅជាបី -- ទាំងបីកងហ្នឹង ឬក៏ស្រូវអង្ករដែលប្រមូលបានហ្នឹង បញ្ជូនទៅថ្នាក់លើ ត្រូវបានបញ្ជូនទៅថ្នាក់លើទេ?

[០៩:៥៤:១៤]

**ឆ៖** ស្រូវអង្ករធ្វើបានទុកនៅក្នុងឃុំសំរោងខ្លះ បញ្ជូនទៅថ្នាក់លើខ្លះដែរ លោកប្រធាន។ បាទ ទុកគ្រាន់មួយគ្រប់ នៅក្នុងកង៣ហ្នឹង។ កង១, កង២, កង៣ ហ្នឹងទុកគ្រប់គ្រាន់សម្រាប់ដល់ខែច្រូតវិញ ហើយការសល់ពីនោះបញ្ជូនមកថ្នាក់លើវិញបាទ។

**ស៖** បាទ ខ្ញុំមិនសូវយល់ដែរ ពេលដែលខ្ញុំឆ្លើយ -- អានចម្លើយទី១១ របស់លោកនោះ គឺថាផលស្រូវទាំងអស់នោះបែងចែកទៅក្នុងសហករណ៍ទាំងអស់ ហើយលោកនិយាយថា មានស្រូវ មាន<បន្លែ> មាន<ត្រីងៀត ត្រី>ស្រស់ មាន<សាច់ និង>អំបិល។ អ៊ីចឹង ខ្ញុំសួរថា តើលោកដឹងថា កង២ ហើយនិង កង៣ហ្នឹង គាត់ហូបចុកអីដែរកាលណោះ?

**ឆ៖** បាទ កង២ និងកង៣ មកយកអង្ករនៅសាលាឃុំអង្គពណ្ណរាយដែរលោកប្រធាន មកយកអង្ករហ្នឹងដូចតែគ្នាទេ។ មានគេបររទេះមកដឹក ព្រលឹមៗឡើងមកដឹកហើយលោកប្រធាន បាទ។

**ស៖** បាទ ទាក់ទងទៅនឹងអ្នកធ្វើការនៅកង១ តើ<ពួកគេ>មានការហូបចុកគ្រប់គ្រាន់ទេចន្លោះឆ្នាំ ១៩៧៦ ដល់ឆ្នាំ១៩៧៩ បើធៀបទៅនឹងប្រជាជនមូលដ្ឋានទាំងអស់គ្នាហ្នឹង?

**ឆ៖** បាទ ប្រជាជននៅកង១របស់ខ្ញុំហ្នឹងឃើញថា ហូបបានបាយម្នាក់មួយចាន សម្លហ្នឹងមួយចានធំ គ្នា៨នាក់ ប៉ុន្តែបាយហ្នឹង គេចែកហើយលោកប្រធាន។

[០៩:៥៦:៣៩]

**ស៖** អ៊ីចឹង បើខ្ញុំយល់មិនច្រឡំទេគឺថា <លោកមិនបាននិយាយអំពីសាច់ ឬក៏ត្រីទេ។> សួរថា តើ <លោកហូប>ត្រី សាច់អី<រៀងរាល់ថ្ងៃ> ជាទៀងទាត់ដែរឬទេ? <ឬក៏មិនសូវញឹកញាប់>ទេ?

**ឆ៖** បាទ មានត្រីខ្លះអ៊ីចឹងដែរ លោកប្រធាន។ បាទ សម្លត្រកួនហ្នឹងមានត្រីខ្លះដែរ។ ពេលនេះគេចាត់សេដ្ឋកិច្ចឲ្យទៅបង់ត្រី ឲ្យទៅអូសត្រីអ៊ីចឹងដែរលោកប្រធាន។

**ស៖** បាទ ខ្ញុំអាននូវចម្លើយទី២២ របស់លោក៖ “<គេឲ្យយើង>ហូបចុក ពីរដងមួយថ្ងៃគឺថ្ងៃ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ត្រង់ ហើយនិងល្ងាច។ យើងមិនមានការហូបចុកគ្រប់គ្រាន់ទេ អ្នកផ្សេងក៏ដូចខ្ញុំដែរ។ យើងបានបាយមួយចានម្នាក់ ហើយនិងសម្លត្រកួនមួយចាននៅកណ្ដាលធំ។ ក្នុងរយៈពេល១០ថ្ងៃ គេកាប់គោឲ្យហូបម្ដង"។ អ៊ីចឹង ក្នុងចម្លើយនេះ លោកឆ្លើយថា "អត់មានការហូបចុកគ្រប់គ្រាន់ទេ" ក៏ប៉ុន្តែទន្ទឹមនឹងនោះលោកនិយាយថា "លោកនៅក្នុងកងល្អជាងគេ ហើយស្អាតស្អំជាងគេ <ជាអ្នកមូលដ្ឋាន> ពេញសិទ្ធិ"។ អ៊ីចឹង ហេតុអីបានជានៅក្នុងកងល្អជាងគេនេះ អត់មានអាហារហូបចុកគ្រប់គ្រាន់?

**ឆ៖** រឿងហូបចុក ប្រហែលតែគ្នាទេលោកប្រធាន។ ខាងកង១ ក៏ដូចកង២ ក៏ដូចកង៣។ ក៏ដូចកង១ ដែរលោកប្រធាន ហូបចុកដូចតែគ្នាទេ ប៉ុន្តែការងារវាលើសគេដែរ។ ឧបមា កង១ គេធ្វើការហ្នឹងវាលឿន កាលណាលឿនទៅវា អាសេដ្ឋកិច្ចហ្នឹងវាតម្លើងលើសគេបន្តិចដែរ មិនមែនថាអត់ទេ។ ឧបមាថា បាយខាងកង២ គេពីរវែក ខាងកង១ហ្នឹង មុខតែបីវែកហើយ លោកប្រធាន បាទ។ លើសគេបន្តិចដែរ លោកប្រធាន។

[០៩:៥៩:១០]

**ស៖** ទាក់ទងទៅនឹងកង២ និងកង៣ ដែលនៅក្នុងឃុំផ្សេងទៀតដូចឃុំប៉ែនមាស ហើយនិងឃុំសោម តើលោកធ្លាប់បានទៅរោងបាយនៅឃុំទាំងអស់ហ្នឹង ហើយដើម្បីមើលឲ្យដឹងថា ពួកគេនោះបានអីហូបចុកដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលបានទៅជួបទេ លោកប្រធាន។ បងប្អូននៅខាងប៉ែនមាស កាលហ្នឹង ខ្ញុំនៅអង្គពណ្ណរាយ អត់ដែលបានមកទេ គេអត់ឲ្យមកផងហ្នឹង។ ខាងតាសោមរឹតតែអត់ទៀតលោកប្រធាន។ ស្រឡះបន្តិច អត់ដែលបានទៅផង គេអត់ឲ្យដើរ។

**ស៖** អ៊ីចឹង ពេលដែលលោកនិយាយថា លោកមិនមានការហូបចុកគ្រប់គ្រាន់នោះ គឺលោកនិយាយសម្រាប់កងមួយនេះហើយ ហើយលោកមិនដឹងពីអ្វីដែលកើតឡើងនៅកង២ ឬកង៣ ទេ។ តើខ្ញុំនិយាយអ៊ីចឹង ត្រឹមត្រូវទេ?

**ឆ៖** បាទ អ៊ីចឹងត្រឹមត្រូវហើយ លោកប្រធាន។ ខ្ញុំអត់បានដឹងដែរថា កង១ កង២ អត់ដែលបានមក គេអត់ឲ្យមក នៅកន្លែងណា កន្លែងហ្នឹង។ គ្រាន់តែសុំមកលេងបន្តិច គេអត់ឲ្យមកផង បាទ។

**ស៖** បាទ សូមអរុណ។ លោកសាក្សី អ៊ីចឹង នៅពេលដែលលោកមិនដឹងទេ អ៊ីចឹងសូមលោកប្រាប់ខ្ញុំថាមិនដឹងទេ។ តើអ្នកនៅក្នុងកង១ បើតាមៗរបបហូបចុកដែលគេឲ្យនោះ ពួកអ្នកធ្វើការកង១នេះមានត្អូញត្អែរទេ?

**ឆ៖** បាទ មានត្អូញត្អែរដែរ តែអត់ឲ្យប្រធានកងគេឮ លោកប្រធាន បាទ។ គេឮ គេយកទៅណែនាំ គេយកទៅអប់រំ ប៉ុន្តែគេមិនសម្លាប់ទេ គ្រាន់ថាអប់រំ។ ថ្ងៃក្រោយថ្ងៃមុខ គេលែងឲ្យនិយាយអារឿងមិនឆ្អែតអីចឹងៗ បាទ។

[១០:០១:៣០]

**ស៖** បាទ ខ្ញុំសូមអានអ្វីដែលលោកបានឆ្លើយទាក់ទងទៅនឹងឈ្មោះ តារិន នៅចម្លើយទី២១ របស់លោក គឺឯកសារ E3/5515 លោកនិយាយដូចតទៅនេះ៖ "នៅក្នុងក្រុមរបស់ខ្ញុំឈ្មោះ តារិន (គឺកងរទេះ) ត្រូវបានចាប់ខ្លួនយកទៅមន្ទីរក្រាំងតាចាន់។ ដោយគេចោទថា គាត់មានទំនាស់ពីរឿងហូបមិនឆ្អែត នៅពេលគាត់និយាយ គេមានរាយការណ៍ទៅថ្នាក់លើ ហើយក៏ត្រូវបានចាប់ខ្លួនតែម្តង។ ប្រធានកងរទេះឈ្មោះ ឡាក់តឹង គាត់រស់នៅភូមិស្វូត្រថ្មី"។ សូមបញ្ចប់ការដកស្រង់។ តើលោកចាំរឿងរ៉ាវនេះទេ ដែលឈ្មោះ តារិន ត្រូវគេចាប់បញ្ជូនទៅក្រាំងតាចាន់ ដោយសារគាត់ហ្នឹង ត្អូញត្អែរថាគាត់ហូបចុកមិនឆ្អែត លោកចាំរឿងហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំអត់បានចាំ លោកប្រធាន។ ខ្ញុំគ្រាន់តែដឹងថា គេចាប់គាត់ទៅក្រាំងតាចាន់ ប៉ុនខ្ញុំអត់ដែលបានទៅក្រាំងតាចាន់ដែរ។ គ្រាន់តែគេថា "តារិន ទៅណា?" ហើយគេខ្សឹបខ្ញុំថា "គេយកទៅក្រាំងតាចាន់បាត់ហើយ"។ តែប៉ុណ្ណឹងទេ លោកប្រធាន។

**ស៖** តើលោកដឹងដែរឬទេ នៅសម័យនោះ ក្រាំងតាចាន់នោះជាអ្វី? គេប្រើសម្រាប់អ្វី? ហើយលោកធ្លាប់ឮគេនិយាយអ្វីខ្លះអំពីក្រាំងតាចាន់នេះ?

**ឆ៖** បាទ នៅក្រាំងតាចាន់នោះ គេអត់ឲ្យដឹងផង លោកប្រធាន។ គេថា មានមន្ទីរឃុំឃាំងអីកន្លែងហ្នឹង ប៉ុនថារឿងសម្លាប់រឿងអី គេអត់ឲ្យប្រជាពលរដ្ឋដឹងទេ លោកប្រធានទេ គេបិទ បាទ គេបិទ។

**ស៖** តើ<ធ្វើម៉េច>លោកដឹងថា តារិន ត្រូវបានគេបញ្ជូនទៅក្រាំងតាចាន់នោះ<ច្បាស់ម្ល៉េះហើយ>មិនបញ្ជូនទៅកន្លែងផ្សេង<?> អ្នកណាគេប្រាប់លោក ថាគេបញ្ជូនគាត់ទៅក្រាំងតាចាន់ហើយ?

[១០:០៤:០៣]

**ឆ៖** បាទ គេប្រាប់ខ្ញុំថាបញ្ជូន "តារិន ទៅក្រាំងតាចាន់" ហើយកងរទេះដូចគ្នាហ្នឹង លោកប្រធាន កងរទេះបររទេះជាមួយគ្នា។ បើយកទៅ ដឹងថាយកទៅហ្នឹងហើយ អត់មានកន្លែងណាទៀត លោកប្រធាន បាទ។

**ស៖** បាទ លោកនិយាយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកដដែល គឺលោកនិយាយពីក្រាំងតាចាន់ហ្នឹង ហើយលោកនិយាយពីការរៀបការផងដែរ។ ខ្ញុំសូមដកស្រង់នៅចម្លើយទី៣២៖ "បើសិនជាគូណាមិនចុះសម្រុងនឹងគ្នា ហើយឈ្លបដឹងរាយការណ៍ទៅថ្នាក់លើ ព្រឹកឡើងហ្នឹងគេនឹងហៅទៅណែនាំ ដោយគំរាមថានឹងយកទៅទីណាមួយ ដូចជាយកទៅក្រាំងតាចាន់ជាដើម"។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងលោកនិយាយថា ដឹងថាក្រាំងតាចាន់នោះជាមន្ទីរឃុំឃាំងដឹងតែប៉ុណ្ណឹងទេ។ ក៏ប៉ុន្តែកន្លែងនេះ លោកនិយាយថា ឃើញថា មានថា ការគំរាមថា បើមានបញ្ហាអីបញ្ជូនទៅក្រាំងតាចាន់។ តើលោក <មិនដែល>ឮកម្មាភិបាលណាមួយ ឬក៏អ្នកធ្វើការជាមួយគ្នាណាមួយនិយាយអំពីអ្វីដែលកើតមានឡើងនៅក្រាំងតាចាន់ <ទេឬ>?

**ឆ៖** បាទ គឺនិយាយដែរណាលោកប្រធាន។ គេថាក្រាំងតាចាន់ជាមន្ទីរឃុំឃាំង គេថាតែប៉ុណ្ណឹង។ ត្រង់គេសម្លាប់ ឬមិនសម្លាប់ ខ្ញុំអត់បានដឹងដែរ លោកប្រធាន គេបិទអត់ឲ្យដឹង អត់ឲ្យប្រជាពលរដ្ឋដឹងទេ បាទ។

**ស៖** បាទ ឥឡូវត្រឡប់និយាយពី តាវិន នៅពេលគេគាត់ចាប់ ហើយនាំគាត់ទៅ តើលោកដឹងថាកាលនោះ នៅឆ្នាំណាដែរ ហើយរដូវណាដែរ ដែលគេចាប់គាត់នោះកាលហ្នឹង?

[១០:០៦:១៧]

**ឆ៖** ចាប់ តាវិន នៅឆ្នាំ១៩៧៦ ពាក់កណ្ដាលឆ្នាំ លោកប្រធាន។ ជិតដាច់ឆ្នាំ ហើយលោកប្រធាន ធ្វើកង់រទេះជាមួយគ្នាដែរហ្នឹង។ ប៉ុនខ្ញុំ ខ្ញុំធ្វើគ្រូបង្រៀនពីឆ្នាំ ជិតដាច់ឆ្នាំ៧៧ហើយបាទ ហើយខ្ញុំនៅបររទេះជាមួយគាត់ដែរកាលហ្នឹង។ ជាមួយ តាតឹង ដែរហ្នឹងលោកប្រធាន។

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមអានសម្រង់ឯកសារមួយ គឺឯកសារ E3/4084 <ឯកសារថតចម្លង>ជាភាសាខ្មែរនោះពិបាកអាន គឺជា<សេចក្ដីសង្ខេបកិច្ចប្រជុំគណៈឃុំ>តាភេម ហើយចុះថ្ងៃទី ១៣ ឧសភា ១៩៧៧ មានលើកឡើងដូចតទៅនេះ ខ្ញុំសូមដកស្រង់ "ឃុំតាភេម ស្រុកត្រាំកក់ សេចក្ដីរាយការណ៍គោរពជូនអង្គការជាទីគោរព។ នៅថ្ងៃទី៧ ឧសភា ឆ្នាំ១៩៧៧ <បុរសម្នាក់ឈ្មោះ> ប៊ិត វិន <ជាប្រជាជន>ថ្មី អតីតទាហាន នៅភូមិស្រែ<ជំរៅ> ឃុំសំរោង បានមកផ្សព្វផ្សាយដំណឹងមួយទៅ<ប្រជាជនមកពី>កម្ពុជាក្រោមដែលរស់នៅ<ភូមិ>សំរោង ឃុំតាភេម<។"> បាទ ខ្ញុំអានជាភាសាអង់គ្លេសពីព្រោះអីជាភាសាបារាំងអត់ច្បាស់។ "គាត់មកផ្សព្វផ្សាយដំណឹងទៅប្រជាជនមកពីកម្ពុជាដែលរស់នៅក្នុងភូមិសំរោង ឃុំតាភេម> តាមដំណឹងនេះ អង្គការបាននាំជនរួមជាតិនៅឃុំសំរោងទាំង

អស់នោះហើយទៅ <ហើយអង្គការនឹង>ធ្វើដូចគ្នា<ចំពោះប្រជាជននៅក្នុងភូមិតាភេម គឺ>បានន័យថា រក្សាជោគវាសនាដូចគ្នា<>"។ ឯកសារមួយទៀតគឺឯកសារ <D157.55 គឺធ្វើក្នុងថ្ងៃតែមួយ គឺថ្ងៃទី ១៣ ខែឧសភា ឆ្នាំ១៩៧៧ ជូនសមមិត្តប្រធានឃុំសំរោង។> ខ្ញុំសូមដកស្រង់ឯកសារនេះ "សូមចាប់ ប៊ុត វិន <ហើយបញ្ជូន>ទៅនគរបាល តាមរយៈលិខិតនេះសូមចាប់ទៅ"។ លោកសាក្សី នេះគឺជាឯក-សារដែលលោកមិនដែលបានឃើញទេ ហើយបុគ្គលម្នាក់ដែលត្រូវបានគេចាប់ទៅនេះ គឺឈ្មោះ ប៊ុត វិន គាត់ត្រូវបានគេចាប់ខ្លួននៅថ្ងៃទី១៣ ឧសភា ឆ្នាំ១៩៧៧។ តើលោក ប៊ុត វិន នេះជា តាវិន ដែលលោកស្គាល់នោះ ឬក៏ជាបុគ្គលផ្សេងទេ? បុគ្គលពីរនាក់ខុសគ្នាទេ?

**ឆ៖** បាទ ខ្ញុំស្គាល់តែ តាវិន មួយទេ លោកប្រធាន ក្រៅពីនោះ ខ្ញុំអស់ស្គាល់ដែរបាទ។

[១០:១០:១១]

**ស៖** បាទ មុនពេលសម្រាកនេះ <ខ្ញុំគិតថា គឺនិយាយ>នៅក្នុងកង១ លោកធ្វើការនៅកង១ ដដែលនេះ អ៊ីចឹងខ្ញុំសួរថាលោកធ្លាប់បានចូលប្រជុំទិតៀន ស្វ័យទិតៀនដែរឬទេ? បើសិនជាធ្លាប់នោះ តើ <គេនិយាយពីអ្វីឲ្យប្រាកដក្នុងប្រជុំហ្នឹង>?

**ឆ៖** បាទ ខ្ញុំនៅកង១ ខ្ញុំមិនសូវប្រជុំទេ លោកប្រធាន ព្រោះខ្ញុំមើលខាងកុមារ គេអត់សូវដែលហៅខ្ញុំទៅប្រជុំផងបាទ។ ប្រជុំតែកងខាងស្ទូង ដក ភ្ជួររាស់ ហើយនិងកងរែកដីដំបូក និងខាងកាស៊ីន បាទប្រជុំញឹក។

**ស៖** លោកបាននិយាយថា នៅក្នុងចម្លើយ២៩របស់លោកនេះ លោកនិយាយថា លោកថាធ្លាប់ចូលទៅប្រជុំធំៗ គឺមេឃុំជាអ្នកដឹកនាំកិច្ចប្រជុំនេះ។ តើនៅក្នុងពេលប្រជុំធំៗនេះ ក្រោមការដឹកនាំរបស់មេឃុំ លោកនិយាយថា ឈ្មោះគាត់ហ្នឹង ឈ្មោះតា<ខែម>។ តើនៅ -- អ្នក១៧មេសា ត្រូវបានគេកោះហៅចូលរួមប្រជុំនេះទេ?

[១០:១១:៤៧]

**ឆ៖** បាទ អត់ទេលោកប្រធាន ប្រជុំៗទៅតាមសហករណ៍ទេ លោកប្រធាន។ កង៣ ប្រជុំដោយកង៣ គេមានមេប្រធានគេសម្រាប់ប្រជុំ។ កង១ដោយកង១ កង២ប្រជុំដោយកង២។ បាទ អត់មានប្រជុំល្បូកឡំគ្នាទេ លោកប្រធានបាទ។

**ស៖** ក្នុងឱកាសប្រជុំធំៗនេះ ដែលដឹកនាំដោយមេឃុំ តើពេលនោះគេមាននិយាយអំពីខ្មាំង ជាពិសេសហ្នឹង គឺចាប់ពីពេលដែលមានការប្រយុទ្ធគ្នានៅព្រំប្រទល់វៀតណាម តើកាលនោះមានគេ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

និយាយអំពីខ្មាំងយួនទេ?

**ឆ៖** បាទ កាលនោះអត់មាននិយាយទេ លោកប្រធាន គេមិនមានប្រាប់ប្រជាជនថាអ៊ីចេះ អ៊ីចុះ អីទេបាទ គេលាក់ដែរហ្នឹង។ ប៉ុន្តែប្រជាជនខ្លះ គាត់ឮដែរ ប៉ុន្តែគាត់អត់ហ៊ាននិយាយ និយាយទៅ វាមានគេយកទៅសម្លាប់អ៊ីចឹង ព្រោះគាត់អត់ហ៊ាននិយាយអ៊ីចឹង។ ហើយមេកងគេ គេអត់ប្រាប់ទេ អត់មានអ្នកណាហ៊ានប្រាប់ទេ ប្រជុំតែរឿងការងារ មហាលោតផ្លោះ មហាអស្ចារ្យ ដីដំបូក រែកដីដាក់ស្រែស្ទូងលឿន ភ្ជួរលឿនអីតែប៉ុណ្ណឹងលោកប្រធាន។ ប្រជុំប្រាប់ថា មានវៀតណាមចូល គេអត់ប្រាប់យើងទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសហព្រះរាជអាជ្ញារងអន្តរជាតិ។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមនៅកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនិតីវិធីសវនាការ និងប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**ស៖** ក្នុងរយៈពេលដែលសេសសល់នេះ ខ្ញុំនឹងសួរសំណួរមួយចំនួនបន្ថែមទៀត ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនៅឃុំរបស់លោក ការរៀបអាពាហ៍ពិពាហ៍បដិវត្តន៍ ការប្រព្រឹត្តចំពោះពុទ្ធសាសនិក ក៏ដូចជា<ការប្រព្រឹត្តចំពោះ>អ្នកដែលមកពីកម្ពុជាក្រោម។ មុននឹងចូលដល់ចំណុចនេះ ខ្ញុំចង់បញ្ចប់ជាមួយលោកពាក់ព័ន្ធទៅនឹងលក្ខខណ្ឌការងារ <និងការរស់នៅ>ក្នុងឃុំសំរោង ហើយខ្ញុំសូមអានសម្រង់<មួយ>នៃកំណត់ហេតុរបស់លោក គឺ<E3/5515> នៅចម្លើយទី១៣ លោកបាននិយាយថា៖ “ចំណែកមេកង៣ ខ្ញុំចាំឈ្មោះ ញ៉ ែតម្នាក់ទេ ឈ្មោះ ញ៉ គាត់ស្លាប់”។ នៅចម្លើយទី១៤ លោកឆ្លើយថា “គេ<ចាត់តាំង>មនុស្សពីកង១ ឬកង២ ទៅក្តោបក្តាប់ប្រជាជននៅក្នុងកង៣។ ខ្ញុំដឹងថា តាញ៉ ត្រូវបានគេចាត់តាំងឲ្យក្តោបក្តាប់កង៣ ពីព្រោះគាត់ម៉ឺងម៉ាត់ក្នុងការងារ”។ សូមបញ្ចប់ការដកស្រង់។ តើលោកដឹងយ៉ាងម៉េចបាន ថាតាញ៉ ត្រូវបានចាត់តាំងឲ្យធ្វើជាមេសហករណ៍<ដែលអ្នក១៧មេសា ធ្វើការហ្នឹង ហើយជាពិសេសនោះគឺ>ដោយសារតែគាត់ម៉ឺងម៉ាត់ក្នុងការងារនោះ លោកដឹងចំណុចនេះដោយរបៀបណា? អ្នកណាជាអ្នកនិយាយប្រាប់លោក?

[១០:៣៥:៥៣]

**លោក ភ្នៅ យ៉ាវ៖**

**ឆ៖** បាទ ដែលខ្ញុំបានដឹងថា តាញ៉ គាត់ជាការងារម៉ឺងម៉ាត់ ព្រោះកាលនៅកង១ គាត់ម៉ឺងម៉ាត់ដែរក្នុងការងារ ធ្វើអីក៏គាត់តឹងដែរ បាទ។ បាទខ្ញុំបាទដឹងតែប៉ុណ្ណឹងទេ។

**ស៖** នៅពេលនុ៎ងប្រហែលជាច្បាស់លាស់ណាស់ ក៏ប៉ុន្តែលោកដឹងទេ ថាហេតុអីបានជាប្រធានសហករណ៍អត់មានអ្នកថ្មី? អត់មានអ្នក១៧មេសា ធ្វើជាប្រធានសហករណ៍?

**ឆ៖** បាទ ប្រធានសហករណ៍១៧មេសា គេអត់ឲ្យធ្វើលោកប្រធាន ព្រោះថាគេទើបតែជម្លៀសមកអ៊ីចឹង គេម៉េចឲ្យធ្វើប្រធាន គេយកពួកមូលដ្ឋានធ្វើប្រធានវិញ បាទ។

**ស៖** សូមអរគុណ។ នៅក្នុងកំណត់ហេតុដដែល គឺនៅចម្លើយ២៣ លោកបាននិយាយថា៖ “នៅក្នុងកងកុមារ គឺកង១ មិនមានការចាប់ខ្លួនទេ ក៏ប៉ុន្តែពួកគេបានលួច ដូចជាលួចបាយ លួចអំបិល លួចបេះដូង លួចទឹកត្នោត តែគេអនុគ្រោះឲ្យដោយកុមារទាំងនោះ ជាកូនរបស់ប្រជាជនមូលដ្ឋាន”។ សូមបញ្ចប់ការដកស្រង់។ តើលោកធ្លាប់ដឹងទេថាមានរឿងអ្វីកើតឡើងដែរ ចំពោះកូនអ្នក១៧មេសា ប្រសិនបើពួកគេលួចចំណីអាហារនោះ?

**ឆ៖** បាទ កូន១៧មេសានោះ បើសិនជាលួចវិញ គេអត់ធ្វើអីទេ ក្មេង ប៉ុន្តែគ្រាន់ថាយកមក

ណែនាំមួយថ្ងៃ ពីរថ្ងៃអីអ៊ីចឹង លែងឲ្យវាលួច វារាងវាខ្លាចវាដែរ លោកប្រធាន បាទ។ វាអត់ហ៊ានលួចដែរហ្នឹង គេសម្លុតវា បាទ។

[១០:៣៨:១៩]

**ស៖** លោកដឹងរឿងហ្នឹងដោយរបៀបណាដែរ? អ្នកណាជាអ្នកប្រាប់លោក?

**ឆ៖** បាទ ខ្ញុំដឹងដោយខ្ញុំឃើញ ដែលក្មេងវាលួចបេះដូងបេះអី នៅកងកុមារខាងកង៣ហ្នឹង ហើយមេកងគេ ហៅវាមក យកមកប្រាប់ថា "អូនអ្អែងលែងលួចលែងអីទៅ ប្រយ័ត្នគេយកទៅវៃចោលអ៊ីចឹង" លោកប្រធាន បាទ។ ហើយវាឈប់លួចទៅ បាទ។

**ស៖** សូមអរគុណ។ ចុះចំពោះរចនាសម្ព័ន្ធឃុំនិងសហករណ៍របស់លោក ហើយនិងថ្នាក់លើវិញនោះ។ លោកបាននិយាយឈ្មោះមួយចំនួន ជាឈ្មោះប្រធានសហករណ៍ ហើយនៅចម្លើយទី១៣ គឺនៅក្នុងឯកសារ E3/5515 ដដែល។ លោកនិយាយថា៖ "មេកងទាំងបីនោះ ត្រូវបានតែង<តាំង> និងទទួលបញ្ជាពីមេឃុំឈ្មោះ តាខែម។ ចំណែកឯគណៈឃុំ ទទួលបញ្ជាពីគណៈស្រុក ឈ្មោះ តាជឹម (ស្លាប់)។ ខ្ញុំមិនចាំឈ្មោះគណៈតំបន់ទេ ប៉ុន្តែគណៈភូមិភាគឈ្មោះ តាម៉ុក។ ស្រុកត្រាំកក់ <ក្លាយ>ជាស្រុក១០៥ ដែលស្ថិតនៅក្នុងតំបន់១៣"។ សូមបញ្ចប់ការដកស្រង់។ លោកអាចប្រាប់បានទេ ថាតើតាខែម នេះ គាត់នៅជាគណៈឃុំរហូតទាល់វៀតណាមវ៉ៃចូល ឬក៏យ៉ាងណា?

**ឆ៖** បាទ គាត់នៅគណៈឃុំរហូតដល់វៀតណាមវ៉ៃចូល ពេលវៀតណាមវ៉ៃមកគាត់រត់ទៅភ្នំ។ ដល់ពេលគាត់ចេញពីភ្នំមកវិញ គេៗសម្លាប់គាត់ហ្នឹងលោកប្រធានបាទ។

**ស៖** នៅចន្លោះពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ តើលោកដឹងទេថា តាខែម រាយការណ៍ទៅថ្នាក់លើ<ដែរឬទេ?> ហើយប្រសិនបើដឹងនោះ ថាតើរបាយការណ៍ហ្នឹងគេបញ្ជូនទៅថ្នាក់លើតាមរបៀបណា? គេបញ្ជូនទៅថ្នាក់ស្រុកនេះ ខ្ញុំចង់សំដៅទៅដល់ថ្នាក់ស្រុក។

**ឆ៖** បាទ របាយការណ៍បញ្ជូនទៅតាមនីរសារ បាទ ប្រើជាសំបុត្រជាអីឲ្យនីរសារយកទៅអ៊ីចឹងទៅដល់ថ្នាក់ស្រុក បាទ រត់សំបុត្រហ្នឹងលោកប្រធាន បាទ។

[១០:៤១:៣០]

**ស៖** តើលោកដឹងរបៀបណាថាមាននីរសារបញ្ជូនសំបុត្រទៅហ្នឹង? លោកស្គាល់នីរសារហ្នឹងទេ? ហើយចុះលោកផ្ទាល់នោះលោកមានតួនាទីអ្វីទេនៅក្នុងការបញ្ជូនសំបុត្រទៅថ្នាក់ស្រុកហ្នឹង?

**ឆ៖** បាទ នីរសារ ខ្ញុំអត់បានស្គាល់គេដែរ លោកប្រធាន ភ្លេចអស់ហើយយូរហើយលោក

ប្រធាន បាទ។

**ស៖** លោកនិយាយឈ្មោះ តាជឹម ជាគណៈស្រុក។ តើលោកស្គាល់គណៈស្រុកផ្សេងទៀតទេ នៅថ្នាក់ស្រុកត្រាំកក់ <គឺស្រុក១០៥>ហ្នឹង នៅចន្លោះឆ្នាំ៧៥ ដល់ ឆ្នាំ៧៩ ហ្នឹង ឬក៏លោកស្គាល់តែ តាជឹមម្នាក់ហ្នឹងទេ?<>

**ឆ៖** បាទ ខ្ញុំបាទអត់ស្គាល់ទេលោកប្រធាន ខ្ញុំស្គាល់តែលោក តាជឹម មួយដោយសារគាត់ធ្លាប់អញ្ជើញមកនៅខាងសំរោងបាទ ហើយសួរគាត់ៗធ្វើគណៈស្រុកត្រាំកក់បាទ ស្គាល់តែប៉ុណ្ណឹងបាទលោកប្រធាន។

**ស៖** អ៊ីចឹងមានន័យថា តាជឹម ហ្នឹងគាត់មកមើល<សហករណ៍> ឬក៏កងរបស់លោកក្នុងអំឡុងពេលគាត់ជាគណៈស្រុក។ អ៊ីចឹងមែនទេ គាត់ចុះមកមើលកងរបស់លោក?

**ឆ៖** បាទ គាត់អញ្ជើញមកញឹកដែរហ្នឹង។ គាត់ដើរមើលនៅតាមឃុំនានា ធ្វើស្រែធ្វើអី បានផលស្រូវអីចេះៗ គាត់ដើរបង្គាប់មេឃុំអីចឹងដែរ លោកប្រធានបាទ។

[១០:៤៣:៣៧]

**ស៖** តើតាជឹម ហ្នឹងធ្លាប់អម តាម៉ុក ទេ ឬក៏គាត់ធ្លាប់អមអ្នកណាផ្សេងទៀតទេ ឧទាហរណ៍ ដូចជា<>មេតំបន់១៣ ឬក៏អមជនបរទេសអីណាចុះមកមើលទេ?

**ឆ៖** បាទ អត់សូវមានជនបរទេសអញ្ជើញមកទេ លោកប្រធាន មានតែខ្មែរ នៅម្តុំហ្នឹងមានតែ -- បើសិនណាលោក តាជឹម មកគណៈស្រុកអញ្ជើញមក គាត់មាននីរសារគាត់មួយមកបាទ ពីរនាក់ នីរសារគាត់ហ្នឹងចូលមកឃុំសំរោងបាទ។

**ស៖** ដូច្នេះលោកមិនធ្លាប់ឃើញ តាម៉ុក មកកងឬក៏ឃុំរបស់លោកទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដែលស្គាល់គាត់ដែរហ្នឹងលោកប្រធាន ឮតែឈ្មោះដែរហ្នឹងបាទ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅសំណួរពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍បង្ខំ។ ដើម្បីឲ្យទៅលឿននោះ ខ្ញុំសូមអានចម្លើយរបស់លោកដែលលោកឆ្លើយទៅកាន់សហចៅក្រមស៊ើបអង្កេត នៅពេលនេះគេសួរព័ត៌មានលម្អិតលោក ហើយលោកក៏បានឆ្លើយនៅក្នុងឯកសារ E3/5515 ចម្លើយទី៣២។ សំណួរ៖ "ក្នុងជំនាន់ ប៉ុល ពត តើមានការរៀបការដែរឬទេ?" លោកឆ្លើយនៅពេលនោះ នៅក្នុងចម្លើយទី៣២ថា៖ "ខ្ញុំធ្លាប់បានចូលរួម<ពិធីរៀបការ> នៅអង្គពណ្ណរាយ។ ខ្ញុំបានឃើញការរៀបការដែលមាន ២០គូ មានគូខ្លះបានស្គាល់គ្នាមុន ប៉ុន្តែមានគូរខ្លះក៏មិនស្គាល់គ្នាដែរ។ បន្ទាប់ពីរៀបការរួចឈ្លបបានទៅ

លបចាំស្ដាប់នៅតាមផ្ទះនៅពេលយប់ ក្នុងគោលបំណងដើម្បីឲ្យដឹងថាពួកគេចុះសម្រុងនឹងគ្នាដែរឬក៏អត់។ កាលសម័យនោះ គ្មានគូណាប៉ានមិនចុះសម្រុងគ្នាទេ ព្រោះខ្លាចងាប់។ បើមានគូណាមិនចុះសម្រុងគ្នា ឈ្លបដឹងរាយការណ៍ទៅថ្នាក់លើ ហើយព្រឹកឡើង គេនឹងហៅទៅណែនាំដោយគំរាមថានឹងយកទៅទីណាៗ ដូចជា យកទៅដាក់ក្រាំងតាចាន់ជាដើម។ ពេលនោះគេមិនប្រើពាក្យថា“រៀបការ”ទេ។ គេហៅថា “ឡើងប្ដេជ្ញា”។ បើមានគូណាដែលស្រឡាញ់គ្នា មិនថាជាមេម៉ាយ កម្លោះ ក្រមុំចាស់ ក្មេង បើគេពេញចិត្ត គេអាចស្នើទៅលើបាន ហើយពេលនោះ មេកងហៅទៅសួរ បើពេញចិត្ត គេរៀបការឲ្យ។ ការរៀបការច្រើនធ្វើនៅពេលយប់ ដោយមានការចូលរួមពីគណៈឃុំ ប្រធានសហករណ៍ និងប្រធានកង”។ សូមបញ្ចប់ការដកស្រង់។

ដំបូងឡើយ លោកនិយាយថា លោកបានចូលរួមក្នុងការៀបការនៅអង្គពណ្ណរាយ ហើយលោកក៏បានប្រាប់ផងដែរថា អង្គពណ្ណរាយហ្នឹងហើយដែលជាទីតាំងស្ថិតនៅរបស់សហករណ៍កង១។ អ៊ីចឹងមានន័យថា លោកធ្លាប់ចូលរួម<តែ>ការរៀបការនៅក្នុងកង១<ប៉ុណ្ណោះ>?

[១០:៤៧:៣៨]

**ឆ៖** បាទ ខ្ញុំបានចូលរួមដែរ លោកប្រធាន គ្រាន់តែទៅមើលគេរៀបហ្នឹងប្រធានបាទ។ ខ្ញុំអត់មាននាទីអីថា ទៅឲ្យគេរៀបទេ ប៉ុន្តែគ្រាន់តែទៅមើលគេ គេរៀបម៉េចវិញ លោកប្រធានបាទ។

**ស៖** អ៊ីចឹងការរៀបការហ្នឹង គឺការតែនៅក្នុងៗតែកង១អ៊ីចឹងមែនទេ គឺថានៅក្នុងកង២ កង៣ អត់មានរៀបការទេ។ ការរៀបការហ្នឹងអាចធ្វើបានតែអ្នកនៅក្នុងកង១ទេ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ រៀបការបានទាំងអស់លោកប្រធាន តែមករៀបការនៅអង្គពណ្ណរាយទាំងអស់ហ្នឹង នៅកន្លែងសាលាឃុំ។ បាទ កន្លែងហ្នឹងតែមួយទេ លោកប្រធាន។ បើកង៣ ចង់រៀបការក៏រៀបទៅ ប៉ុន្តែមករៀបកន្លែងហ្នឹងដដែលហ្នឹងប្រធានបាទ។

**ស៖** តើអ្នកនៅក្នុងកង១នុ៎ង អាចរៀបការជាមួយអ្នកដែលនៅក្នុងកង២, កង៣ បានទេ?

**ឆ៖** បាទ រៀបការជាមួយកង២ បានលោកប្រធាន។ កង៣ គេអត់ឲ្យយកទេ លោកប្រធាន។ មានការពាក់ព័ន្ធហ្នឹង គេអត់ឲ្យរៀបការ។

**ស៖** លោកឆ្លើយថា ការរៀបការហ្នឹងច្រើនតែធ្វើឡើងនៅពេល<ល្ងាច>។ លោកនិយាយថា៖ “គេច្រើនធ្វើនៅពេល<ល្ងាច>” អ៊ីចឹងមានន័យថា មានការរៀបការច្រើនហើយ បើលោកឆ្លើយបែបនេះនោះ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកបានចូលរួមការរៀបការហ្នឹងប្រហែលប៉ុន្មានដែរ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំបានចូលរួមពីរដងដែរ លោកប្រធាន ម្ដង១០គូ ម្ដងនោះ២០គូ បាទ ក្នុងមួយយប់ ប៉ុន្តែឡើងប្ដេជ្ញា មិនមែនរៀបការទេ។ គ្រាន់តែថា បើឪបមាថាតាគាត់ស្រឡាញ់យាយ គាត់ឡើងទៅ គាត់គ្រាន់តែថា៖ "ខ្ញុំសូមប្ដេជ្ញាស្រឡាញ់យាយអស់មួយជីវិត"។ ហើយយាយគាត់ឡើងដែរថា "សូមប្ដេជ្ញាស្រឡាញ់តាអស់មួយជីវិត"។ តែប៉ុណ្ណឹងលោកប្រធាន បាទ។

**ស៖** លោកនិយាយអំពីការចូលរួមរបស់<មេ>ឃុំ <មេសហករណ៍ និង>មេកង។ អ៊ីចឹងចំពោះការរៀបការដែលលោកបានចូលរួមទៅមើលហ្នឹង តើមេឃុំហ្នឹង តាខែម ហ្នឹងគាត់ជាអ្នករៀបចំ ហើយជាអ្នកដឹកនាំពិធីរៀបការហ្នឹងមែនទេ?

[១០:៥០:៤៣]

**ឆ៖** បាទ មេឃុំតាខែម គេអញ្ជើញមកដែរលោកប្រធាន មកឲ្យខាងគណៈកងជួយរៀបចំរើសគូៗហ្នឹងឲ្យហើយ ហើយចូលម្ដងមួយគូៗអ៊ីចឹងទៅ។ ប្ដេជ្ញាហើយចុះចេញពីហ្នឹងទៅ ទៅផ្ទះសព្វខ្លួន លោកប្រធានបាទ។

**ស៖** ក្នុងពេលរៀបការហ្នឹងគេឲ្យប្ដេជ្ញា អ៊ីចឹងពេលហ្នឹង តើតាខែម គាត់មានបាននិយាយអីទេនៅពេលឲ្យប្ដេជ្ញាហ្នឹង? ចំពោះ ទោះថាអ្នកហ្នឹងស្គាល់គ្នាមិនស្គាល់គ្នាក៏ដោយហ្នឹង តើនៅពេលឡើងប្ដេជ្ញាហ្នឹង តាខែម គាត់មាននិយាយអ្វីទេ?

**ឆ៖** បាទ គាត់និយាយពីរបីម៉ាត់ដែរលោកប្រធាន គាត់ថាការប្ដេជ្ញានេះមិនអាចលែងគ្នាបានអីចេះចុះអ៊ីចឹង គាត់ណែនាំអ៊ីចឹងដែរលោកប្រធាន។ គាត់ថាពីរបីម៉ាត់ហ្នឹងហើយ ឲ្យមេកងជួយប្ដេជ្ញាហៅពីរនាក់ហ្នឹងឡើងមកម្ដងមួយគូៗ ទាំង២០គូអ៊ីចឹង ចប់ហើយ ទៅផ្ទះសព្វខ្លួន លោកប្រធានបាទ។

**ស៖** តើតាខែម គាត់មាននិយាយអំពីបញ្ជា ឬក៏សេចក្ដីណែនាំរបស់ថ្នាក់លើនៅពេលដែលគាត់និយាយទៅកាន់អ្នកដែលត្រូវរៀបការហ្នឹង គាត់មានបានលើកឡើងថាអង្គការណែនាំមកយ៉ាងម៉េចខ្លះអីទេ?

**ឆ៖** អង្គការមានណែនាំអីក្រៅពីការណែនាំឲ្យស្រឡាញ់គ្នា ឲ្យការហើយហ្នឹង បានជួបគ្នាល្ងាចហ្នឹងទេ ដល់ល្ងាចស្អែកទៅ ទៅតាមកងសព្វខ្លួនវិញ ហើយថ្ងៃ១០ ត្រូវមកជួបគ្នាវិញទៀត។ នៅ១០ថ្ងៃទៅមុខទៀត បាទ អ៊ីចឹង។ គាត់និយាយតែប៉ុណ្ណឹង។

**ស៖** លោកឆ្លើយថា អ្នកខ្លះស្គាល់គ្នាពីមុន អ្នកខ្លះមិនស្គាល់គ្នា។ អ៊ីចឹង នៅពេលរៀបការនោះគិតយ៉ាងម៉េចទៅចំពោះអ្នកអត់ស្គាល់គ្នានោះ? គេមានអានឈ្មោះ គេមានចុះជាលេខទេ? ដើម្បីឲ្យដឹង

ថា អ៊ូ! អ្នកនេះត្រូវរៀបការជាមួយអ្នកនេះ អ៊ីចឹងនោះ ចំពោះអ្នកមិនស្គាល់គ្នានោះ?

[១០:៥៣:៣០]

**ឆ៖** បាទ គឺប្រាប់ឈ្មោះដែរលោកប្រធាន ប្រាប់ថា នាងនេះត្រូវគូជាមួយបុរសនេះអ៊ីចឹងទៅ។ បាទ អត់ស្គាល់គ្នា គេណែនាំឲ្យស្គាល់ដែរបាទ។

**ស៖** តើអ្នកដែលមិនស្គាល់គ្នា ហើយដែលត្រូវរៀបការជាមួយគ្នាហ្នឹង។ គាត់មានសិទ្ធិជ្រើសរើសទេ ថានៅពេលគេចាប់ថាឲ្យរៀបការជាមួយអ្នកនេះ អ្នកនោះអ៊ីចឹង គាត់ថា អ៊ូ! អត់ទេ ខ្ញុំអត់ព្រមរៀបការជាមួយគាត់ទេ។ តើមានអ៊ីចឹងទេ?

**ឆ៖** បាទ មានអ៊ីចឹងដែរ លោកប្រធាន មានគេអត់ត្រូវ គេអត់យក ក៏គេអត់ថាអីដែរលោកប្រធាន បាទ។ តាមចិត្តគេស្រឡាញ់អ៊ីចឹងដែរ បាទ បើថា ឲ្យអ៊ី "ក" អ៊ីចឹងថា ទេខ្ញុំមិនយកទេ អ៊ី "ក"។ ខ្ញុំស្រឡាញ់អ៊ី "ខ" អាហ្នឹងគេរៀបឲ្យអ៊ី "ខ" ហ្នឹងបាទ។ អត់ថាអីដែរហ្នឹងបាទ។

**ស៖** លោកឆ្លើយថា "ក្រោយពីរៀបការហ្នឹង មានឈ្លបលបស្ដាប់នៅក្រោមផ្ទះនៅពេលយប់ដើម្បីឲ្យដឹងថាតើពួកគាត់ហ្នឹងចុះសម្រុងគ្នាដែរឬក៏អត់"។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើលោកដឹងដោយរបៀបណា ថាមានឈ្លបមកលបចាំស្ដាប់នៅក្រោមផ្ទះហ្នឹង ថាអ្នករៀបការហើយហ្នឹង ចុះសម្រុងគ្នា ឬក៏មិនចុះសម្រុងគ្នានោះ?

**ឆ៖** បាទ កាលណាការហើយ ប្រធានកងគេណែនាំ ថាឲ្យឈ្លបទៅស្ដាប់តាមផ្ទះហ្នឹង បាទ។ ខ្ញុំដឹងដោយវិធីគេប្រាប់ដែរ គេប្រាប់ ខ្ញុំឮ។ បាទ ហើយគេចាត់ឈ្លបពីរនាក់អ៊ីចឹងទៅ មួយផ្ទះអ៊ីចឹង ដើរស្ដាប់អ៊ីចឹងទៅ បាទ។

[១០:៥៥:៥៤]

**ស៖** ឈ្លបដែលទៅលបហ្នឹង មានអាយុប៉ុន្មានដែរ ជាក្មេងៗ ឬក៏ជាមនុស្សធំហើយ? <តើពួកគេឈ្លបនៅក្នុងសហករណ៍ ឬក៏ឃុំរបស់លោក?>

**ឆ៖** ឈ្លបទៅលបស្ដាប់ហ្នឹង លោកប្រធាន អាយុខ្ទង់២០ជាង ៣០អីហ្នឹង ឲ្យធ្វើឈ្លប មានប្រពន្ធ ខ្លះវាអត់ប្រពន្ធអ៊ីចឹងដែរ យុវជនខ្លះមានប្រពន្ធខ្លះជាកសិករខ្លះ ប៉ុន្តែធ្វើឈ្លបឃុំនៅប្រចាំឃុំសំរោងហ្នឹងដែរ បាទ។

**ស៖** លោកបានឆ្លើយថា ឈ្លបទៅលបស្ដាប់ហ្នឹង ដើម្បីឲ្យដឹងថាពួកគេចុះសម្រុងគ្នា ឬក៏មិនចុះសម្រុងគ្នា។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើពាក្យថា "ចុះសម្រុង ឬមិនចុះសម្រុងនោះ" មានន័យថាម៉េច?

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

មានន័យថា ពួករួមដំណេកគ្នាឬក៏យ៉ាងម៉េច ឬមានន័យអ្វីផ្សេងពីនេះ?

**ឆ៖** បាទ គេចង់ដឹងរឿងរួមដំណេកហ្នឹង លោកប្រធាន។ បាទ បើអត់ចុះសម្រុងគ្នាអ៊ីចឹង ស្អែកឡើងគេហៅមកទាំងពីរនាក់ហ្នឹង ណែនាំ ប្រាប់អ៊ីចេះ ប្រាប់អ៊ីចុះ ថាអ្វី! វាមិនបានដែរ លោកប្រធាន។ ចុះសម្រុងគ្នាវិញទៅ អត់អី បាទ។ ប្រសិនបើយើងមិនចុះ អាហ្នឹងគេណែនាំ បើយើងចុះហើយ អត់អីទេ មានអ្នកណាណែនាំអី បែកគ្នាទៅធ្វើការងារតាមកងរៀងខ្លួនវិញ បាទ។

**ស៖** លោកថា អ្នកដែលមិនចុះសម្រុងគ្នា ឬក៏មិនចុះដំណេកគ្នាហ្នឹង ត្រូវបានគេកោះហៅយកទៅ<អប់រំកសាង> ហើយជួនកាលទៅ គេគំរាមថាយកទៅកន្លែងណាមួយ ដូចជាយកទៅ<មន្ទីរសន្តិសុខ>ក្រាំងតាចាន់ជាដើម។ ហើយលោកអម្បាញ់មិញនេះ លោកក៏ឆ្លើយថា "មានអ្នកខ្លះប្រកែកអត់ព្រមរៀបការ តែអត់មានរឿង អ្វីកើតឡើងទេ"។ អ៊ីចឹងដូចជាមើលទៅដូចវាផ្ទុយគ្នាចម្លើយរបស់លោកនេះ។ យើងមើល -- លោក ឆ្លើយហើយថា អ្នកដែលមិនព្រមចុះសម្រុងហ្នឹង គេហៅយកទៅ<អប់រំកសាង> ហើយគំរាមយកទៅក្រាំងតាចាន់ ហើយមួយទៀត លោកឆ្លើយថាមានអ្នកប្រកែកមិនព្រមរៀបការ ហើយគេអត់មានធ្វើអ្វីចំពោះអ្នកប្រកែកហ្នឹងទេ។ អ៊ីចឹងលោកអាចឆ្លើយលម្អិតបានទេថា ចំពោះអ្នកដែលប្រកែកមិនព្រមរៀបការនោះ គេធ្វើអ្វីដែរ?

[១០:៥៨:៥៣]

**ឆ៖** បាទ អ្នកដែលប្រកែកមិនព្រមរៀបការ ព្រោះគេអត់ស្រឡាញ់បុរសហ្នឹង បានគេអត់ព្រម លោកប្រធាន ហើយគេចាំយកបុរសមួយទៀតទៅ គេរៀបចំថ្ងៃក្រោយទៀត បាទ។

**ស៖** អ៊ីចឹង វាមើលទៅដូចជាមិនសូវសម<នឹងអង្គហេតុនេះសោះ ដែលថា>អ្នកដែលមិនចុះសម្រុង <គឺត្រូវ>គេគំរាម<កំហែង>។ អ៊ីចឹងមើលទៅដូចជាមិនសូវជាទំនងយ៉ាងម៉េច។ បើអ៊ីចឹង បើសិនជា<គូស្រករទាំងអស់នេះ>ស្រឡាញ់<ទៅវិញទៅមក ហើយយល់ព្រមរៀបការនោះ ច្បាស់ណាស់ពួកគេចុះសម្រុងហ្នឹងគ្នាហើយ។ ដូច្នេះយោងតាមអ្វីដែលលោកបានដឹងនោះ ហេតុអ្វីបានជា> ពួកគេហ្នឹងមិនចុះសម្រុងនឹងគ្នា?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមជំទាស់នឹងសំណួរតំណាងសហព្រះរាជអាជ្ញាអន្តរ-

ជាតិ។ ការពិតទៅ សាក្សីបានឆ្លើយច្បាស់ហើយទៅលើសំណួរតំណាងសហព្រះរាជអាជ្ញា ទាក់ទងទៅនឹងការសម្រេចចិត្តរបស់អ្នកណាម្នាក់ថាមិនទទួលយកបុគ្គលណាម្នាក់ជាភរិយា ឬស្វាមីក្នុងរបបនោះ។ ក៏ប៉ុន្តែចម្លើយរបស់សាក្សី ប្រហែលជាមិនត្រូវចិត្តនឹងតំណាងសហព្រះរាជអាជ្ញាហើយលោកព្យាយាមបញ្ចេញនូវទស្សនៈរបស់ខ្លួនដើម្បីធ្វើការប្រៀបធៀបថា វាសម ឬមិនសមទៅនឹងចម្លើយរបស់សាក្សី។ ការធ្វើបែបនេះ វាមិនមានភាពត្រឹមត្រូវទទួលយកបានដែលអាចឲ្យសាក្សីធ្វើការឆ្លើយតបទៅនឹងទស្សនៈរបស់តំណាងសហព្រះរាជអាជ្ញានោះទេ។ បើអ៊ីចឹងខ្ញុំបាទ សូមជំទាស់ចំពោះចំណុចនេះបាទ។

[១១:០០:៥៩]

**លោក វ៉ាងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំព្យាយាមដោះស្រាយបញ្ហាផ្ទុយគ្នានូវចម្លើយរបស់សាក្សី ពីព្រោះថា សាក្សីគាត់បាននិយាយថា <>មានអ្នកមិនស្គាល់គ្នា<មុន ពេលដែលរៀបការហ្នឹង>។ អ៊ីចឹងយើងអាចសន្និដ្ឋានបានថា អ្នកដែលមិនស្គាល់គ្នាហ្នឹងគាត់អត់ស្រលាញ់គ្នាទេ។ ហើយបន្ទាប់មក គាត់និយាយថា <មិនមានគូស្រករណាដែលមិនយល់ព្រម ឬប្រកែកមិនរួមដំណេកជាមួយគ្នានោះទេ ពីព្រោះពួកគេភ័យខ្លាចស្លាប់ ឬក៏>គំរាមថា<បញ្ជូន>ទៅក្រាំងតាចាន់<>។ ហើយគាត់ក៏បានឆ្លើយទៀតថា អ្នកខ្លះនោះប្រកែក គេឲ្យរើសអ្នកផ្សេង គេមិនបង្ខំទេ។ អ៊ីចឹងខ្ញុំព្យាយាមដោះស្រាយបញ្ហាចម្រូងចម្រាស់គ្នានូវចម្លើយរបស់សាក្សីទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

គប្បីយើងចៀសវាងនូវការបកស្រាយរបស់លោក វាអាចឈានដល់ការណែនាំសាក្សីឲ្យឆ្លើយតាមបំណងរបស់លោក។ លោកអាចរៀបចំសំណួរសាថ្មី ហើយសំណួរគឺឲ្យបានច្បាស់លាស់ ធ្វើយ៉ាងណាឲ្យវាមានអាចដោះស្រាយបញ្ហាហ្នឹងបាន។ ចៀសវាងធ្វើការវាយសរុបវិភាគលើបញ្ហានេះហើយ ធ្វើការ -- មានន័យថាធ្វើការសន្និដ្ឋានលើអ្វីដែលសាក្សីឆ្លើយរួច នោះគឺជាកំហុសនៃបច្ចេកទេសក្នុងការសួរដេញដោលហើយ។

**សួរដោយលោក វ៉ាងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី លោកថា អ្នករៀបការហ្នឹងមិនហ៊ាន<ប្រកែកនឹងការចាប់គូហ្នឹងនោះទេដោយសារ>ពួកគេខ្លាចស្លាប់<។ ហេតុអ្វីបានជាពួកគេភ័យខ្លាចសម្លាប់> ប្រសិនបើពួកគាត់<ប្រកែក>មិន<រួមដំណេកជាមួយ>គ្នា? តើលោកមានបាននិយាយទៅកាន់អ្នករៀបការថ្មីហ្នឹងទេ ដើម្បីដឹងពី

បញ្ហាហ្នឹង ឬ<ក៏បាននិយាយពិភាក្សាអំពីបញ្ហាហ្នឹងដែរ ឬទេ>?

**លោក ភ្នៅ យ៉ាវ៖**

**ផ៖** បាទ លោកប្រធាន ខ្ញុំដែលឮគេណែនាំអីចឹងដែរ ប៉ុនថា រឿងថាមិនចុះសម្រុង មិនហ៊ានទេ ព្រោះថា ដែលឈ្លបវាទៅយាមនេះ ខ្លាចក្រែង លោកប្រធាន បាទ ខ្លាចក្រែងមិនចុះទេ។ ថាវាមិនអី ប៉ុន គ្រាន់ថាគេយាមទៅ ខ្លាចក្រែងមិនចុះសម្រុងគ្នានៅថ្ងៃក្រោយទៀតអីចឹងទៅ គេលបមើលអីចឹងណា លោកប្រធាន បាទ។

**ស៖** ខ្ញុំចូលទៅប្រធានបទផ្សេងទៀត។ ខ្ញុំចង់និយាយអំពីព្រះពុទ្ធសាសនាម្តង។ មុនពេលរបប ខ្មែរក្រហមនោះ<> តើមានវត្តអារាមច្រើនទេ នៅក្នុងឃុំសំរោងនោះ?

**ផ៖** បាទ សូមឆ្លើយប្រាប់លោកប្រធានថា កាលនោះវត្តមាន -- កន្លែងខ្ញុំមានវត្តទឹកជុំ អង្គ ពណ្ណរាយ។ វត្តតែពីរវត្តទេ លោកប្រធាន បាទ។

[១១:០៤:៣៧]

**ស៖** នៅចន្លោះថ្ងៃទី១៧ ខែមេសា ៧៥ រហូតដល់<ខែមករា> ឆ្នាំ៧៩ តើគេយកវត្តអារាមទាំង អស់ហ្នឹងទៅធ្វើអ្វីដែរ?

**ផ៖** បាទ នៅឆ្នាំ១៩៧៥ វត្តត្រូវឱ្យព្រះសង្ឃលោកសឹកអស់ទៅ ហើយយកអារាមហ្នឹង ជួន កាលគេធ្វើជាកន្លែងដាក់ជី ដាក់អី ហើយកន្លែងប្រជុំអីលើសាលាគេអត់រុះចេញទេ បើជាទឹកជុំ អត់មាន រុះទេលោកប្រធាន ទុកនៅហ្នឹង ពេលគេប្រជុំ គេអី គេឱ្យមូលគ្នានៅហ្នឹងវត្តហ្នឹងទៅ។

**ស៖** ចុះព្រះពុទ្ធរូប អ្នក -- គេធ្វើអ្វីដែរ ខ្មែរក្រហមមានធ្វើអ្វីទេ ចំពោះព្រះពុទ្ធរូបនៅក្នុងព្រះ វិហារហ្នឹង?

**ផ៖** បាទ ព្រះពុទ្ធរូបនៅវត្តទឹកជុំ គឺយកទៅដាក់ក្នុងទឹកស្រះអស់ហើយលោកប្រធាន អត់មាន ទុកនៅក្នុងលើបល្ល័ង្កក្នុងព្រះវិហារទេបាទ។

**ស៖** តើអ្នកមូលដ្ឋាននោះ គាត់មានអារម្មណ៍បែបណានៅពេលដែលឃើញខ្មែរក្រហម ប្រព្រឹត្ត យ៉ាងហ្នឹងចំពោះព្រះសង្ឃ ហើយនិងចំពោះវត្តអារាមទាំងអស់ហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី រ៉ិចទ័រ កូប៉េ!

[១១:០៦:២៦]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំជំទាស់ចំពោះសំណួរនេះ។ សាក្សីឆ្លើយតែអ្វីដែលគាត់បានឃើញដោយផ្ទាល់ គាត់មិនអាចឆ្លើយជំនួសឲ្យប្រជាជននៅតាមមូលដ្ឋានថា<មានអារម្មណ៍បែបណា ដែល> បានឃើញអ្វីកើតឡើងនោះទេ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំសូមសួរឡើងវិញ ចុះលោកខ្លួនឯងផ្ទាល់នេះ លោកមានអារម្មណ៍បែបណាដែរ នៅពេលដែលឃើញព្រះសង្ឃត្រូវបានគេចាប់ផ្សឹក ហើយគេយកវត្តអារាមយកទៅធ្វើជាអ្វីផ្សេង មិនប្រើដូចពីមុនដែលថាជាកន្លែងប្រណិប័តន៍សាសនា ទៅជាប្រើជាកន្លែងផ្សេងនោះ។ តើលោកផ្ទាល់ អារម្មណ៍លោកបែបណានៅពេលដែលប្រឈមមុខចំពោះទិដ្ឋភាពបែបនុ៎ង?

**លោក ភ្នៅ យ៉ាវ៖**

**ឆ៖** បាទ ខ្ញុំនឹកឃើញអារម្មណ៍ថានឹកស្ដាយព្រះពុទ្ធរូប ស្ដាយព្រះសង្ឃដែរ ប៉ុន្តែមិនដឹងធ្វើម៉េចបើប្រទេសវាទៅអ៊ីចឹងហើយ ខ្ញុំអត់ប៉ានិយាយដែរហ្នឹងបាទ លោកប្រធាន អត់មានមាត់កអីដែរ។ គេអត់ប៉ានិយាយគ្រប់គ្នា ខ្ញុំក៏អត់ប៉ាននិយាយដែរ បាទនៅស្ងៀមដូចគ្នា ទៅតាមការណែនាំរបស់គណៈកងគេហ្នឹង អត់ប៉ានមាត់ អត់ប៉ាននិយាយអីដែរបាទ។

[១១:០៧:៤៣]

**ស៖** លោកបានឆ្លើយថា នៅចម្លើយ៣ និងនៅ៣៥ លោកថា<ក្រៅពីអ្នកមូលដ្ឋាន និងអ្នក១៧មេសា>ហ្នឹង អត់មានជនជាតិភាគតិចវៀតណាម ឬក៏ជនជាតិចាមទេ។ អ៊ីចឹងតើនៅចន្លោះពី <ថ្ងៃទី១៧> ខែមេសា ឆ្នាំ៧៥ ទៅដល់<ចុងឆ្នាំ៧៨>ហ្នឹង លោកមានឃើញ ឬក៏ស្ដាប់ឮថាមានខ្មែរមកពីកម្ពុជាក្រោម ដែលគាត់និយាយរដឺនៗមកក្នុងស្រុកត្រាំកក់ហ្នឹង ជាពិសេសគឺក្នុងឃុំសំរោងហ្នឹងទេ លោកមានឃើញអ៊ីចឹងទេ?

**ឆ៖** បាទ អត់មានឃើញទេ ក្នុងឃុំខ្ញុំលោកប្រធាន អត់មានឃើញខ្មែរនិយាយរដឺនៗ កម្ពុជាក្រោមអត់សូវមាន។ អត់សូវទេ អត់មានតែម្ដងលោកប្រធាន មានតែពួកខាងកង១, កង២, កង៣ នៅរស់នៅកន្លែងហ្នឹង។

**ស៖** <ប៉ុន្តែ>លោកបានឆ្លើយថា លោកនៅឆ្ងាយពីកង២, កង៣។ អ៊ីចឹង<តើលោកច្បាស់>ទេ

ថា នៅកងពាហ្នឹង គឺសុទ្ធតែជាអ្នកដែលគេជម្លៀសពីភ្នំពេញ មកពីតាកែវតែម្តង អត់មានអ្នកណាផ្សេងនៅលាយឡំនោះទេ ឬក៏<អាចដែរទេ គឺលោកមិនសូវច្បាស់អំពីបញ្ហានេះ>?

**ឆ៖** បាទ តាមខ្ញុំដឹង គឺថាអត់មានអ្នកលាយទេលោកប្រធាន។ មានតែកងពាហ្នឹងតែម្តង មកពីទៅពីភ្នំពេញទៅ ហើយមានគណៈកងគេមានតែម្នាក់ហ្នឹង។ ប៉ុន្តែថាស្រី ខ្ញុំអត់បានចាំទេលោកប្រធាន ចាំតែប្រុសម្នាក់។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ដោយសារតែពេលវេលាខើចទៅហើយ អ៊ីចឹងខ្ញុំសូមបញ្ចប់តែម្តងទៅលោកប្រធាន។

សូមអរគុណដល់លោកសាក្សី ដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ អង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេ-ណី។

[១១:១០:២១]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** បាទជាដំបូងខ្ញុំសូមគោរពអង្គជំនុំជម្រះទាំងមូល ហើយសូមគោរព ដល់អ្នកទស្សនានៅទីនេះ និងអ្នកដែលបានទស្សនាតាមបណ្តាប្រព័ន្ធផ្សព្វផ្សាយនានា។ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីនៅក្នុងអង្គជំនួយផ្នែកច្បាប់នៃកម្ពុជា ហើយក៏ជាមេធាវីឲ្យតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ។

នៅពេលនេះ ខ្ញុំសូមជម្រាបសួរទៅលោកពូ យ៉ាវ ដែលលោកពូមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ អំពីបរិបទខាងត្រាំកក់ ហើយនិងក្រាំងតាចាន់ បាទ។

សំណួរដំបូងរបស់ខ្ញុំដែលពាក់ព័ន្ធនឹងឯកសាររបស់លោកពូគឺឯកសារ E3/5515 បាទ។ សំណួរទី១ នោះគឺថាតើ លោកពូដឹងថា -- តាមរយៈនរណាថា លោកតា មានលោក តានន ឬមួយលោក តាជាមកពីហាណូយ។ ថាតើគាត់មកពីហាណូយ ដឹងតាមរយៈអ្នកណា?

**លោក ភ្នៅ យ៉ាវ៖**

**ឆ៖** បាទ ខ្ញុំបានដឹងថាលោកតាជាហ្នឹង គាត់មកពីហាណូយ ហើយនិងលោកតានន ហ្នឹង គាត់មកពីហាណូយដោយសារគណៈកងនៅក្នុងស្រុកហ្នឹងគាត់និយាយ ខ្ញុំបាទបានដឹងតែប៉ុណ្ណឹង -- គាត់ថា

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

តាហ្នឹងគាត់នៅហាណូយ គាត់ចេញពីផ្ទះទៅៗនៅហាណូយ តាំងពីឆ្នាំប៉ុន្មានទេភ្លេចបាត់ហើយលោកប្រធានបាទ។

**ស៖** ហើយគាត់ទាំងពីរនាក់ អ្នកនៅស្រុកយើងហ្នឹងជាមួយគ្នាឬមួយយ៉ាងណា?

**ផ៖** បាទ តានន គាត់នៅខាងភូមិចានទាប ឃុំសំរោង ដែរពីដើម ខាងជើងវត្តទឹកជុំ បាទ។ ហើយតាជាហ្នឹងគាត់ ខ្ញុំបាទអត់ដឹងផ្ទះគាត់នៅណាដែរ លោកប្រធាន ស្រាប់តែគាត់ហ្នឹង គេថាគាត់មកពីហាណូយតែម្តងបាទ។

[១១:១៣:០៩]

**ស៖** បាទ អរគុណ។ ចុះខ្ញុំមើលនៅក្នុងចម្លើយហ្នឹងគឺមានពាក់ព័ន្ធនឹងឈ្មោះ តាជា។ ថាតាជាហ្នឹងគាត់បានចាប់បងស្រីជីដូនមួយរបស់លោក លោកពូហ្នឹងពីអង្គតាសោម មក -- ពីអង្គតាសោមមកហ្នឹង ហើយវាយលើគាត់អ៊ីចឹង។ ថាតើៗបងស្រីជីដូនមួយហ្នឹងគាត់នៅអង្គតាសោមគាត់ធ្វើអី មានបញ្ហាអី ដែលវាខុសហ្នឹង បានជាគេចាប់មកទីនេះបាទ?

**ផ៖** បាទ សូមជម្រាបលោកប្រធានថា អ៊ីចេះ កាលនោះដែលគាត់នៅអង្គតាសោមហ្នឹង គាត់ធ្វើគ្រូបង្រៀនទេ ប្តីគាត់។ តែដល់តែពេលទាហានគេចុះមកផ្លូវជាតិលេខ៣ហ្នឹង គាត់មកតាមទាហានដល់មកតាមទាហានទៅ ទាហានគេបាញ់ទាហាន គាត់រត់អត់ទាន់ត្រូវពួកខ្មែរក្រហមចាប់បានតែម្តងទាន បាទ។ សូមឆ្លើយជម្រាបជូនប៉ុណ្ណឹង។

**ស៖** បាទអរគុណបាទ។ ខ្ញុំនឹងឈានចូលទៅចំណុចមួយទៀតថាអំពី ខ្ញុំចង់ដឹងថាតើនៅក្នុងភូមិនីមួយៗដែលលោកពូថានៅក្នុងភូមិហ្នឹងគេចែកចេញជាកងៗ ហើយយើងចង់ដឹងថាតើភូមិនីមួយៗហ្នឹងពេលដែលចែកជាកងៗ ការផ្គត់ផ្គង់ផ្សេងៗហ្នឹង តើខាងណាជាអ្នកផ្គត់ផ្គង់មកខាងភូមិនីមួយៗហ្នឹង?

**ផ៖** បាទ ការផ្គត់ផ្គង់នៅភូមិនីមួយៗហ្នឹង សម្ភារៈនៅក្នុងភូមិតែម្តងលោកប្រធាន ដូចជាស្រូវអង្ករអីៗហ្នឹង ធ្វើទៅតាមសហករណ៍ក្នុងភូមិហ្នឹង អត់មានគេផ្តល់ពីវាលទេលោកប្រធានបាទ។

[១១:១៥:២៩]

**ស៖** បាទ អរគុណ។ អ៊ីចឹងមានន័យថាពេលៗដែលត្រូវផ្គត់ផ្គង់ភូមិហ្នឹង ទៅយកពីសហករណ៍ធំមកវិញ ឬមួយយ៉ាងម៉េចសហករណ៍ នៅៗកន្លែងណា? យើងៗទៅយកមកឬមួយយ៉ាងម៉េច?

**ផ៖** បាទ ពេលព្រឹកយើងត្រូវទៅដឹកមកពីអង្គពណ្ណរាយ បើឧបមាសហករណ៍ប៉ែនមាសអ៊ីចឹងទៅដឹកអង្ករមក គេថាគេឲ្យប៉ុន្មានកំប៉ុងអាហ្នឹងគេយកប៉ុណ្ណឹងមក មានបន្លែមានអីយកមកទៀតមក

ហើយៗសហករណ៍កង៣ គេយករទេះមួយដែរមក។ សហករណ៍ខាងត្បូងហ្នឹងគេរទេះមួយដែរមកគេចែក មានពាណិជ្ជគេនៅចែកកន្លែងហ្នឹងលោកប្រធានបាទ គេវាល់ចែកបាទ។

**ស៖** អរគុណ។ ចំណុចមួយទៀត អម្បាញ់មិញមានការលើកឡើងហើយដែលពាក់ព័ន្ធនឹងការប្រមូលទ្រព្យសម្បត្តិយកមកដាក់រួម។ តើការប្រមូលទ្រព្យសម្បត្តិយកមកដាក់រួមនេះ នរណាជាអ្នកប្រកាសប្រមូលទ្រព្យសម្បត្តិអស់ទាំងហ្នឹង?

**ឆ៖** បាទ ការប្រមូលទ្រព្យសម្បត្តិរួមដាក់នៅកន្លែងកាស៊ីនបាយនេះ មេប្រធានកងជាអ្នកប្រមូលលោកប្រធាន ព្រោះថាស្លាបព្រាមួយគេមអត់ឲ្យទុកផងបាទ ឆ្នាំង ចាន ប្រមូលដាក់មកសហករណ៍ទាំងអស់ ហើយយើងចង់ទុកស្លាបព្រាមួយគេដេញដោល គេថាអត់ឲ្យទុកទេ "ទុកធ្វើអ្វីស្លាបព្រាចង់ដាំបាយហូបឯកជនហ្អេ!" គេថាអ៊ីចឹងទៀតបាទ ដឹងប៉ុណ្ណឹងលោកប្រធាន។

[១១:១៧:២៩]

**ស៖** អរគុណ។ ចុះពេលដែលគេប្រមូលមកហើយៗការចាត់ចែងប្រើប្រាស់គឺចាត់ចែងទៅតាមកងនីមួយៗ ឬមួយយ៉ាងម៉េច? ព្រោះពូបានលើកឡើងថា មានកង១, កង២, កង៣ មិនអ៊ីចឹងបាទ។ តើគេចាត់ចែងយ៉ាងម៉េចដែរ ទ្រព្យសម្បត្តិដែលគេប្រមូលមក ឬមួយគេប្រមូលតាមកង? គេប្រើតាមកង?

**ឆ៖** បាទ កាស៊ីនក្នុងភូមិគេប្រើទៅតាមកាស៊ីនក្នុងភូមិ។ កងជីកប្រឡាយ គេមានកាស៊ីនគេដើរតាមបាទ ដើរតាមដាំបាយអ៊ីចឹងទៅមានសម្ភារៈគេរែកតាមខ្លួនគ្រប់គ្នាអ៊ីចឹងទៅលោកប្រធានបាទ។

**ស៖** អរគុណលោកពូ។ ចំណុចមួយទៀតដែលលោកពូបានលើកឡើងថា លោកពូបានទៅបង្រៀន ទទួលបន្ទុកបង្រៀនក្មេង។ ខ្ញុំចង់ដឹងថាពីដំបូង តើនរណាគេដែលចាត់តាំងឲ្យលោកពូទៅបង្រៀនក្មេងហ្នឹង ហើយតើបង្រៀនអីខ្លះ? គេមានប្រាប់ឲ្យថាត្រូវបង្រៀនអក្សរ ឬមួយត្រូវបង្រៀនពាក់ព័ន្ធគោលនយោបាយបដិវត្តន៍ ឬមួយត្រូវបង្រៀនស្អីខ្លះ?

**ឆ៖** បាទ គេចាត់តាំងខ្ញុំឲ្យបង្រៀន។ គេថាមេកងគេនៅខាងមុខសញ្ញាមួយហ្នឹង គេឲ្យខ្ញុំទៅបង្រៀនក្មេង បង្រៀនអក្សរផង បង្រៀននាំវាឲ្យមើលគោផង បង្រៀនវាឲ្យកើបអាចម៍គោដាក់គំហុកផងលោកប្រធាន បាទតែប៉ុណ្ណឹងទេ។

[១១:១៩:៤០]

**ស៖** អរគុណ លោកពូ។ តើមានការបង្រៀនមួយដែលគេថាបង្រៀនទៅក្មេងៗឲ្យហៅអង្គការជាឪពុក ឬមួយជាម្ដាយអី ដែលមានបង្រៀនអ៊ីចឹងទេអត់?

**ឆ៖** បាទ អត់មានប្រាប់អ៊ីចឹងដែរ លោកប្រធាន ព្រោះថាម្ដាយៗដោយខ្លួន ហើយអង្គការគេ គេនៅខាងកន្លែងគេធ្វើជី ធ្វើប្រឡាយនេះហ្នឹង ព្រោះថាឲ្យខ្ញុំបង្រៀនៗថា រើសអាចម៍គោ បង្រៀនថា អក្សរ។ អក្សរហ្នឹងបង្រៀនតាមសៀវភៅគេចែកមកលោកប្រធាន។ ត្រង់រៀនឲ្យហៅឪពុកហៅម្ដាយ អត់ទេ។

**ស៖** អរគុណលោកពូ។ ខ្ញុំចូលចំណុចមួយទៀត ចំណុចហ្នឹងអម្បាញ់មិញខាងសហព្រះរាជអាជ្ញាគាត់បានលើកដែរ វាពាក់ព័ន្ធនឹងការបែងចែកប្រជាជន។ ខ្ញុំចង់ដឹងថាតើលោកពូអាចប្រាប់បានទេថា ការបែងចែកប្រជាជនហ្នឹង ថ្នាក់ណាដែលជាអ្នកជ្រើសរើសបែងចែកហ្នឹងបាទ?

**ឆ៖** បាទ ការបែងចែកប្រជាជនជាបីប្រភេទហ្នឹង គឺថាថ្នាក់ឃុំលោកប្រធាន ឲ្យរើសបាទ។

**ស៖** អរគុណលោកពូ។ ថ្នាក់ឃុំឲ្យរើស ហើយលោកពូបានដឹងថាតើការរើសហ្នឹង គេរើសប្រជាជនណាទៅចូលក្នុងកង១? ប្រជាជនណាទៀតចូលនៅក្នុងកង២? ប្រជាជនណាទៀតចូលកង៣? ផ្អែកទៅលើមូលហេតុអីដែលត្រូវជ្រើសរើសអ៊ីចឹង? ហើយអ្នកទាំងអស់នោះ ពេលដែលជ្រើសរើសហើយវាមានការងារខុសគ្នាយ៉ាងម៉េចបាទ?

[១១:២២:២០]

**ឆ៖** បាទ ខ្ញុំបាទសូមជម្រាបលោកប្រធានថា ការជ្រើសរើសនេះ ខ្ញុំបាទអត់សូវបានដឹងទេលោកប្រធាន។ គ្រាន់តែគេប្រាប់ខ្ញុំថា "ឥឡូវពួងឯងត្រូវទៅនៅកង១ ហើយពួកកង១ ហ្នឹងត្រូវមកដូរកង២វិញ"។ មិនដឹងគេរើសរបៀបយ៉ាងណាដែរលោកប្រធានបាទ គ្រាន់តែរើសអ៊ីចឹងទៅ ដល់ទៅនៅទៅនៅដូចតែគ្នាលោកប្រធានបាទ។ ប៉ុន្តែគេត្រូវដូរចុះដូរឡើងយ៉ាងម៉េចខ្ញុំអត់បានដឹងដែរ អត់ហ៊ានសួរគេលោកប្រធាន។ គ្រាន់តែថាគេដូរហើយអ៊ីចឹងទៅ ក៏នៅធ្វើការសព្វខ្លួនអ៊ីចឹងទៅណ៎ាបាទ។

**ស៖** អរគុណលោកពូ។ លោកពូបានមានប្រសាសន៍ថា ពាក់ព័ន្ធនឹងអ្នកដែលធ្វើការខ្លាំងបានរបបច្រើន។ លោកបានលើកឡើងអម្បាញ់មិញគឺថា កង១ៗគេធ្វើការងារខ្លាំង ហើយគាត់ត្រូវបានរបបច្រើន។ សួរថា តើការងារខ្លាំងហ្នឹងមានន័យថាម៉េច? មានន័យថា គាត់អ្នកលើកទំនប់ ឬមួយកងផ្សេងទៀតហ្នឹងធ្វើស្ទូងស្រូវធម្មតា ឬមួយយ៉ាងម៉េច បានគេឲ្យរបបអាហារហ្នឹងច្រើនជាងគេបាទ?

**ឆ៖** បាទ កងខ្លាំងហ្នឹង កង ឧបមាថាស្ទូងគេឲ្យស្ទូង១០នាក់ហ្នឹងក្នុងមួយហិកតាហ្នឹងឲ្យហើយមួយព្រឹកហ្នឹង គេហៅថា "កងខ្លាំងហើយ" លោកប្រធានបាទ។

[១១:២៤:០៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អ៊ីចឹងបានន័យថា នៅក្នុងកង១ក៏ដោយ កង២ក៏ដោយ កង៣ក៏ដោយ តែ១០នាក់មួយហិកតាហើយ គឺខ្លាំង?

**ឆ៖** បាទ អ៊ីចឹងហើយលោកប្រធាន គេហៅ"កងពិសេស"លោកប្រធានបាទ។ ខ្លាំងលើសគេ។

**ស៖** សំណួរខ្ញុំ ខ្ញុំកំពុងតែចង់សួរថា ស្អីទៅកងពិសេសហ្នឹង? ហើយកងពិសេសហ្នឹង គេជ្រើសរើសយ៉ាងម៉េច បានជានៅក្នុងកងមួយៗមានកងពិសេស?

**ឆ៖** បាទ បានន័យថា កងពិសេសហ្នឹង ធ្វើការទៅខ្លាំងជាងគេ ធ្វើអ្វីៗក៏ហើយមុនគេដែរបាទ។ អ៊ីចឹងបានគេហៅថា "កងពិសេស"។ ភ្ជួរក៏ហើយមុនគេ បើសិនជាស្ទូងវិញក៏ហើយមុនគេដែរ។ បើកងអត់ពិសេសមិនទាន់ហើយ កងពិសេសហ្នឹងគេហើយៗគេឡើងមកហើយ កងមិនទាន់ពិសេសហ្នឹងនៅស្ទូងនៅឡើយទេបាទ។ អ៊ីចឹងហៅ "កងពិសេស" ឈានមុខគេ បាទ។

**ស៖** អរគុណពូ។ ខ្ញុំបែរទៅរឿងរបបអាហារបន្តិច ថាតើរបបអាហារកាលពីសម័យនោះ គេបែងចែកយ៉ាងម៉េច? ដូចឧបមាថា នៅក្នុងកង១ៗមានប្រជាជន ១០០នាក់អ៊ីចឹង។ តើក្នុង ១០០នាក់ហ្នឹងគេឲ្យជាអង្ករមកយ៉ាងម៉េច? គេបែងចែកថាក្នុងម្នាក់មួយកំប៉ុង ឬមួយកន្លះកំប៉ុង? ឬមួយដូចថាមួយកំប៉ុង១០នាក់អីអ៊ីចឹង បាទ?

**ឆ៖** បាទ ការអាហារហូបចុកហ្នឹង កាលពីមុននោះ វា១០នាក់ហ្នឹងឲ្យតែបីកំប៉ុងទេ លោកប្រធាន ប៉ុន្តែដល់ខ្ញុំទៅនៅខាងអង្គពណ្ណរាយនោះ ហ្នឹងបានម្នាក់កន្លះកំប៉ុងវិញ បាទ។ បើខ្ញុំនៅខាងជើងហ្នឹង ១០នាក់បីកំប៉ុង បាទ។

[១១:២៦:៣៩]

**ស៖** អ៊ីចឹងមានន័យថា នៅពេលដែលយើងទទួលអាហារ របបអាហារហ្នឹងគេដាំបាយឲ្យឬមួយជាដាំបបរឲ្យយើង?

**ឆ៖** បាទ កាលខ្ញុំនៅខាងប៉ែនមាស ហ្នឹងបបរបីកំប៉ុងហ្នឹង ១០នាក់បបរ លោកប្រធាន។ ដល់ខ្ញុំទៅនៅអង្គពណ្ណរាយ ហ្នឹងគេដាំ បាទ ដាំស្ងួតត្រឹមត្រូវ ប៉ុន្តែទៅតែមិនឆ្អែតដែរទេលោកប្រធាន។

**ស៖** បាទ អរគុណ។ ខ្ញុំចង់ចូលទៅចំណុចមួយទៀតដែលក្នុងឯកសារលោកពូបានលើកឡើងដែរ នៅចម្លើយទី១៣ អំពីរចនាសម្ព័ន្ធនោះ គឺលោកពូថាមានគណៈឃុំ គណៈអ៊ីចឹង គណៈឃុំ គណៈស្រុក គណៈតំបន់ ភូមិភាគអ៊ីចឹង ហើយគណៈទាំងអស់ហ្នឹង គឺគេទទួលបញ្ជាពីគ្នាមក។ ខ្ញុំចង់ដឹងថាតើលោកពូ បានដឹងរឿងថា បញ្ជា ទទួលបញ្ជាទទួលអីហ្នឹង តាមរយៈនរណាមក បានលោកពូបានពី

និយាយបញ្ហានេះ?

**ឆ៖** បាទ ដឹងថាទទួលបញ្ហាហ្នឹង ក៏ខ្ញុំនៅជិតៗមេកងគេដែរហ្នឹង បាទ គេនិយាយប្រាប់ខ្ញុំដែរហ្នឹង។ ប្រធានកងនៅក្បែរៗគ្នា គេធ្វើការជាមួយគ្នាហ្នឹង គេនិយាយប្រាប់ខ្ញុំដែរ។ ខ្ញុំដឹងបាទ ប៉ុន្តែខ្ញុំអត់បានធ្វើប្រធានកងទេ គ្រាន់តែថានៅធ្វើការក្បែរគេ គេបញ្ជា គេថាមកពីថ្នាក់ឃុំឲ្យអ៊ីចេះ មកពីថ្នាក់ស្រុកឲ្យធ្វើអ៊ីចឹងណ៎ា លោកប្រធាន បាទ។

[១១:២៨:៤៥]

**ស៖** អរគុណលោកពូ ដោយសារពេលវេលា ខ្ញុំនឹងសួរសំណួរប្រហែលជាពីរទៀតសម្រាប់បញ្ចប់។ ពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា តើមុនឆ្នាំ១៩៧៥ លោកពូនៅទីនោះ បានន័យថាបានលើកឡើងថាមានវត្តពីរ នៅក្នុងភូមិ ឃុំហ្នឹងណ៎ា ហើយខ្ញុំចង់ដឹងថា វត្តពីរហ្នឹងមានព្រះសង្ឃច្រើនទេ កាលមុន៧៥?

**ឆ៖** បាទ វត្តអង្គពណ្ណរាយ ព្រះសង្ឃតិចទេ ព្រះសង្ឃតែ៣០អង្គទេ ហើយវត្តទឹកជុំខ្ញុំ ១០០ជាង ១២០អង្គ វត្តទឹកជុំ មុនឆ្នាំ៧០ បាទ។

**ស៖** ចុះក្រោយពីឆ្នាំមួយពាន់ -- ១៧ មេសា ១៩៧៥ មក តើព្រះសង្ឃនិមន្តទៅណាវិញ ឬមួយលោកនៅវត្តហ្នឹងទេ?

**ឆ៖** បាទ សង្ឃលោកគង់នៅវត្តហ្នឹងដែរ លោកប្រធាន។ អាក្រោយ១៧មេសា ហ្នឹងមក ព្រះសង្ឃទៅសឹកអស់ សឹកបណ្ដើរៗអស់ទៅ បាទ។ ហើយនៅសល់ប៉ុន្មានអង្គ គេឲ្យសឹកអស់ទៀត បាទ អត់មាននៅសល់ទេ បាទ នៅតែវត្តទទេ។

**ស៖** ចុះនៅពេលដែលព្រះសង្ឃសឹកអស់អ៊ីចឹង ពេលដែលក្នុងភូមិ ឬមួយក្នុងកងអីមានការមានស្លាប់មានអី តើទៅរកព្រះសង្ឃពីណាមកចុះ?

**ឆ៖** បាទ រឿងមានអ្នកស្លាប់ហ្នឹង អ៊ីចេះទេលោកប្រធាន កាលណាមានឈឺ គេយកទៅពេទ្យ ទៅដេកពេទ្យអ៊ីចឹងទៅ អាណាស្លាប់នៅពេទ្យ គេកប់នៅកន្លែងពេទ្យនេះ គេអត់មានយក មានព្រះសង្ឃ មិនបាច់មានព្រះសង្ឃមានអី ដូចកាលជំនាន់យើងនៅសង្គមរាស្ត្រនិយមទេ លោកប្រធាន។ មិនបាច់ព្រះសង្ឃទេ យកទៅទុកចោលតែម្ដង បាទ។

[១១:៣១:២០]

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកពូជាច្រើន ហើយខ្ញុំអស់សំណួរហើយលោកប្រធាន បាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី អ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខី-កម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៦:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីដំបូងនោះគឺក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ មុនពេលការតាំងសំណួរទៅកាន់សាក្សីរូបនេះ ខ្ញុំធ្វើការកត់សម្គាល់ថា គេបានផ្តល់ឯកសារចម្លើយសាក្សីចំនួនពីរនៅក្នុងក្រុណ្ឌនេះ ពីសំណុំរឿង ០០៤។ ចម្លើយសាក្សីមួយ គឺជាចម្លើយសាក្សីដ៏សំខាន់សម្រាប់រឿងក្តីរបស់យើងខ្ញុំ ដែលមាន<១២៨>

ទំព័រ។ ពីម្សិលមិញ យើងមានពេលក្រឡេកមើលមួយភ្លែតដែរទៅលើឯកសារពាក់ព័ន្ធទាក់ទងទៅនឹងសាក្សីរូបនេះ។ ឥឡូវនេះគឺថា យើងបានទទួលឯកសារទើបតែ <៥នាទី ឬ>១០នាទីមុន។ ដូច្នេះយើងមិនអាចពិនិត្យមើលចម្លើយសាក្សីនេះឲ្យបានល្អិតល្អន់ទេ។ ដូច្នេះ មធ្យោបាយដែលសមស្រប និងត្រឹមត្រូវគឺថាត្រូវផ្អាកការតាំងសំណួររបស់យើងខ្ញុំ <ឬក៏>ផ្អាកកិច្ចដំណើរការនីតិវិធីដើម្បីឲ្យក្រុមយើងខ្ញុំអាចពិនិត្យមើលទៅលើ<កំណត់ហេតុនៃការស្តាប់>ចម្លើយសាក្សី<ថ្មីទាំងអស់នេះ។ ដូច្នេះ កាលពីម្សិលមិញ យើងបាននិយាយថា យើងអាចបន្តស្តាប់សក្ខីកម្មសាក្សីរូបនេះ ប៉ុន្តែឥឡូវនេះ រហូតមកដល់ពេលនេះ ខ្ញុំសូមនិយាយថា យើងមិនអាចបន្តស្តាប់សក្ខីកម្មសាក្សីរូបនេះបានទេ។ ដូច្នេះពេលនេះ> ខ្ញុំស្នើសុំជាផ្លូវការឲ្យផ្អាកកិច្ចដំណើរការនីតិវិធី<សវនាការ>ត្រឹមនេះសិនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរ យើងបានប្រគល់ទៅដល់ភាគីដែលមានវត្តមាននៅក្នុងសវនាការ<ថ្ងៃនេះ> នូវកំណត់ហេតុ<នៃការស្តាប់ចម្លើយចំនួន>ពីរដែលស្ថិតនៅក្នុងចំណោម<កំណត់ហេតុនៃការស្តាប់ចម្លើយទាំង>៨៩ ដែលយើងនិយាយពីម្សិលមិញ។ <កំណត់ហេតុនៃការស្តាប់ទាំងពីរ>ហ្នឹងគឺពាក់ព័ន្ធនឹងផ្នែកនេះហើយ គឺក្រាំងតាចាន់ និងត្រាំកក់។ ដូច្នេះ យើងៗប្រគល់ឲ្យភ្លាមដល់ភាគីដើម្បីឲ្យពួកភាគីអាចអានឲ្យបានឆាប់រហ័សបំផុត។ អ៊ីចឹងហើយ យើងធ្វើបែបហ្នឹងហើយគឺយើងមិនមែនធ្វើឲ្យភ្ញាក់ផ្អើលអ្វីទេ យើងធ្វើយ៉ាងម៉េចដើម្បីឲ្យពួកគាត់អាចបាន មើលបានច្រើន ព្រោះថាឯក-សារហ្នឹងវាវែង។ ហើយ<កំណត់ហេតុនៃការស្តាប់ចម្លើយចំនួនប្រាំបី>ដែលបានផ្តល់ជូនកាលពីម្សិលមិញ និង<កំណត់ហេតុនៃការស្តាប់ចម្លើយ>ពីរដែលផ្តល់ជូនថ្ងៃនេះ អ៊ីចឹងវាសរុបទៅគឺ ១០ឯកសារ គឺវាពាក់ព័ន្ធនឹងផ្នែកនៃសវនាការយើងនេះហើយ។ ដូច្នេះ ក្នុងចំណោមកំណត់ហេតុ<នៃការស្តាប់ចម្លើយ>ទាំង១០នេះ <គឺមានតែ>កំណត់ហេតុ<នៃការស្តាប់ចម្លើយ>មួយចំនួន<ប៉ុណ្ណោះ ដែល>និយាយអំពីសាក្សី<តែម្នាក់គត់ ដែលមកផ្តល់សក្ខីកម្ម គឺ> 2-TCW-809 <បើសិនជាខ្ញុំមិនច្រឡំទេនោះ។> អ៊ីចឹង<ក្នុងចំណោម>កំណត់ហេតុ<នៃការស្តាប់ចម្លើយទាំង១០នេះ> គឺថាអត់មានពាក់ព័ន្ធទៅនឹងសាក្សី<ម្នាក់>ដែលបានស្តាប់<សក្ខីកម្មរួច>ហើយ <ឬក៏សាក្សី>ដែល<នឹង>មកផ្តល់សក្ខីកម្ម<នាពេលខាងមុខ>នោះទេ។

ដូច្នេះ ខ្ញុំគិតថា<>យើងបាន<ជូនដំណឹងកាលពីម៉ោង១២:០០ ដើម្បីពន្លឿនកិច្ចការងារនេះ។> អ៊ីចឹងខ្ញុំគិតថា<កំណត់ហេតុនៃការស្តាប់ចម្លើយចំនួនពីរថ្មីនេះ> មិនរាំងអ៊ីក្នុងការស្តាប់សក្ខីកម្ម <លោកសាក្សី យ៉ាវ> នៅរសៀលនេះទេ។ អ៊ីចឹងក៏មិនមានផល -- មិនមានការបង្ហាញថា មានផលប៉ះពាល់សម្រាប់សាក្សីនៅថ្ងៃស្អែកដែរ។ សាក្សីនោះ គឺមិនមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកំណត់ហេតុ<នៃការស្តាប់ចម្លើយ>ផ្សេងទៀតដែលបានជូនដំណឹងដល់ភាគីនោះទេ។ ចំពោះព័ត៌មានលម្អិតនៃខ្លឹមសារនៃកំណត់ហេតុ<នៃការស្តាប់ចម្លើយ>ទាំង១០ <ដែលពាក់ព័ន្ធនឹងផ្នែកនេះ> ខ្ញុំមានសហការីរបស់ខ្ញុំ ដែលគាត់អាចផ្តល់ព័ត៌មានបានលម្អិតបន្តិចទៀតនេះ ប្រសិនជាអង្គជំនុំជម្រះចង់បានអ៊ីចឹងនោះ។

[១៣:៤០:៥៩]

**កញ្ញា អង់តា ហ្គីសេះ**

សូមអរគុណលោកប្រធាន។ ជាថ្មីម្តងទៀត ខ្ញុំគិតថាយើងមានបញ្ហាពាក់ព័ន្ធនឹងវិធីសាស្ត្រ ពាក់ព័ន្ធទៅនឹងអ្វីដែលយើងគិតថា វាមានភាពសំខាន់ក្នុងការតទល់ចំពោះសក្ខីកម្មទាំងអស់នោះ។ ដើម្បីឲ្យបានច្បាស់នោះ ខ្ញុំគិតថាការិយាល័យសហព្រះរាជអាជ្ញាគាត់កំពុងតែដាក់អន្ទាក់យើងហើយ ហើយយើងក៏ដឹងអំពី<បញ្ហានៃការដាក់បង្ហាញ>ឯកសាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែរ ក៏ប៉ុន្តែថ្ងៃនេះ សហព្រះរាជអាជ្ញាគាត់អាចងើបឡើង ហើយគាត់និយាយថាខ្លឹមសារ<នៃកំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះ មិនមានផលប៉ះពាល់លើ>សក្ខីកម្ម<របស់>សាក្សីនេះ ឬសាក្សីនោះៗទេ។ <ប៉ុន្តែយើងមិនអាចនិយាយអ្វីបានទាល់តែសោះ ពីព្រោះ>យើងមិនទាន់បាន<អានកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់នេះ>ទេ អ៊ីចឹង<នៅត្រង់ចំណុចនេះ គឺមានភាពលម្អៀងហើយ>។

ហើយចំណុចទី២ ខ្ញុំនិយាយកាលពីម្សិលមិញហើយ <វាមិនមែនដោយសារតែយើងមិនបានបង្ហាញវត្តមានសាក្សីម្នាក់ ដែលត្រូវបានលើកឡើងនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់នោះថាវាមិន>ពាក់ព័ន្ធ<នោះ>ទេ<។ វា>មិនមែន<ដោយសារតែអ្នកដែលមានឈ្មោះទាំងអស់នោះ មិនបានមកបង្ហាញខ្លួន វានាំឲ្យអង្គហេតុ ឬក៏ការរៀបរាប់>ពាក់ព័ន្ធនឹងក្រាំងតាចាន់ <គឺគ្មានប្រយោជន៍នោះទេ>។ អ៊ីចឹងយើង ខាងសហព្រះរាជអាជ្ញាហ្នឹងក៏គាត់ត្រូវតែមាន<ចក្ខុវិស័យឲ្យទូលាយ>អំពីការងាររបស់មេធាវីការពារក្តីដែរ នៅពេលដែលយើងនិយាយអំពីការតទល់សក្ខីកម្មនោះ។ អ៊ីចឹងនេះជាការបញ្ជាក់ពីរ ដែលខ្ញុំចង់ផ្តល់ជូនអង្គជំនុំជម្រះថា នៅក្នុងនេះគឺថាយើងដូចជាស្រពេចស្រពិល យើងមិនដឹងថាតើសហព្រះរាជអាជ្ញាគាត់ទៅណា ទៅណីទេ។ អ៊ីចឹងហើយបានជាយើងស្នើសុំទទួលបានឱកាស

មួយ ដើម្បីឲ្យវាមានភាពស្មើភាពគ្នាក្នុងការពិនិត្យមើលទៅលើឯកសារទាំងអស់ហ្នឹង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១៣:៤៣:០៥]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ចំពោះគោលជំហររបស់យើង គឺយើងបានរំឭកកាលពីម្សិលមិញហើយ ថា<តើវាមានសារៈសំខាន់យ៉ាងដូចម្ដេចខ្លះសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការដែល> សវនាការ<នេះដំណើរការ>ទៅមុខ<។ ប៉ុន្តែយើងកំពុងតែដោះស្រាយជាមួយ>ស្ថានភាព<មួយ ដែលវាគឺជាបញ្ហា និងខុសប្លែកពីរាល់ដង>។ យើងទទួលបានឯកសារធំ ច្រើនណាស់ យើងអត់ដឹងខ្លឹមសារយ៉ាងម៉េចទេ។ អ៊ីចឹងចំណុចនេះហើយ វាផ្ដល់ជាការលំបាកដល់យើង ក៏ប៉ុន្តែយើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងយល់អំពីកង្វល់របស់មេធាវីការពារក្ដី ពីព្រោះថាយើងដូចជាស្ថិតនៅក្នុងស្ថានភាពមួយដូចគ្នាអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយដោយខ្លីទេ។ ខ្ញុំចង់ឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្ដីថាម៉េចមិនស្មើភាព។ <ក្នុងតថភាពជាក់ស្ដែង យើងមិនអាចប្រើឯកសារកំណត់ហេតុស្ដាប់ចម្លើយនោះបានទេ ព្រោះឯកសារទាំងនោះនៅមិនទាន់បាន>ផ្ដល់ជូនភាគី <ហើយ>យើង<មិនទាន់>មាន<ការបញ្ជាក់ច្បាស់លាស់>ពីការិយាល័យសហចៅក្រមស៊ើបអង្កេត<នៅឡើយ។ ដូច្នេះ> យើងមិនអាចប្រើ<ឯកសារទាំងនោះ>នៅក្នុងសវនាការបាន<ទេ។ ខ្ញុំគ្រាន់តែចង់ឲ្យវាច្បាស់លាស់តែប៉ុណ្ណោះ>។

[១៣:៤៤:២៤]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោសខ្ញុំសូមបំភ្លឺមួយ។ គឺថាតាមលក្ខណៈបច្ចេកទេស នៅក្នុងឯកសារដែលបានផ្ដល់ជូនមកយើងទាំងអស់គ្នា<នាពេលចុងក្រោយនេះ> យើងអត់មានឃើញភាពពាក់ព័ន្ធទៅនឹងឯកសារ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យោង ដែលយើងអាចយកមកប្រើនៅក្នុងសវនាការ<សាធារណៈ>បានទេ។ <ដូច្នេះ បើទោះបីជាយើងចង់ប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់នេះ> នៅពេលនេះ យើងមិនទាន់បានអាន<ក៏ដោយ> អ៊ីចឹងយើងមិនអាច<ធ្វើបែបនេះបានឡើយ ក្នុងករណីណាក៏ដោយ គឺក្នុងក្របខ័ណ្ឌ>ដែលកំណត់ដោយសហចៅក្រមស៊ើបអង្កេត<>។ ហើយចំណុចចុងក្រោយ ខ្ញុំដឹងហើយថាយើងមិនអាចប្រើឯកសារហ្នឹងបានទេ បើសិនបើមិនមានការអនុញ្ញាតពីចៅក្រមស៊ើបអង្កេតនោះ ក៏ប៉ុន្តែយ៉ាងហោចណាស់ក៏ពួកគាត់ខាងសហព្រះរាជអាជ្ញាហ្នឹងគាត់បានមើលមុនយើងទៅហើយ។

[១៣:៤៥:១៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៧:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមាន ដែលលើកឡើងដោយភាគីអម្បាញ់មិញនេះ។

បាទ សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូចដែលម្នាក់ៗបានដឹងហើយ មិនមែនជាការស្តីបន្ទោសគ្នានោះទេ ប៉ុន្តែជាការដោះស្រាយស្ថានភាពដែលយើងជួបការលំបាក។ ដើម្បីធានាឲ្យមានកិច្ចដំណើរការនីតិវិធីមួយឿនលឿនទៅមុខ អង្គជំនុំជម្រះបានសម្រេចទៅលើ ពិចារណាទៅលើគំនិតខ្លះៗដែលលើកឡើងតាំងពីម្សិលមិញ ក៏ដូច<ជាពីមុនមក> ហើយយើង<នឹង>ផ្ញើអ៊ីម៉ែលទៅដល់ភាគីនៅថ្ងៃនេះ ដែលកំណត់ថាតើអង្គជំនុំជម្រះបានប្រមើល៍មើលដូចម្តេចអំពីដំណើរការនីតិវិធីសម្រាប់ថ្ងៃមុខ។ <ខ្ញុំមិនចង់ចូលទៅរឿងលម្អិតនោះទេ ដោយសារវាអាចនាំឲ្យមាន>ការច្របូកច្របល់ទេ <ប៉ុន្តែ>យើង<នឹង>ផ្តល់ពេលវេលាឲ្យភាគី ដើម្បីឲ្យភាគីបាន<ស្វែងយល់>អំពីឯកសារនានា ប៉ុន្តែយើងបានគិតថាសម្រាប់<សាក្សី>ថ្ងៃនេះ <>និងសាក្សីសម្រាប់ថ្ងៃស្អែក មធ្យោបាយល្អបំផុត គឺយើងត្រូវប្រើប្រាស់ឯកសារដែលមាននៅក្នុងដៃ។ <ចំពោះរឿងគួរតែកោះហៅសាក្សីទាំងអស់នេះមកវិញ ក្រោយពេលដែលយើងទាំងអស់គ្នាមានពេលវេលាស្វែងយល់>អំពីខ្លឹមសារនៃឯកសារ<ថ្មីដែលនឹងត្រូវដាក់បង្ហាញនោះ គឺសំណើសុំនោះនឹងត្រូវធ្វើឡើង ហើយ>អង្គជំនុំជម្រះនឹងធ្វើការសម្រេចទៅលើសំណើដែលលើកឡើងនេះ។

[១៣:៤៩:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ លោកស្រីចៅក្រម សូមប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សួន វិសាល៖**

**ស៖** សូមអរគុណលោកប្រធាន សូមជម្រាបសួរលោកសាក្សី។ លោកសាក្សីបានឆ្លើយមួយចំនួនហើយ តាំងពីព្រឹកមិញទាក់ទងទៅនឹងសំណួរដែលចោទសួរដោយព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចំពោះខ្ញុំគឺថាមានចំណុចមួយចំនួនដែលមិនទាន់ច្បាស់លាស់។ អ៊ីចឹងសូមសួរបន្ថែម។ ដំបូងនេះខ្ញុំចង់សួរលោកទាក់ទងនឹងការងារដែលនៅសហករណ៍របស់លោកតែម្តង។ លោកបានជម្រាបជូនអង្គសវនាការហើយថាក្នុងពេលធ្វើការនោះ គឺថាក្នុងសហករណ៍របស់លោកមានបីក្រុមចែកផ្សេងៗគ្នា ខ្ញុំចង់ថាតើកម្រិតការងារពីមួយទៅមួយ ពីក្រុមមួយទៅក្រុមមួយហ្នឹង តើដូចគ្នាឬទេ ឬក៏មិនមាន មិនដូចគ្នាទេតាមលោកដឹង?

**ឆ៖** បាទ សូមជម្រាបលោកប្រធានថាការងារទាំងបីក្រុមនេះឃើញថាការងារក្រុមទី១ គឺជឿនលឿនជាងលោកប្រធាន ហើយបន្ទាប់មកក្រុមទី២ ក្រុមទី៣ហ្នឹង ឃើញថាមិនសូវលឿនដូចគេ អ៊ីចឹងបានជាគេចែកជាក្រុម៣ហ្នឹងបាទ សូមជម្រាបអ៊ីចឹងបាទ។

**ស៖** សូមអរគុណ។ សំណួរទី២របស់ខ្ញុំ គឺចង់ដឹងថាតើនៅពេលដែលក្រុមការងារ ឬក៏ក្រុមសហករណ៍របស់លោកធ្វើការហ្នឹង តើនៅពេលដែលឈឺថ្កាត់ហ្នឹង តើគេឲ្យឈប់សម្រាកទេ?

**ឆ៖** បាទ សូមជម្រាបលោកប្រធានថា បើមានឈឺថ្កាត់គេឲ្យឈប់ចូលមន្ទីរពេទ្យដែរលោកប្រធានបាទ យកទៅពេទ្យ។

**ស៖** នៅពេលដែលយកទៅពេទ្យហ្នឹងគឺមានអ្នកថែទាំ មានបងប្អូនក្រុមសាច់ញាតិអីទៅថែទាំអ្នកជំងឺឬទេ ឬក៏គាត់ទៅតែម្នាក់ឯងទេ?

**ឆ៖** បាទ សូមជម្រាបលោកប្រធានថា អត់មានអ្នកបងប្អូនទៅទេ ទៅតែម្នាក់ឯង ហើយបុគ្គលិកពេទ្យគេមាន បើយើងទៅសួរក៏គេអត់ឲ្យយើងទៅសួរដែរ ព្រោះថាយើងមិនមែនពេទ្យទេ គេថាអ៊ីចឹងបាទ ប្រធានកងគេថាបាទ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

E1/264.1

[១៣:៥២:៣៥]

**ស៖** នៅពេលដែលលោកធ្វើការ តើមានពេលឈប់សម្រាកខ្លះទេនៅម៉ោងធ្វើការ?

**ឆ៖** បាទ ចូលធ្វើការអត់មានឈប់សម្រាកទេលោកប្រធាន ធ្វើរហូតទល់ដល់ម៉ោងប្រាំ ចាប់ពីម៉ោងពីរទៅ ម៉ោងប្រាំឈប់សម្រាកមកហូបបាយ ងូតទឹកងូតអីសម្រាកយប់បាទ។

**ស៖** តើនៅក្នុងរយៈពេលធ្វើការក្នុងមួយខែៗ ថាតើមានគេកំណត់ថាតើ១០ថ្ងៃឈប់ម្តង ពីរថ្ងៃឈប់ម្តង ឬបីថ្ងៃឈប់ម្តងអ៊ីចឹង ឬក៏អត់មានទាល់តែសោះ?

**ឆ៖** បាទ សូមជម្រាបថាអត់បានឈប់ទេ បើ១០ថ្ងៃហ្នឹងឲ្យមកផ្ទះមកជួបជុំគ្រួសារ អាហ្នឹងបាន បើថាឲ្យឈប់សម្រាកដូចថ្ងៃអាទិត្យ ច័ន្ទ អត់មានទេលោកប្រធានបាទ។

**ស៖** ប៉ុន្តែពេល១០ថ្ងៃហ្នឹង ពេលឈប់អ៊ីចឹង លោកអាចទៅសួរសុខទុក្ខគ្រួសារបានទៅផ្ទះរបស់លោកបានវិញធម្មតា។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ទៅជួបគ្នា បើគ្រួសារនៅខាងកងចល័ត ហើយយើងនៅខាងកងចល័តដោយខ្លួនដែរ ដោយខាងប្រុស ខាងកងនារីទៅជួបគ្នាប្តីប្រពន្ធ ទៅជួបគ្នានៅយប់ហ្នឹងទៅ។ ស្អែកមកធ្វើការបែកគ្នាវិញបាទ។

[១៣:៥៤:១៨]

**ស៖** សូមអរគុណ។ ខ្ញុំសួរទៅប្រធានបទមួយទៀតគឺទាក់ទៅនឹងការធ្វើការរបស់លោកនៅកងកុមារ។ តើនៅកងកុមាររបស់លោកៗបានបង្រៀនអំពីថារៀនអំពីព្យញ្ជនៈ ស្រះ អ៊ីចឹងទៅ ការប្រកបអីជាដើម។ តើមានរៀនខ្លឹមសារអីផ្សេងក្រៅពីហ្នឹងទេ?

**ឆ៖** បាទ អត់មានរៀនខ្លឹមសារផ្សេងក្រៅពីហ្នឹងទេ លោកប្រធាន មានរៀនតែអក្សរ និងលេខបាទ ហើយចុះៗទៅរៀបចំមើលគោ មើលអំពែ ប៉ុណ្ណឹងបាទ។

**ស៖** តាមចម្លើយរបស់លោក លោកបានឆ្លើយពីព្រឹកមិញថា មានសៀវភៅដែរ។ តើសៀវភៅហ្នឹងគេនិយាយអំពីអីសម្រាប់បង្រៀនសិស្សនោះ?

**ឆ៖** សៀវភៅហ្នឹងគេគូរជារូបក្មេង រូបអីមានគេសរសេរស្រះអ ស្រះអា ដាក់ក្នុងហ្នឹង លោកប្រធាន ដូចសៀវភៅយើងកុមារដ្ឋានយើងពីដើមអ៊ីចឹង លោកប្រធាន បាទ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកបង្រៀនចប់ តើយប់ឡើងឬក៏អី ពេលសម្រាកហ្នឹង តើកុមារទាំងអស់នៅក្រោមការគ្រប់គ្រងរបស់លោកផ្ទាល់ ឬក៏ទៅតាមជួបឪពុកម្តាយគេធម្មតាវិញ?

**ឆ៖** បាទ សុំជម្រាបលោកប្រធានថា នៅជាមួយខ្ញុំទាំងអស់ហ្នឹងពេលយប់ បាទ។ ដល់ថ្ងៃ១០ហ្នឹងបានទៅជាមួយម្ដាយទាំងអស់។ ថ្ងៃខ្លះអត់ទៅក៏នៅជាមួយខ្ញុំដែរទៅបាទ ថ្ងៃ១០ ថ្ងៃ២០ គឺត្រូវម្ដាយទៅផ្ទះ កូនហ្នឹងក៏ទៅដែរ បាទ។

**ស៖** ទាក់ទងទៅនឹងការហូបចុកវិញ តើហូបចុកយ៉ាងម៉េចដែរ? ចំពោះកុមារទាំងអស់នោះ?

[១៣:៥៦:៣៦]

**ឆ៖** បាទ កុមារហូបចុកដូចកងចល័តនារី កងប្រមូលផ្ដុំដែរលោកប្រធាន។ គេឲ្យបាយមួយឆ្នាំងមកហ្នឹង គ្នាប្រាំបីនាក់ដូចគ្នា ប៉ុន្តែកុមារខ្ញុំគាត់អត់សូវហូបនៅកន្លែងកាស៊ីនបាយទេ ភាគច្រើនលួចដាក់ថ្នក់យកមកកន្លែងវាមានបានម្ហូបអាហារអី ដូចត្រីអាំងអីវាចេះតែយកមកហើយ លោកប្រធាន។

**ស៖** លោកបាននិយាយអម្បាញ់មិញ ទាក់ទងទៅនឹងការមានត្រីអាំងមានម្ហូបអីក្រៅ ហើយកុមារអាចខ្ចប់បាយមក។ តើកុមារទាំងអស់នោះអាចរកត្រី រកអីផ្សេងៗបានសម្រាប់ហូបទេ នៅពេលដែលគេត្រូវការម្ហូបអាហារបន្ថែម?

**ឆ៖** បាទ សូមជម្រាបថា ពេលវាទៅឃ្វាលគោអ៊ីចឹង វាៗលួចរកត្រីដែរលោកប្រធាន បាទ។ គេអត់ថាអីវាដែរ វាលាក់ដែរលោកប្រធាន។ អត់ឲ្យប្រធានកងគេឃើញដែរហ្នឹង បាទ។

**ស៖** តើមានប្រធានកងណាក្រៅពីលោក បើលោកអ្នកគ្រប់គ្រងផ្ទាល់នៅលើកុមារហ្នឹងហើយ? មានអ្នកផ្សេងពីហ្នឹងក្រៅគ្រប់គ្រងថែមទៀត ឬយ៉ាងម៉េច?

**ឆ៖** បាទ មានខ្ញុំ ក្រោមគេហ្នឹងលោកប្រធាន។ មានគេលើខ្ញុំទៀត គេគ្រប់គ្រងខ្ញុំហ្នឹងទៀត គេគ្រប់គ្រងក្មេងនៅលើខ្ញុំទៀត។ បើសិនក្មេងណាខុស គេស្ដីឲ្យខ្ញុំ គេស្ដីទាំងក្មេងហ្នឹងទៀតបាទៗ។

**ស៖** សូមអរគុណ។ ខ្ញុំសួរសំណួរចុងក្រោយ។ នៅក្នុងសហគមន៍របស់លោកមានជនជាតិចាមរស់នៅទេ?

**ឆ៖** បាទ សូមជម្រាបថា អត់មានចាមទេលោកប្រធាន មានតែខ្មែរសុទ្ធ។ បាទចិនក៏អត់មានដែរ ចិនទៅនៅកង៣ អស់ហើយបាទ។

**លោក សួន វិសាល៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី រ៉ិចទ័រ កូប៉េ!

[១៣:៥៩:០២]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរតិចតួចទេ មិនជាច្រើនទេ។ សំណួរទី១គឺ ទាក់ទងនឹងចម្លើយដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតគឺសំណួរចម្លើយលេខ<>២៤ <នៃឯកសារលេខ E3/5515> ដែលពាក់ព័ន្ធទៅនឹងអ្នកឈឺ <ហើយលោកឆ្លើយទៅកាន់អ្នកស៊ើបអង្កេត ដោយ>និយាយថា ប្រពន្ធរបស់លោកត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យ ដោយសារតែទាស់កូនខ្ចី។ <សូមលោកជួយរៀបរាប់បន្ថែម តើប្រពន្ធរបស់លោកមានជំងឺយូរប៉ុនណាដែរ? តើនៅពេលណាគេ>បញ្ជូន<គាត់>ទៅមន្ទីរពេទ្យ<>?

**លោក ភ្លៅ យ៉ាវ៖**

**ឆ៖** បាទ គឺទាស់កូនខ្ចី កាលពីឆ្នាំមុន មុនឆ្នាំ១៩៧៥ លោកប្រធាន។ អាហ្នឹងនៅសហករណ៍ភូមិទេ គេឲ្យរែកដី ហើយគាត់ទើបតែកូនង៉ែតបានប្រាំពីរថ្ងៃ ហើយប្រធានកងគេថា "ល្មមទៅរែកដីហើយ" ហើយគ្រួសារខ្ញុំថា "ទៅរែកដីម៉េច! បើខ្ញុំទើបតែកូនង៉ែតបានប្រាំពីរថ្ងៃ" គេថា "អត់អីទេ" ថាអត់អីក៏រែកទៅ វាទាស់ លោកប្រធាន បាទ ទាស់។ ទាស់អ៊ីចឹងទៅ សុំស្រាគេមួយកែវ យកដាក់ពោះកាំប្រមា ក៏គេអត់ឲ្យដែរ គេកំណាញ់អ៊ីចឹងទៅ ហើយដល់នេះ យកទៅពេទ្យអ៊ីចឹងទៅ បានជាទៅលោកប្រធាន បាទ។ ពេទ្យនៅអង្គពណ្ណរាយដែរហ្នឹង។

**ស៖** តើនៅក្នុងឆ្នាំណាដែរ មុនឆ្នាំ១៩៧៥ ឬក៏ក្រោយឆ្នាំ១៩៧៥?

**ឆ៖** បាទ មុននឹងបន្តិច លោកប្រធាន មុនឆ្នាំ១៩៧៥ ប្រហែលជាមុនហ្នឹងប្រហែលពីរបីខែចូលឆ្នាំ១៩៧៥ ព្រោះកាលនោះនៅសហករណ៍ភូមិនៅឡើយ បាទ។ រែកដីតាមត្រពាំងនានា ចាក់ដាំមនបាទ គេឲ្យគ្រួសារខ្ញុំរែក។

[១៤:០១:២៩]

**ស៖** សូមអរគុណលោកសាក្សី។ ប្រធានបទមួយទៀតនេះ លោកបានឆ្លើយពីខាងដើម <សមាជិក>សហករណ៍ គឺគេចែក<ជាបីប្រភេទ> គឺមាន ពេញសិទ្ធិ ត្រៀម ហើយនិងអ្នកផ្ញើ ឬក៏បញ្ញើ។ <តើលោកដឹងថានៅ>ក្នុងចន្លោះពីឆ្នាំ៧៥-៧៩ <គឺថាមានពេលមួយហ្នឹង> គឺថាប្រភេទទាំងអស់ហ្នឹងក៏ត្រូវបានបំបាត់ចោល ដោយឲ្យអ្នកទាំងអស់ហ្នឹងក្លាយទៅជាសមាជិកសហករណ៍ដូចគ្នាៗ ដោយមិនមានការថែងចែកទៅជាបីកងបែបនេះទេ។ តើលោកចាំថា ក្រោយមកគេមានផ្ញើអ៊ីចឹងទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ លោកប្រធាន កាលនោះគេបម្រុង ពួកបម្រុង បម្រុងចូលកង១ដែរ តែវៀតណាមវ៉ៃចូល អត់បានធ្វើទេលោកប្រធាន ក៏ចប់ត្រឹមហ្នឹងទៅ។

**ស៖** តើវាត្រឹមត្រូវទេនៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ ប្រជាជនក្នុងប្រភេទទាំងបីហ្នឹង គឺត្រូវបានរំលាយហើយ ដាក់ចូលតែប្រភេទតែមួយ។ តើលោកនៅមានចាំចំណុចនេះទេ?

**ឆ៖** បាទ ខ្ញុំបាននៅចាំខ្លះដែរ លោកប្រធាន គេត្រូវប្រមូលចូលទាំងអស់ តែកង៣អត់បញ្ចូលទេ បញ្ចូលកង២ និងកង១ លោកប្រធាន បាទ។

[១៤:០៣:០៨]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត។ លោកបានឆ្លើយពីព្រឹកមិញថានៅពេលដែលគេឲ្យហូបបាយរួម ហើយបើប្រជាជនមិនយល់ព្រម យល់ស្របតាមទេ អាចគេយកខ្លួនចេញទៅបាត់ ហើយអាចសម្លាប់។ ហេតុដូច្នេះមិនមានអ្នកណាម្នាក់ហ៊ានជំទាស់តវ៉ាទេ ទាក់ទងទៅនឹងការហូបរួមគ្នានេះ។ សូមលោកលើកជាឧទាហរណ៍បង្ហាញឲ្យបានច្បាស់បន្តិចបានទេ ថាបើសិនជាមានអ្នកណាម្នាក់ដែលត្រូវបានគេចាប់ខ្លួនបញ្ជូនទៅក្រាំងតាចាន់ ឬទៅកន្លែងណាផ្សេងដោយសារការជំទាស់តវ៉ានឹងការហូបរួមនេះទេ?

**ឆ៖** បាទ នៅកន្លែងខ្ញុំខាងជើងអត់មានទេ លោកប្រធាន។ បើនៅកន្លែងខាងត្បូង មានតែតាមួយនោះ ឈ្មោះ តាវិន នោះ គាត់បររទេះ គាត់គ្រាន់តែថាបន្តិច ស្រាប់តែគេឮ គេយកគាត់ទៅ មិនដឹងយកទៅកន្លែងណាវិញ ខ្ញុំមិនបានដឹងដែរលោកប្រធាន បាទ។

**ស៖** ខ្ញុំសួរសំណួរច្រើនអំពីតាវិន។ លោកបានឆ្លើយថា លោកបានឮ<ពី>សមាជិកនៃកង<បររទេះ>របស់លោកម្នាក់ <អំពីមូលហេតុនៃការចាប់ខ្លួនរបស់គាត់> ហើយបញ្ជូនទៅក្រាំងតាចាន់។ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើ<ហេតុអ្វី ឬហេតុដូចម្ដេចបានជា>សមាជិកកង<បររទេះ>របស់លោកហ្នឹង <>ស្គាល់ តាវិន<>? ហើយ<គាត់>មានដឹងទេ ថាមូលហេតុអីបានជាគេចាប់ខ្លួនបញ្ជូនទៅក្រាំងតាចាន់ហ្នឹង?

**ឆ៖** បាទ តាវិន ហ្នឹង ខ្ញុំស្គាល់តើលោកប្រធាន។ ព្រោះតាវិន ហ្នឹង គាត់នៅ -- កាលពីមុនគាត់នៅបររទេះគោជាមួយខ្ញុំ។ ហើយកាលនោះគាត់ចូលទៅហូបបាយនៅក្នុងកាស៊ីននោះ គាត់ហូបអត់ឆ្អែត គាត់ក៏មានសម្ដីចេញមកថា "ស៊ីបាយក៏ស៊ីមិនឆ្អែតដែរ" គាត់ថាអ៊ីចឹង។ គ្រាន់តែប៉ុណ្ណឹងក៏គេឮ ថ្ងៃក្រោយគេយកគាត់ទៅ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:០៥:៣៣]

**ស៖** លោកស្មាន ឬក៏យ៉ាងម៉េចចំពោះមូលហេតុនៃការចាប់ខ្លួនហ្នឹង ឬក៏លោកមិនច្បាស់ទេ?

**ឆ៖** គេចាប់ច្បាស់តើលោកប្រធាន ខ្ញុំឃើញដែរតើ នៅជាមួយគ្នាតើលោកប្រធាន។ នៅជាមួយគ្នារាល់យប់ដេករាល់យប់តើ បាទ ផ្ទះជាមួយគ្នាតើ។

**ស៖** តើអ្នកដែលមកចាប់ខ្លួនគាត់ហ្នឹង មានប្រាប់គាត់ថា ហេតុអ្វីបានជាគេចាប់ខ្លួនគាត់ទេ? ខ្ញុំ<នៅតែមិនច្បាស់ថា ហេតុដូចម្តេចបានជាលោក>ដឹងមូលហេតុនៃការចាប់ខ្លួនគាត់ហ្នឹង។

**ឆ៖** បាទ គេអត់មានប្រាប់អីទេលោកប្រធាន គេគ្រាន់តែថា "យកតាហ្នឹងយកទៅរៀនសូត្រ" គ្រាន់តែថាប៉ុណ្ណឹងគេមានប្រាប់ថាចាប់អីចេះអីចុះអី។ ហើយខ្ញុំបាត់សមាជិកខ្ញុំម្នាក់ដែរ ព្រោះ៤០នាក់បាត់តាហ្នឹងម្នាក់ៗដែរហ្នឹង។ ខ្ញុំសួរគេថា "តាហ្នឹងទៅណា? គេថា តាហ្នឹងគេឲ្យទៅរៀនសូត្រហើយ"។ គេគ្រាន់តែថាប៉ុណ្ណឹងតើលោកប្រធាន។

**ស៖** ខ្ញុំសូមព្យាយាមសួរឡើងវិញ។ តើធ្វើម៉េចបានជាលោកដឹងអំពីមូលហេតុនៃការចាប់ខ្លួននេះ?

**ឆ៖** បាទ បានជាខ្ញុំដឹង វាឮតៗគ្នារឿងចាប់មិនចេះបាត់ទេលោកប្រធាន តែគេចាប់បាត់ម្នាក់ក្នុងសមាជិកអីចឹង ខ្ញុំចេះតែសួរគេអីចឹងទៅ។ សួរគេគេថាគេហៅគាត់ទៅរៀនសូត្រហើយ។ បានខ្ញុំដឹងអីចឹងណា បាទដឹងតែប៉ុណ្ណឹងទេ -- ទៅណាវិញបាទ។

[១៤:០៧:២៩]

**ស៖** លោកសាក្សីព្រឹកមិញលោកបានឆ្លើយថា ប្រជាជនរស់នៅដោយមានភាពភ័យខ្លាច ហើយប្រជាជនមិនហ៊ានធ្វើអីឲ្យខុសទេ បើធ្វើអ្វីខុសគឺថា អាចគេនាំខ្លួនយកចេញទៅ ហើយអាចហ្នឹងសម្លាប់ចោល។ លោកអាចផ្តល់ឧទាហរណ៍មួយបានទេ មាននរណាម្នាក់ធ្វើខុសអីមួយ ហើយត្រូវបានគេនាំខ្លួនយកទៅ<បាត់ ហើយក្រោយមក>សម្លាប់ចោល<>?

**ឆ៖** បាទ ខ្ញុំមិនដឹងលើកឧទាហរណ៍យ៉ាងម៉េចបើក្នុងមូលដ្ឋានខ្ញុំ គេអត់សូវនាំទៅសម្លាប់ទេ ព្រោះមូលដ្ឋាន -- ព្រោះមនុស្សមូលដ្ឋាន អត់ទេ បើក្រៅពីមូលដ្ឋានហ្នឹងបានគេចេះតែយកទៅសម្លាប់ញឹកអីចឹងដែរបាទ។ បើថាក្នុងមូលដ្ឋានគេគ្រាន់តែអប់រំកែប្រែប៉ុណ្ណឹងទេ បាទ។

**ស៖** <តើ>លោកកំពុងនិយាយពីបញ្ហាដែលលោកឮពីគេ ឬក៏និយាយតៗ ខ្សឹបខ្សៀវតៗគ្នា ឬក៏លោក<ពិតជាបាន>ដឹង<អំពីរឿងនេះ?>

**ឆ៖** បាទ ខ្ញុំនិយាយនេះគឺថា ឮពីគ្នា ដែលនៅរស់នៅជាមួយគ្នាទៅហូបបាយជាមួយគ្នាអីហ្នឹង កាលណាបាត់មនុស្សអ៊ីចឹងទៅ ខ្ញុំទៅសួរគេអ៊ីចឹង។ គេថាយកទៅនេះ ទៅនោះ យកទៅរៀនសូត្រអ៊ីចឹង ណាលោកប្រធាន។ បាទ កាលណាបាត់មនុស្សយើងមិនសួរគេ អ៊ីចឹងបាទ។

**ស៖** លោកសាក្សី តើវាអាចត្រូវទេ ដែលថាអ្នកណាម្នាក់ដែលបាត់ខ្លួន <>គឺថា អ្វីដែលលោកកំពុងនិយាយគឺលោកនិយាយដោយស្មានៗ <អំពីការចាប់ខ្លួនរបស់ម្នាក់នោះ>។ អ៊ីចឹងមែនទេ?

[១៤:០៩:២៤]

**ឆ៖** បាទ ខ្ញុំនិយាយអត់ស្មានទេ លោកប្រធាន។ ខ្ញុំនិយាយត្រង់។

**ស៖** លោកសាក្សី វាសំខាន់ណាស់សម្រាប់យើងខ្ញុំបង្ហាញការពិត។ យើងចង់ដឹងថាប្រភពនៃការដឹងរបស់លោក លោកដឹងមកពីណា? តើ -- កាលណាប្រជាជនគេនិយាយគ្នាតៗនេះ គឺមិនមែនមានន័យថាគេបានដឹងដោយផ្ទាល់អីនោះទេ។ អ៊ីចឹងខ្ញុំចង់បានចម្លើយពីលោកថា លោកដឹងព័ត៌មាននេះពីប្រភពណាមក? លោកយល់សំណួរខ្ញុំដែរទេ លោកសាក្សី?

**ឆ៖** បាទ ខ្ញុំយល់សំណួរលោកប្រធានដែរហ្នឹង។ បានន័យថា ដឹងហើយដឹងពីបាត់មនុស្ស បាទ បើដឹងបាត់មនុស្ស ឧបមាថាកងរទេះខ្ញុំ៤០នាក់ ដល់៤០នាក់ វាបាត់ម្នាក់។ បាត់ម្នាក់ ខ្ញុំសួរគ្នាខ្ញុំទៅថា “ចុះតាហ្នឹងទៅណា?” ដល់នេះម្នាក់នោះប្រាប់ថា “គេហៅគាត់ទៅហើយ ហៅល្ងាចមិញ”។ អ៊ីចឹងណ៎ះលោកប្រធាន បាទៗខ្ញុំបានដឹងរឿងប៉ុណ្ណឹងទេ បាទ។

**ស៖** ប៉ុន្តែចម្លើយគឺ គ្រាន់តែដឹងថាមានអ្នកណាម្នាក់បាត់ខ្លួន។ ឯមូលហេតុថា ហេតុអីបានជាអ្នកហ្នឹងបាត់ខ្លួន គឺលោកអត់ដឹងទេ។ លោកយល់ទេចំណុចពីរហ្នឹងវាខុសគ្នានេះ? <ការពិតនោះ គឺអ្នកណាម្នាក់ដែលត្រូវបាននាំខ្លួនយកទៅបាត់ គឺវាខុសគ្នាអំពីមូលហេតុនៃការចាប់ខ្លួនអ្នកណាម្នាក់។>

**ឆ៖** បាទ ខ្ញុំអត់សូវដឹងរឿងដែរ ព្រោះថាគាត់នៅធ្វើការជាមួយគ្នាសុខៗស្រាប់តែបាត់ទៅហើយ ខ្ញុំសួរគេទៅថា “តើតាហ្នឹងគាត់ទៅណា?”, ថា “គេយកគាត់ទៅហើយ” គាត់ក៏នៅស្ងៀម គ្រាន់ប្រាប់ប៉ុណ្ណឹង បាទត្រង់មានរឿងហេតុអី ខ្ញុំអត់បានដឹងដែរបាទ។

[១៤:១១:១៨]

**ស៖** លោកសាក្សី ព្រឹកមិញលោកក៏បានឆ្លើយថា លោកឆ្លើយអំពីកុមារៗនៅកង៣ ដែលបានលួចដូង ហើយក៏គេព្រមានថាបើសិនណាជាហ៊ានធ្វើអ៊ីចឹងទៀត គឺថាគេនឹងយកទៅសម្លាប់ចោល។ លោកមានដឹងរឿងពិតដែលកុមារណាម្នាក់ លួចផ្លែ<ដូង> ឬក៏លួចអ្វីមួយ ហើយត្រូវបានគេចាប់ខ្លួន

បញ្ជូនទៅក្រាំងតាចាន់ ដែរឬទេ?

**ឆ៖** បាទកុមារគ្មានចាប់ទេលោកប្រធាន។ គេអត់ចាប់កុមារទេ គ្រាន់តែថា គ្រាន់តែបើសិនជាលួចបាយ លួចដំឡូង លួចបេះផ្លែឈើហូបអីចឹងទៅ គេគ្រាន់យកព្រមានទេ កុមារគេអត់មានសួរធ្វើអីទេលោកប្រធានបាទ។ គេអត់សម្លាប់ គេអត់យកទៅដាក់ទោសទណ្ឌអីកើតទេ ព្រោះក្មេងអាយុ១២ឆ្នាំយកគ្នាទៅយ៉ាងម៉េច អត់ទេ។ បាទគេអត់ត្រូវធ្វើអីចឹងដែរហ្នឹងបាទ។

[១៤:១២:២១]

**ស៖** តែព្រឹកមិញ លោកបានឆ្លើយថាកុមារៗហ្នឹង ថាបើសិនជាលួចម្តងទៀត គឺថាគេនឹងយកសម្លាប់ចោលហើយ។ ព្រឹមមិញលោកនិយាយអីចឹងទេ? ហើយឥឡូវនេះ លោកឈប់ឆ្លើយថាអីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទខ្ញុំឆ្លើយថា ព្រឹកមិញខ្ញុំថា គេយកសម្លាប់ហ្នឹង គេគំរាមទេ លោកប្រធាន។ ខ្ញុំថាព្រឹកមិញដែរហ្នឹង គេគ្រាន់តែគំរាមក្មេងទេ គេមិនយកសម្លាប់អីទេ។ ហើយដល់យើង គេថាអីចឹងទៅ វាឈប់លួចទៅអាហ្នឹងវារួចខ្លួនហើយបាទ។ ខ្ញុំនិយាយព្រឹកមិញអីចឹងដែរហ្នឹងបាទ។

**ស៖** ខ្ញុំមានសំណួរពាក់ព័ន្ធទៅនឹងគូស្រករដែលទើបនឹងរៀបការ។ លោកមានដឹងឧទាហរណ៍ណាមួយដែលថាគូស្រករណាម្នាក់ត្រូវបានគេបញ្ជូនទៅរៀនសូត្រ ឬក៏បញ្ជូនទៅក្រាំងតាចាន់ ដោយសារតែមិនរួមដំណេក ក្រោយពីគេរៀបការហើយទេ? លោកមានឧទាហរណ៍ជាក់ស្តែងណា ជម្រាបជូនអង្គជម្រះទេ? <ឬក៏វាគ្រាន់តែជាភ័យខ្លាចអ្វីមួយ?>

**ឆ៖** បាទ ការរៀបគូស្រករនេះ គ្មានគេបញ្ជូនទេ លោកប្រធាន អត់ទេ។ ប៉ុន្តែគ្រាន់តែគេលបស្តាប់។ បើកាលណាអ្នកនៅលើផ្ទះដឹងថាមានគេលបស្តាប់ហើយ មិនហ៊ានធ្វើអំពើមិនល្អណាមួយទេ ព្រោះថាខ្លាចគេយកទៅណែនាំដែរហ្នឹង បាទ។ ខ្ញុំចាំតែប៉ុណ្ណឹង លោកប្រធានបាទ។

[១៤:១៣:៥៤]

**ស៖** លោកសាក្សី តើត្រឹមត្រូវទេដែលថា លោករៀបរាប់ <ប្រហែលវាគឺជាវិធានបំភ័យឲ្យ> ខ្លាចជាទូទៅ <>តែតាមការពិតថាមិនមានអ្នកណាម្នាក់ត្រូវបានគេបញ្ជូនទៅមន្ទីរអប់រំ ឬក៏ត្រូវក្រាំងតាចាន់ ដោយសារតែ<ប្រព្រឹត្តិខុស ដូចជាលួចដំឡូង ឬក៏>គេមិនរួមដំណេក<ក្រោយរៀបការ>នោះទេ។ តើបើខ្ញុំនិយាយថាអីចឹង វាត្រឹមត្រូវដែរឬអត់?

**ឆ៖** បាទជាការត្រឹមត្រូវ លោកប្រធាន បាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** សំណួរចុងក្រោយ គឺថាលោកឆ្លើយពីព្រឹកមិញថា លោកបានឃើញស្តាបត្យ -- ឃើញរូបបដិមា ត្រូវបានគេបោះចូលទៅក្នុងទឹក។ លោកអាចជម្រាបឲ្យលម្អិតបន្តិចមើល៍ តើលោកបានឃើញបញ្ហាហ្នឹងនៅកន្លែងណា? នៅពេលណា? ហើយអ្នកណាទម្លាក់រូបបដិមានោះចូលទៅក្នុងទឹកហ្នឹង?

**ឆ៖** រូបបដិមានៅវត្តទឹកជុំ ទម្លាក់ហ្នឹងដោយប្រជាពលរដ្ឋដែរលោកប្រធាន ព្រោះគេប្រើប្រធានកងគេប្រើឲ្យគាត់ទម្លាក់ គាត់ចេះតែទម្លាក់ទៅ ធ្វើម៉េចគេប្រើហើយបាទ ទម្លាក់នៅក្នុងស្រះ នៅមុខវត្ត នៅមុខវិហារបាទ។

**ស៖** ដូច្នេះអ្នកភូមិបានធ្វើបែបនេះ ដោយសារតែមេភូមិឲ្យធ្វើអ៊ីចឹង។ តើលោកចាំទេ គេបានធ្វើហ្នឹងនៅពេលណាដែរ ទម្លាក់ព្រះពុទ្ធរូបហ្នឹងនៅពេលណាដែរ?

**ឆ៖** ឆ្នាំ៧៥ លោកប្រធាន បែកភ្នំពេញ រៀបចំនៅកន្លែងនោះ រៀបចំវត្តវ៉ាហ្នឹង ផ្សឹកលោកផ្សឹកអីហើយ ដែលគេយកព្រះហ្នឹងទៅដាក់ក្នុងទឹកហើយ រៀបចំសហករណ៍ហ្នឹងទៅបាទ ជារៀងរហូតដល់ឆ្នាំ៧៨ បានចប់ទៅបាទ។

**ស៖** តើប្រធានភូមិដែលណែនាំប្រជាជនហ្នឹង គឺថាត្រូវបានខ្មែរក្រហមដាក់ទណ្ឌកម្មអីទេ?

**ឆ៖** បាទ អត់មានដាក់ទណ្ឌកម្មអីទេលោកប្រធាន ព្រោះកាលហ្នឹង គ្នាគាត់ហ្នឹង គាត់ដាក់ម៉េចបើគេប្រើគាត់មកដែរ មេភូមិ មេឃុំ គេប្រើមកដែរ គាត់អត់ហ៊ានដែរហ្នឹង គាត់ឲ្យតែជួយប្រជាពលរដ្ឋហ្នឹង ជួយសែង ជួយវ៉ៃ ជួយអីដាក់នៅក្នុងទឹកអ៊ីចឹងទៅ។

[១៤:១៦:៥៧]

**ស៖** លោកដឹងច្បាស់អ៊ីចឹង ឬក៏លោកស្មានៗថា គាត់ត្រូវបានថ្នាក់លើណែនាំ?

**ឆ៖** បាទ ខ្ញុំដឹងច្បាស់ ព្រោះបង -- ដែលក្មួយខ្ញុំក៏គេទៅដែរហ្នឹង ប៉ុន្តែគេអត់ហ៊ានវ៉ៃ គេចុះមកវិញ គេថា “ដឹងវ៉ៃម៉េច ព្រះអង្គធំអ៊ីចឹង” គេថាគេអត់ហ៊ាន ចុះមកវិញ។ គេឲ្យវ៉ៃដែរ ប៉ុន្តែគាត់អត់ហ៊ានវ៉ៃ មិនហ៊ានក៏ចុះមកវិញ ឲ្យអ្នកដទៃផ្សេងគេវ៉ៃ គេវ៉ៃព្រះហ្នឹង ដាក់នៅក្នុងទឹក យកសែងយកដាក់ទឹកស្រះ នៅមុខវត្តហ្នឹង។ ឥឡូវនៅក្នុងហ្នឹង មានទាន់ស្រង់ចេញផងហ្នឹង។

**ស៖** លោកដឹងឧទាហរណ៍ណាផ្សេងទៀត ដែលមានការណែនាំឲ្យវាយកម្ទេចពុទ្ធបដិមាហ្នឹងទេ ដឹងរឿងផ្សេងទៀតទេ? <ឬនេះគឺជាពេលតែម្តងគត់ដែលលោកបានឃើញ និងឮអំពីរឿងនេះ?>

**ឆ៖** បាទ ខ្ញុំអត់សូវដឹងដែរលោកប្រធាន។ ព្រោះថាដឹងតែប៉ុណ្ណឹង ខ្ញុំឃើញគេវ៉ៃព្រះតែប៉ុណ្ណឹងហើយយកទៅចោលនៅក្នុងទឹកស្រះតែប៉ុណ្ណឹងលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណច្រើនលោកសាក្សី ដែលឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

អស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហមេធាវីការពារក្ដីលោក ខៀវ សំផន!

[១៤:១៨:៤០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរ<ចំនួនពីរបី> ដើម្បីសួរទៅលោក ដើម្បីសុំការបំភ្លឺអំពីចម្លើយរបស់លោក។

**ស៖** បាទសំណួរទី១របស់ខ្ញុំ នៅក្នុងកំណត់ត្រារបស់ខ្ញុំកាលពីព្រឹកមិញនេះ គឺថាព្រឹកមិញលោកបាននិយាយថា កង១ គឺជាកម្លាំងសំខាន់ដើម្បីធ្វើការងារ ហើយលោកក៏បានឆ្លើយផងដែរថា នៅក្នុងកង ២ មានមនុស្សដែលមិនសូវមានកម្លាំងខ្លាំងក្លាទេ។ អ៊ីចឹងខ្ញុំសូមឲ្យលោកបញ្ជាក់ម្ដងទៀតថា តើនៅក្នុងកង១ហ្នឹងសុទ្ធតែជាអ្នកកម្លាំងខ្លាំង ហើយនៅកង២ហ្នឹងមិនសូវខ្លាំងទេ។ អ៊ីចឹងតើលោកនិយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**លោក ភ្លៅ យ៉ារ៖**

**ឆ៖** សូមជម្រាបលោកប្រធានថា កង១នេះ គឺគេជ្រើសរើសកម្លាំងដែលកម្លាំងច្រើន ហើយនៅក្មេង ហើយចាស់ៗគេដាក់ម៉ុំដែរ ដូចគ្នាដែរ។ ប៉ុន្តែកង២ហ្នឹង អត់សូវខ្លាំងមែន ដូចខ្ញុំជម្រាបអ៊ីចឹង។ កង១ហ្នឹងមានខ្លាំងតែពីរបីកងទេ ក្រៅពីនោះសុទ្ធតែចាស់ដូចគ្នាដែរ។ កងចល័តនារី កងនារីវ័យចាស់ តែមានកូនពីរបី អាហ្នឹងកងខ្លាំង។ ហើយតាៗកងភ្ជួរ បាទ ក៏ខ្លាំងដែរ បាទ ភ្ជួរនង្គ័លបី ១ហិកតា រនាស់ពីរ បាទ។ ហ្នឹងសុទ្ធកងខ្លាំង បាទ។

**ស៖** ក្នុងចម្លើយរបស់លោកចំពោះមុខសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/5515 នៅចម្លើយទី៩ លោកឆ្លើយថា លោកនិយាយពីការបែងចែកការងារ។ ខ្ញុំសូមដកស្រង់៖ "គេចែកកម្លាំងអាស្រ័យតាមការងារដែលយើងអាចធ្វើបាន។ សម្រាប់អ្នកចាស់គេឲ្យធ្វើបង្គីធំៗ ហើយចាស់ៗល្មមឲ្យស្រោចដំណាំ ដាំថ្នាំជក់ ហើយយាយចាស់ៗហ្នឹងឲ្យមើលចៅៗពីប្រាំ ទៅ ១០នាក់។ ហើយក្មេងតូចៗគេ

ឱ្យរើសអាចម៍គោ ក្រៅពីរើសអាចម៍គោ គេឱ្យរៀនប្រហែលជាពីរទៅបីម៉ោងដែរ បន្ទាប់ពីរៀនគេឱ្យទៅឃ្វាលគោដល់ម៉ោងប្រាំល្ងាចទើបមកហូបបាយ"។ សូមបញ្ចប់ការដកស្រង់។ តើនេះជាអ្វីដែលលោកបានឆ្លើយហ្នឹងគឺថានៅក្នុងកង១ហ្នឹង មានកងតូចៗផ្សេងទៀត ហើយគេមានគេរៀបចំតាមអាយុផងដែរ<។ អាយុ>ដូចគ្នានៅក្នុងកងជាមួយគ្នា អាយុខុសគ្នានៅក្នុងកងផ្សេងទៀត។ លោកចង់និយាយអ៊ីចឹងឬក៏យ៉ាងម៉េច?

[១៤:២២:០០]

**ឆ៖** បាទ ខ្ញុំចង់ជម្រាបលោកប្រធានថា កងអ៊ីៗហ្នឹងចំណាស់ៗគ្នាហ្នឹងមួយកង អាហ្នឹងស្ទួង។ ហើយកងពូៗ ចំណាស់គ្នាហ្នឹងមួយកងដែរ ហ្នឹងកងចល័តរែកដីបាទ។ ហើយកងកុមារមួយកងទៀត ហើយកងយាយៗមើលចៅមួយកងទៀត កងតាដាំដំណាំមួយកងទៀត។ បាទ ជម្រាបលោកប្រធានអ៊ីចឹងបាទ។

**ស៖** បាទព្រឹកមិញដដែលហ្នឹង លោកបាននិយាយអំពីកងនេសាទ។ តើកងនេសាទហ្នឹង កងរកត្រីហ្នឹង គេនៅក្នុងកង១ដែរឬមួយក៏យ៉ាងម៉េច?

**ឆ៖** បាទ នៅក្នុងកង១ ក៏មាន កង២ ក៏មានលោកប្រធាន កង៣ ក៏គេចាត់តាំងឱ្យរកដែរលោកប្រធានបាទ រកគ្រប់កងទាំងអស់ រកផងបេះបន្លែផងបាទ។ ត្រីផងបន្លែយកមកឱ្យសេដ្ឋកិច្ចគេក្នុងចង្ក្រានព្រលឹមឡើង រៀបចំដាំស្ល។ ហើយអ្នករកចេះតែរកមក អ្នកនៅដាំចេះតែនៅដាំទៅលោកប្រធាន បាទ។

**ស៖** អ៊ីចឹង បើខ្ញុំយល់មិនច្រឡំទេ គឺថាកងមួយៗហ្នឹងមានកងនេសាទ ហើយនិងភ្ជួរស្រែអ៊ីចឹងដើម្បីផ្គត់ផ្គង់ដល់កន្លែងគេធ្វើម្ហូបអាហារ។ លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំចង់និយាយជម្រាបលោកប្រធានអ៊ីចឹង ថាកង៣ គេមានកងគេទំនុកបម្រុង ប្រធានគេចាត់តាំងហើយៗ។ ហើយកង២ ក៏អ៊ីចឹងដែរ មានអ្នករកត្រី មានអ្នករកបន្លែ។ កង៣ក៏មានដូចគ្នាដែរលោកប្រធានមានទាំងអស់គ្រប់កងទាំងអស់ បាទ។ ប្រសិនបើកង១ ទៅចិញ្ចឹមដល់ កង២ កង៣ វត់មិនរួចទេលោកប្រធានបាទ។

**ស៖** សូមអរគុណ។ និយាយពីកងរកត្រីនេះ លោកបានឆ្លើយថានៅពេលដែលលោកហូបចុកហ្នឹងមានសម្ល។ អ៊ីចឹងខ្ញុំសួរថាតើៗសម្លហ្នឹង គឺសម្លត្រីដែលក្រុមរកត្រីហ្នឹងរកបានឬយ៉ាងម៉េច? ហើយបើសិនជាសម្លហ្នឹងមានសម្លត្រីអ៊ីចឹងមែន អ៊ីចឹងបានហូបសម្លត្រីហ្នឹងយ៉ាងម៉េច ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** សម្លត្រីរាល់ថ្ងៃដែរលោកប្រធាន។ តែថ្ងៃឈប់សម្រាក ដូចជាថ្ងៃ១០អី អាហ្នឹងគេមានម្ហូប

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គេឲ្យដែរហ្នឹង កាប់គោ កាប់អី គេឲ្យ កាប់គោមួយកងអ៊ីចឹង មួយអ៊ីចឹងទៅ គេឲ្យស្លបន្លែអីស្លអ៊ីចឹងដែរ ប៉ុន្តែរកត្រី រករាល់ថ្ងៃ ជួនកាលថ្ងៃណាបានតិចបានច្រើន តាមសេដ្ឋកិច្ចគេដើររកបានអ៊ីចឹង។ កន្លែងណារកអត់បាន ក៏ថ្ងៃហ្នឹងបានតិចអ៊ីចឹងទៅ បាទ។

[១៤:២៥:២៨]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ ឥឡូវសូមផ្តល់វេទិកាទៅសហភាតារបស់ខ្ញុំលោក គង់ សំអុន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី គង់ សំអុន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក ភ្នៅ យ៉ាវ សូមជម្រាបសួរ។ ខ្ញុំ គង់ សំអុន សូមអនុញ្ញាតសួរលោកសំណួរមួយចំនួនទាក់ទងទៅនឹងតួនាទីរបស់លោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំបានស្តាប់ឮហើយថាលោកបានចូលបដិវត្តន៍តាំងពីឆ្នាំ១៩៧០ ហើយក្រោយមកលោកបានធ្វើជាគ្រូបង្រៀននៅក្នុងកងកុមារ។ ខ្ញុំចង់ដឹងឲ្យច្បាស់នូវពេលវេលាដោយសារលោកក៏មានបញ្ជាក់ថាលោកបានទៅធ្វើនៅក្នុងកងរទេះ ដែលបររទេះនោះផងដែរ។ អ៊ីចឹង ខ្ញុំចង់បានពេលវេលាច្បាស់លាស់មួយថា បន្ទាប់ពីថ្ងៃ១៧ មេសា ១៩៧៥ លោកបានធ្វើអីគេមុនដំបូង បន្ទាប់ពីរំដោះភ្លាម?

[១៤:២៦:៤២]

**លោក ភ្នៅ យ៉ាវ៖**

**ឆ៖** បាទ មុនដំបូង ខ្ញុំនៅធ្វើស្រែ លោកប្រធាន។ ធ្វើស្រែនៅខាងកង២ នៅខាងជើង នៅខាងប៉ែនមាសនេះបាទ។

**ស៖** លោកធ្វើរយៈពេលប៉ុន្មានខែ?

**ឆ៖** នៅធ្វើស្រែនៅខាងជើងនេះ ធ្វើតាំងពីឆ្នាំ១៩៧៥។ ៧៥ ដល់គេរៀបចំហើយអ៊ីចឹង គេជម្លៀសខ្ញុំទៅខាងកង១ ខាងត្បូង គេដូរ៧ឆ្នាំ១៩៧៦ លោកប្រធានបាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទ ឆ្នាំ១៩៧៦ លោកចាំខែទេ?

**ឆ៖** បាទ ភ្លេចខែហើយ លោកប្រធាន យូរពេកហើយ ៣០ឆ្នាំជាងហើយបាទ។ មិនដឹងខែអីថ្ងៃអី។ បាននៅចាំតែគេជម្លៀសឲ្យខ្ញុំទៅនៅហ្នឹង ខ្ញុំទៅបររទេះជាមួយពួកដឹកថ្មហ្នឹងបាទ។ មិនទាន់បានធ្វើគ្រូទេកាលហ្នឹងបាទ។

**ស៖** បើអ៊ីចឹង ពេលដែលលោកចេញទៅកង១ លោកទៅចូលក្នុងកងបររទេះ។ លោកអាចបញ្ជាក់បានទេថាលោកធ្វើជាអ្នកបររទេះហ្នឹងរយៈពេលប៉ុន្មានខែដែរ ឬប៉ុន្មានឆ្នាំដែរ?

**ឆ៖** បាទ ខ្ញុំធ្វើកងបរទេះដឹកថ្មធ្វើស្ពានតាមប្រឡាយហ្នឹង ៨ខែ លោកប្រធាន ជិតមួយឆ្នាំ។ ឆ្នាំ៧៦ហ្នឹង ដល់ជិតដាច់៧៦ បានគេឲ្យខ្ញុំទៅមើលក្មេងឃ្វាលគោវិញ។ បាទ ដូចខ្ញុំជម្រាបពីមុនអ៊ីចឹង។

**ស៖** បាទ លោកមានប្រសាសន៍ថាក្មេងឃ្វាលគោ ហើយខ្ញុំស្ដាប់បានសក្ខីកម្មរបស់លោកពីខាងដើមថា លោកមើលក្មេងផង លោកឃ្វាលគោផង។ លោកក៏បានបញ្ជាក់ថាមានក្មេងប្រហែល១០០នាក់ និងគោប្រហែលជា១០០ក្បាល។ លោកអាចបញ្ជាក់ពីក្រុមការងាររបស់លោកទេថា នៅក្នុងក្រុមឃ្វាលគោហ្នឹង ឬក៏កងកុមាររបស់លោកហ្នឹងមានអ្នកធ្វើការជាមួយប៉ុន្មាននាក់?

[១៤:២៩:០៧]

**ឆ៖** បាទ មុនដំបូង ខ្ញុំធ្វើតែម្នាក់ឯងទេ លោកប្រធាន។ ហើយដល់ឆ្នាំ១៩៧៨ ហ្នឹងបានមានគ្រូម្នាក់ក្មេងតូចគេឲ្យមកជំនួយខ្ញុំទៀត។ មុនដំបូងខ្ញុំម្នាក់ឯង ក្មេង១០០នាក់ហ្នឹងបាទ។

**ស៖** នៅពេលដែលលោកធ្វើការម្នាក់ឯង មើលៗកុមារ១០០នាក់ ហើយនិងគោ១០០ក្បាល លោកមានតួនាទី ឬឋានៈជាអ្វីដែរ នៅពេលហ្នឹង?

**ឆ៖** បាទ ខ្ញុំមានតួនាទីថា គេឲ្យខ្ញុំបង្រៀនក្មេង គ្រាន់តែបង្រៀនហើយ ឲ្យខ្ញុំទៅមើលគោ ខ្ញុំអត់ទៅ ខ្ញុំនៅមន្ទីរទេ ខ្ញុំនៅសាលាមួយវែង គេធ្វើឲ្យក្មេងដេកយប់។ ប៉ុន្តែវាទៅ ខ្ញុំណែនាំវាថាយកគោទៅមើល ហើយម៉ោងប្រាំដឹកចងក្រោល ហើយមកហូបបាយមក គ្រាន់តែជម្រាបវា -- ប្រាប់វាប៉ុណ្ណឹង លោកប្រធាន។

**ស៖** ខ្ញុំនិយាយអំពីតួនាទីក្នុងឋានៈក្នុងមុខងារលោកនៅពេលដែលមើលក្មេងហ្នឹង លោកជាមេកង ឬក៏ជាមេក្រុម ឬមានឋានៈអ្វីដែលគេប្រគល់ឲ្យលោកក្នុងនាមជាអ្នកមើលការខុសត្រូវចំពោះក្មេង ហើយនិងគោ១០០ក្បាល ក្មេង១០០នាក់ហ្នឹង?

**ឆ៖** បាទ ខ្ញុំកាលហ្នឹងគេឲ្យខ្ញុំធ្វើគ្រូប្រមូលផ្ដុំលោកប្រធានបាទ មិនមែនគ្រូមុខសញ្ញាធំទេ គ្រូ

ខាងកងប្រមូលផ្ដុំនៅតាមភូមិលោកប្រធានបាទ គេឱ្យខ្ញុំមើលក្មេង។

**ស៖** លោកអាចពន្យល់ជូនអង្គជំនុំជម្រះបានទេថា គ្រូប្រមូលផ្ដុំហ្នឹងធ្វើការងារអី អាម៉េចហៅថាគ្រូប្រមូលផ្ដុំហ្នឹង?

[១៤:៣១:១៤]

**ឆ៖** បាទ គ្រូប្រមូលផ្ដុំនៅមុខសញ្ញានៅតាមភូមិ នៅតាមភូមិហូបបាយនៅក្នុងកាស៊ីនលោកប្រធាន ហើយគ្រូដែលកងចល័តគេនោះ គេទៅនៅវត្តថ្មីខាងកើត ហ្នឹងគេហៅកងចល័ត។ កងចល័តក្មេងធំជាងកងប្រមូលផ្ដុំ។ កងប្រមូលផ្ដុំហ្នឹងក្មេងតូចៗទេ ក្មេង១០ឆ្នាំ ១២ឆ្នាំ ប្រគល់ឱ្យមកខ្ញុំៗមើលវាថែវា បង្រៀនវាអ៊ីចឹងណាលោកប្រធានបាទ។

**ស៖** បាទ ទាក់ទងនឹងឯកសារ E3/5515 ចម្លើយរបស់លោកលេខ១៥ លោកបានបញ្ជាក់អំពីកងកុមារ ហើយកងកុមារហ្នឹងមានកុមារា កុមារី ហើយមានកងកុមារប្រមូលផ្ដុំ។ ខ្ញុំចង់សួរលោកបញ្ជាក់ថាតើកងកុមារប្រមូលផ្ដុំដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ ជាកងមួយនៅក្នុងក្រុមកងកុមារ ឬមួយក៏ការពិតវាជាកងកុមារ ហើយដែលមានកងកុមារប្រមូលផ្ដុំនៅក្នុងក្រុមកងកុមារ លោកយល់សំណួរខ្ញុំទេ? បាទសូមអញ្ជើញ!

**ឆ៖** ជម្រាបលោកប្រធានថា កងនារីអត់មានទេលោកប្រធាន។ នារីគេមានមេនារីគេតើ មានគ្រូនារីគេមួយដែរ ខ្ញុំខាងគ្រូបុរសទេ គ្រូក្មេងតូចៗទេបាទ។

**ស៖** សូមទោស ខ្ញុំបញ្ជាក់អម្បាញ់មិញនេះគឺក្នុងចម្លើយលេខ១៥របស់លោក គេហៅថា "កងកុមារ"។ កងកុមារហ្នឹងហើយមានបើកក្នុងវង់ក្រចកដាក់ថាមានកុមារា ហើយមានកុមារី មិនមែនកងនារីទេ។ ហើយមានកងកុមារប្រមូលផ្ដុំទៀត លោកចាំៗពាក្យហ្នឹងទេ លោកបានឆ្លើយជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ?

**ឆ៖** បាទ ខ្ញុំឆ្លើយជាមួយលោកចៅក្រមថាមានកងកុមារា នៅកន្លែងខ្ញុំហ្នឹងគឺថាកងប្រមូលផ្ដុំ។ កងប្រមូលផ្ដុំហ្នឹងបានន័យថាក្មេងតូចៗលោកប្រធាន ហើយបើកងគេខាងគេធំៗហ្នឹង គេកងមានគ្រូគេដោយខ្លួនទៀត ខ្ញុំ(ឮមិនច្បាស់)ដែរទេ ហើយក្មេងធំនៅខាងវត្តថ្មី ហ្នឹងគ្រូគេដោយខ្លួន បួនប្រាំនាក់ទៀតអាហ្នឹងគេសម្រាប់ខាងចល័តគេនោះ ចល័តរត់ ម៉ោងបួនម៉ោងអីគេឡើងធ្វើការហើយបាទ ហើយកូនសិស្សខ្ញុំបាទអត់ទេដល់ភ្លឺ ព្រោះវាតូចៗវាអត់សូវដឹងអីដែរហ្នឹងបាទ។

**ស៖** បាទ ដើម្បីឱ្យច្បាស់ ខ្ញុំចង់បញ្ជាក់លោកថា តើក្នុងកងកុមាររបស់លោកមានកុមារីនៅ

ក្នុងហ្នឹងជាសមាជិកដែរទេ?

**ឆ៖** បាទ គ្មានកុមារីទេលោកប្រធាន មានតែកុមារា។ កុមារីគេនៅកន្លែងខាងកើតខ្ញុំ នៅផ្ទះមួយដោយខ្លួនទៀតបាទ។

[១៤:៣៤:៥២]

**ស៖** អ៊ីចឹងយើងអាចនិយាយថាកងកុមារបែងចែកជាពីរ។ កងកុមារដែលលោកបានឆ្លើយបញ្ជាក់ថាមានអាយុពី ៨ឆ្នាំ ទៅ១២ឆ្នាំ បែងចែកជាពីរមានខាងកុមារាផ្សេងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក ហើយខាងកុមារីស្ថិតនៅក្រោមការគ្រប់គ្រងអ្នកដទៃទៀត។ ខ្ញុំនិយាយអ៊ីចឹង ត្រឹមត្រូវទេ?

**ឆ៖** បាទ លោកប្រធានមានប្រសាសន៍ត្រឹមត្រូវហើយលោកប្រធាន បាទ។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញនេះ តាំងពីព្រឹកមក ខ្ញុំបានឮការផ្ដល់សក្ខីកម្មរបស់លោកអំពីការបង្រៀនចំពោះកុមារទាំងនោះ លោកបានបង្រៀនថា ឲ្យចេះសរសេរ ចេះប្រកបអក្សរ និងចេះបូកដកលេខ ហើយមិនមានបង្រៀនអីទៀតទេ។ ខ្ញុំចង់សួរលោកថា តើលោកខ្លួនឯងផ្ទាល់មានបានទទួលការហ្វឹកហ្វឺន ការអប់រំណាមួយពីស្ថាប័នខាងលើអំពីបច្ចេកទេសក្នុងការបង្រៀនដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទអត់មានបានទទួលពីស្ថាប័នណាមួយ ឬថាបច្ចេកទេសគេឲ្យខ្ញុំបង្រៀនអីទេ បាទ អត់ គឺថាឲ្យខ្ញុំបង្រៀនវាតែម្ដងព្រោះខ្ញុំជាអ្នកចេះអក្សរ គេនិយាយអ៊ីចឹង ខ្ញុំនិយាយតាមគេលោកប្រធាន បាទ។

**ស៖** បាទ ដើម្បីឲ្យច្បាស់ ខ្ញុំចង់សួរបន្ថែមថា ចុះខាងសហករណ៍ ឬក៏គណៈឃុំមានដែលណែនាំលោកឲ្យបង្រៀនរបៀបណាៗដែរទេ?

**ឆ៖** បាទ គេប្រាប់ដែរលោកប្រធាន។ គេថាឲ្យបង្រៀនក្មេងហ្នឹង វារៀនបីម៉ោងទៅ ហើយបង្រៀនពីម៉ោងដប់មួយអ៊ីចឹងទៅ ចុះហូបបាយហើយមកវិញ ដប់ពីរ ម៉ោងមួយ មួយកន្លះហ្នឹងឲ្យវាទៅមើលគោទៅ គេប្រាប់អ៊ីចឹងដែរលោកប្រធាន។

[១៤:៣៧:២៥]

**ស៖** ក្នុងកម្មវិធីដែលលោកនិយាយថាបង្រៀនបីម៉ោងហ្នឹងជាកម្មវិធីដែលលោកអនុវត្តរៀងរាល់ថ្ងៃ ឬក៏មានការឈប់ខានក្នុងរយៈពេលណាមួយ?

**ឆ៖** បាទ បង្រៀនបីម៉ោង ឬពីរម៉ោងកន្លះហ្នឹង ជារៀងរាល់ថ្ងៃលោកប្រធាន អត់មានឈប់

ទេ។ ព្រោះមានមេកងគេ គេដើរមកក្បែរៗហ្នឹង គេសង្កេតខ្ញុំដែរហ្នឹងថា គេថាបើអត់បង្រៀនក្មេងគេស្ដីខ្ញុំទៀត លោកប្រធាន បាទ។

**ស៖** មេកងចុះមកមើលលោកបង្រៀនហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ ជួនកាលគេមកមួយថ្ងៃអ៊ីចឹងចឹងទៅ ស្អែកគេដើរមកក្បែរៗហ្នឹងទៀតទៅ ជួនកាលខានស្អែកអត់អ៊ីចឹងទៅ លោកប្រធាន មិនបានរាល់ថ្ងៃទេ បាទ។

**ស៖** មានអ្នកផ្សេងទៀតមកមើលលោក ឬក៏មកទស្សនកិច្ចពេលដែលលោកកំពុងបង្រៀនដែរទេនៅពេលដែលលោកបង្រៀននោះ?

**ឆ៖** បាទ លោកប្រធានអត់មានគេមកជិតទេ បង្រៀនតែខ្ញុំម្នាក់ឯងលោកប្រធាន។ បង្រៀនហើយដល់ម៉ោង គេចុះទៅព្រួៗអស់ទៅបាទ រត់ទៅមើលគោអស់ទៅ។ នៅតែខ្ញុំម្នាក់ឯងនៅក្នុងហ្នឹងក្នុងសាលាអត់ទៅជាមួយវាទេខ្ញុំ។

**ស៖** ពេលលោកកំពុងបង្រៀនក្មេង ឬក៏កំពុងមើលក្មេងហ្នឹងមានដែលឪពុកម្ដាយរបស់ក្មេងហ្នឹងមកសុំជួបក្មេងហ្នឹងដែរទេ នៅពេលលោកកំពុងបង្រៀនហ្នឹង ហើយមានដែលនាំយកក្មេងនោះទៅជាមួយដែរទេ?

**ឆ៖** បាទ សូមជម្រាបថា ពេលខ្ញុំបង្រៀននោះ អត់មានឪពុកម្ដាយគេមក លោកប្រធាន។ ឪពុកម្ដាយទៅធ្វើការអស់ហើយ អត់មានបានមកជិតកុមារហ្នឹងទេ បាទ។ ពេលល្ងាចបានចូលមកក្នុងផ្ទះវិញ ហើយបើកុមារហ្នឹងចង់ទៅ ក៏សុំខ្ញុំទៅ ខ្ញុំឲ្យទៅដែរហ្នឹង អត់ហួងវាទេ ព្រោះវាតូចតាចបាទ។

[១៤:៤០:០២]

**ស៖** នៅពេលដែលលោកបង្រៀន តើលោកមានបានធ្វើការផ្ទៀងផ្ទាត់ ឬវាយតម្លៃទៅលើលទ្ធផលនៃការសិក្សារបស់ក្មេងនោះដែរទេ? ឧទាហរណ៍ដូចជា ការធ្វើការប្រឡង ឬក៏ប្រកួតប្រជែងដើម្បីវាស់ស្ទង់សមត្ថភាពរបស់ក្មេងដែលលោកបានបង្រៀននោះ?

**ឆ៖** បាទ អត់សូវបានធ្វើដែរ លោកប្រធាន អត់បានធ្វើពិសោធក្មេងហ្នឹង ថាវាចេះ មិនចេះអត់ប៉ុនថាខ្ញុំជួបវារាល់ថ្ងៃ នៅតើក្មេងអស់ហ្នឹង វាចេះដែរ លោកប្រធាន។ វាហៅខ្ញុំគ្រូដែរ រាល់ថ្ងៃ។ វានៅគោរពដែរ អត់អី បាទ។

**ស៖** លោកអាចពិនិត្យពីពេលចាប់ផ្ដើមដំបូង ពេលដែលលោកចូលធ្វើគ្រូបង្រៀន ហើយនិងដល់ឆ្នាំចុងក្រោយ ពេលដែលបែកគ្នានេះ លោកបានពិនិត្យឃើញលទ្ធផលនៃការបង្រៀនរបស់លោក

ហ្នឹងវាមានលទ្ធផលបែបណាដែរ?

**ឆ៖** បាទ ការបង្រៀនក្មេងរបស់ខ្ញុំ គឺថាចេះតែអក្សរ បើលេខមិនសូវចេះទេ លោកប្រធាន ព្រោះអត់បានរៀនលេខទេ។ រៀនលេខហ្នឹង រៀនអត់បានគុណចែកទេលោកប្រធាន ព្រោះថារៀនតែ លេខ១ អ៊ីចឹងដល់លេខ១០០ លេខ១០០០អ៊ីចឹង ចេះតែប៉ុណ្ណឹង បើថារឿងគុណចែកមិនសូវដែរ លោក ប្រធានបាទ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមពិភាក្សាជាមួយលោកអំពីពលកម្ម។ លោកបាននិយាយ ថាក្មេងទាំងអស់នោះត្រូវធ្វើការ គឺត្រូវទៅឃ្វាលគោ បន្ទាប់ពីថ្ងៃត្រង់ បានន័យថាបន្ទាប់ចេញពីសាលា ទទួលទានអាហារហើយ ត្រូវតែទៅឃ្វាលគោ។ ខ្ញុំចង់សួរថា តើលោកបែងចែកការងារឲ្យក្មេងនោះ ឃ្វាលគោរបៀបណាដែរ?

**ឆ៖** បាទ សូមជម្រាបលោកប្រធានថា ខ្ញុំបែងចែកការងារនេះ គោ -- ចុះពីរៀនទៅ ប្រាប់វាថា "មើលគោម្នាក់មួយៗហ្នឹង ថ្ងៃល្ងាចដឹកគោមកចងក្រោលហើយ មកហូបបាយ។ ពេលព្រឹក ដើរយក បាយក្ដាំងហើយ គេឲ្យបាយក្ដាំងនៅកាស៊ីនហើយ អ្អែង!ទៅកើបអាចម៍គោម្នាក់មួយបង្គីដាក់ក្នុងគ្រហុក ហើយ មកវិញ"។ តែប៉ុណ្ណឹងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់ សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៦:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក គង់ សំអុន**

បាទ សូមអរគុណលោកប្រធាន។

**ស៖** សូមជម្រាបសួរលោក ភ្នៅ យ៉ាវ ឥឡូវយើងបន្តសំណួរទៀត។ មុនពេលសម្រាកខ្ញុំបានសួរលោកទាក់ទងទៅនឹងការដែលឱ្យកុមារទៅធ្វើពលកម្ម គឺទៅមើលគោដែលលោកបានមានប្រសាសន៍ថា កុមារម្នាក់មើលគោមួយ ហើយពេលត្រឡប់មកវិញ ឱ្យទៅកើបអាចម៍គោនោះផង បានម្នាក់មួយបង្គីមក យកមកវិញ យកមកដាក់នៅក្នុង ចាក់នៅកន្លែងរណ្តៅណាមួយអ៊ីចឹងទៅ។ ឥឡូវ ខ្ញុំចង់សួរបន្ថែមថាការងាររបស់កុមារក្រៅពីកុមារម្នាក់មើលគោមួយ ហើយនិងកើបអាចម៍គោនោះ មានការងារអីផ្សេងទៀតដែលកុមារត្រូវធ្វើទេ?

**លោក ភ្នៅ យ៉ាវ៖**

**ឆ៖** បាទ អត់មានទេលោកប្រធាន មានតែប៉ុណ្ណឹងទេ មានតែការងារមើលគោ កើបអាចម៍គោ ហើយនិងរៀនតែប៉ុណ្ណឹង បាទ។

[១៥:០៧:៣៨]

**ស៖** ការងារបែបហ្នឹងគឺបន្តរហូតតាំងពីលោកទៅធ្វើការនៅកងកុមារនោះ រហូតដល់ចប់ពេលវៀតណាមចូលអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងហើយលោកប្រធាន។

**ស៖** បាទ សូមអរគុណ។ ទាក់ទងការស្នាក់នៅ លោកអាចជម្រាបអង្គជំនុំជម្រះបានទេ ថាកុមារទាំងនោះរស់នៅយ៉ាងដូចម្តេចដែរនៅក្រោមការគ្រប់គ្រងរបស់លោក?

**ឆ៖** បាទ វារស់នៅរោងមួយវែង នៅជាមួយខ្ញុំយប់ឡើងលោកប្រធាន។ បាទ អត់ទៅផ្ទះទៅអីទេ បើថ្ងៃដែលគេឱ្យសម្រាកថា ថ្ងៃ១០, ២០ នោះ បានវាទៅជាមួយម្តាយវាលោកប្រធាន។

**ស៖** បាទ ខ្ញុំអាចសួរតទៀតបានទេ?

**ឆ៖** បាទ សួរទៀតទៅ លោកប្រធាន។

**ស៖** ទាក់ទងនឹងអនាម័យការប្រើប្រាស់បន្ទប់ទឹក ឬក៏បង្គន់ជាដើម មានការរៀបចំយ៉ាងម៉េច

ដែរ នៅក្នុងសាលាហ្នឹង?

**ឆ៖** បាទ លោកប្រធាន សាលាអត់មានបន្ទប់ទឹក មានបង្គន់ទេ លោកប្រធាន។ ក្មេងវាទៅជុះតាមព្រៃផ្សៃ ទៅមើលគោទៅមើលអី អត់មានបន្ទប់ទឹកមានអីទេ កាលជំនាន់នោះ មានអីអត់ទេ ទទេសុទ្ធ។

**សៈ** បាទ សូមអរគុណ។ នៅពេលដែលលោកមើលក្មេងទាំងអស់នោះ មានដែលមានករណីដែលក្មេងណាម្នាក់ឈឺ ហើយត្រូវយកទៅពេទ្យអីដែរទេ?

[១៥:០៩:៥១]

**ឆ៖** បាទ មានក្មេងឈឺខ្លះដែរលោកប្រធាន។ បើឈឺអ៊ីចឹងអត់ឲ្យវាទៅមើលគោទេ ឲ្យវានៅក្នុងកន្លែងហ្នឹង ហើយឲ្យទៅផ្ទះទៅ ម៉ែវាយកទៅពេទ្យទៅ ខ្ញុំអត់ដែលយកទៅពេទ្យទេ ឲ្យម៉ែឪវាយកទៅដាក់នៅមន្ទីរពេទ្យនៅជិតហ្នឹងដែរហ្នឹង។ ពេទ្យនៅអង្គពណ្ណរាយ ហើយកងក៏នៅក្បែរហ្នឹងដែរបាទ។

**សៈ** លោកធ្វើម៉េចបានឲ្យដំណឹងដល់ម្ដាយឪពុករបស់កុមារហ្នឹងបាន?

**ឆ៖** ខ្ញុំទៅប្រាប់ម្ដាយវា ថាកូនហ្នឹងអត់សូវស្រួលខ្លួនទេ យកវាទៅពេទ្យផង។ ហើយខ្ញុំអត់បានទៅ ជាប់គ្រប់គ្រង់ក្មេងច្រើន។ ហើយបើអ៊ីចឹងឈឺម្នាក់ហ្នឹងឲ្យម្ដាយយកទៅ បើមិន -- ម្ដាយគេថាមិនបាច់យកទៅក៏បានដែរ កោសខ្យល់ឲ្យៗជាវិញ មកវិញមកលោកប្រធាន បាទ។

**សៈ** លោកទៅប្រាប់ហ្នឹង ទៅប្រាប់នៅឯណា? នៅកន្លែងធ្វើការ ឬនៅផ្ទះ?

**ឆ៖** បាទទៅប្រាប់នៅផ្ទះ ព្រោះផ្ទះនៅជិតៗគ្នាលោកប្រធាន ផ្ទះជិតៗក្បែរៗគ្នាហ្នឹងតើ។ នៅផ្ទះ សាលាហើយនិងផ្ទះនៅប្រហែល ២០០ម៉ែត្រផងហ្នឹង បាទពីគ្នា។

**សៈ** បាទអំមិញ ដោយសារថាអត់មានស្ដាប់ចម្លើយ សំណួររបស់ខ្ញុំជាភាសាបារាំង ខ្ញុំអំមិញខ្ញុំសួរថា តើកុមារដែលឈឺនោះលោកទៅៗ -- លោកសាក្សីទៅជូនដំណឹងទៅឪពុកម្ដាយគេនៅកន្លែងណា? ហើយលោកសាក្សីបានឆ្លើយថា បានទៅផ្ទះ ព្រោះផ្ទះនៅជិតៗគ្នាដែរ បាទ។ ខ្ញុំចង់សួរបន្តទៀតទាក់ទងទៅនឹងរបបអាហារ។ មុននេះលោកបានមានប្រសាសន៍អំពីការទទួលទានម្ហូបអាហាររបស់កុមារហ្នឹងផងដែរ។ អ៊ីចឹង លោកអាចជម្រាបបានទេថា កុមារហ្នឹងមានរបបអាហារយ៉ាងម៉េចដែរ?

[១៥:១២:២២]

**ឆ៖** បាទ ដោយសារកុមារហ្នឹងដូចមនុស្សចាស់ លោកប្រធាន ដូចតែគ្នា កុមារគេឲ្យមួយចានម្នាក់ ដូចគ្នាដែរ បាទ។

**ស៖** មុនៗនេះនៅពេលមេធាវីការពារមុនសួរលោក ទាក់ទងទៅនឹងថា កុមារហូបយ៉ាងម៉េច ហើយលោកមានប្រសាសន៍ថា កុមារអាចយកបាយយកទៅហូបនៅផ្ទះ។ លោកអាចបញ្ជាក់បានទេថា តើកុមារយកម្ហូបទៅញ៉ាំផ្ទះ ដោយសារលោកថា អាចមានត្រីអាំង ត្រីអីបន្ថែមហ្នឹង តើលោកទៅដោយរបៀបណា ចង់និយាយថា កុមារហ្នឹងទៅដោយរបៀបណា? តើគេទៅហ្នឹង គេត្រូវត្រឡប់មកគេង មកដេកនៅកន្លែងលោកវិញ ឬមួយក៏ដេកនៅផ្ទះជាមួយឪពុកម្ដាយរបស់គេ?

**ឆ៖** បាទ គេយកពីកន្លែងកាស៊ីនបាយមក យកមករោងវានៅដែរ លោកប្រធាន អត់មានយកទៅផ្ទះទេ បាទយកមកនៅហ្នឹងហើយ វាដេកទៅបាទយប់ឡើង។

**ស៖** បាទអរគុណ។ ទាក់ទងទៅនឹងកុមារដែលមិនស្ដាប់បង្គាប់ លោកមានប្រសាសន៍ថា មានករណីលួចដូង លួចអីជាដើម ហើយលោកថាមិនមានការដាក់វិន័យអីទេ គ្រាន់តែការស្ដីបន្ទោសព្រមានដើម្បីកុំឱ្យលួចអ៊ីចឹងទៀត។ ខ្ញុំចង់សួរថា តើអ្នកណាជាអ្នកដាក់វិន័យកុមារនោះ?

[១៥:១៤:១៥]

**ឆ៖** បាទ មេកងគេលោកប្រធាន។ មេកងគេអ្នកដាក់ ខ្ញុំអត់ដែលដាក់អីឱ្យវា ប៉ុនមេកងគេ គេប្រាប់ខ្ញុំថា "គ្រូយ៉ាវ ឯងប្រយ័ត្នក្មេងលួចបេះនេះ បេះនោះ បេះដូងអី ប្រាប់វាផង កុំឱ្យលួច"។ គេគ្រាន់ថាប៉ុណ្ណឹងលោកប្រធាន។ បាទប៉ុនវានៅតែលួចដដែលហ្នឹង ធ្វើអីវាបាន តែៗដេញវាៗរត់ ក្មេងធ្វើអីវាបាទ។

**ស៖** សម្រាប់ខ្លួនលោកផ្ទាល់លោកមានដែលស្ដីបន្ទោស ឬក៏ដាក់វិន័យចំពោះកុមារណាម្នាក់ទេ?

**ឆ៖** បាទ មានដាក់ខ្លះដែរ លោកប្រធាន។ កុមារនោះវាឈ្លោះគ្នា ខ្ញុំអត់វ៉ៃទេ គ្រាន់តែស្ដីបាទ។ ថាថ្ងៃក្រោយលែងឈ្លោះគ្នាៗសុទ្ធតែគ្នាយើងទេ កុំឈ្លោះគ្នាអី។ ហើយវាលែងអីដែរលោកប្រធាន។ វាស្ដាប់ខ្ញុំប្រាប់វាដែរហ្នឹងបាទ។ ណែនាំវាកុំឱ្យឈ្លោះឱ្យទាស់គ្នាទៅមើលគោហ្នឹង ឱ្យលែងជាមួយគ្នាស្រួលបួល កុំវ៉ៃគ្នា កុំអី មកវិញអត់អីដែរលោកប្រធានបាទ សុខស្រួល។

**ស៖** ចុះក្នុងករណីដែលដឹងទៅដល់មេកង ដែលលោកមានប្រសាសន៍អំមិញនេះ តើគេដឹងដោយរបៀបណា?

**ឆ៖** ដឹងក្មេងលួចរបស់ ដូចផ្លែឈើ ផ្លែអីហ្នឹង ដឹងតាមអ៊ីៗទេលោកប្រធាន អ៊ីៗគាត់ដើរធ្វើការឃើញក្មេងវាបេះ វាអ៊ីចឹង គេរាយការណ៍ប្រាប់គណៈកងគេទៅ បាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសហករណ៍ នៅក្នុងចម្លើយ១២ របស់លោកនៅក្នុង

ឯកសារ E3/5515 លោកបានបញ្ជាក់អំពីឃុំសំរោង ដែលមានបីសហករណ៍ បាទ។ ហើយទន្ទឹមនឹងនោះលោកក៏បានបញ្ជាក់អំពីកង មានកងបីដែរ គឺកង១, កង២ និងកង៣។ ខ្ញុំចង់សួរបញ្ជាក់ថាតើការប្រើប្រាស់ពាក្យថា "សហករណ៍" ហើយនិង "កង" នេះ មានន័យដូចគ្នាឬសម្រាប់លោកនៅក្នុងទីនេះ?

[១៥:១៦:៤៩]

**ឆ៖** បាទ "សហករណ៍" មិនមែនដូច "កង" ទេ លោកប្រធាន។ កងគេដើរតាមភូមិ ដើរតាមចល័តនានា ដែលធ្វើការតាម -- ដូចជីកប្រឡាយ អាហ្នឹងគេហៅកងជីកប្រឡាយ កងប្រមូលផ្តុំនៅវត្តថ្មី អាហ្នឹងគេហៅកងចល័ត ឯកាស៊ីនបាយនេះ មិនមែនៗកងដែរទេ ហៅកងៗខុស កាស៊ីនហើយនិងកងខុសគ្នា។ កងប្រមូលផ្តុំគេហូបបាយដោយកងប្រមូលផ្តុំ អឺៗនៅតាមមូលដ្ឋានហូបបាយនៅចង្ក្រានមូលដ្ឋានបាទ។ អឺចឹងលោកប្រធាន បាទ។

**សៈ** សំណួររបស់ខ្ញុំៗសួរពី "សហករណ៍" មិនមែន "គ្វីស៊ីន" ពីព្រោះលោកនិយាយនៅក្នុងចម្លើយ១២របស់លោក។ ខ្ញុំសូមអានជូនដើម្បីឲ្យលោកស្តាប់បានច្បាស់។ សូមដកស្រង់៖ "នៅក្នុងឆ្នាំ១៩៧៦ គេបានបែងចែកប្រជាជនឲ្យទៅរស់នៅតាមសហករណ៍។ នៅក្នុងឃុំសំរោង មានបីសហករណ៍ ការបែងចែកសហករណ៍នោះ គឺសំដៅទៅលើប្រជាជនប្រភេទទី១ គេហៅថាកង១ ជាប្រជាជនមូលដ្ឋាន(ចាស់ពេញសិទ្ធិ)ដែលមានទីតាំងស្ថិតនៅក្នុងភូមិអង្គពណ្ណរាយ។ ប្រភេទទី២ ឬកង២ ជាប្រជាជនមូលដ្ឋាន(ត្រៀម)ដូចគ្នាដែរ តែមានបងប្អូនជាប់ពាក់ព័ន្ធ ឬ ជាប់និន្នាការជាមួយខ្មាំងដែលមានទីតាំងស្ថិតនៅភូមិប៉ែនមាស។ ចំណែកប្រភេទទី៣ ឬកង៣ ជាប្រជាជនដែលជម្លៀសមកពីភ្នំពេញ ឬហៅថាអ្នក១៧ មេសា (បញ្ញើ) ដែលមានទីតាំងស្ថិតនៅភូមិតាសោម"។ បាទខ្ញុំចង់ឲ្យលោកពន្យល់ពាក្យថា" សហករណ៍" ហើយនិងពាក្យថា "កង១" "កង២" "កង៣" ដែលលោកប្រើនៅក្នុងឃុំសំរោងនេះ ដែលថាមានបីសហករណ៍ ហើយមានបីកងដែរ។ អឺចឹងខ្ញុំចង់សួរថា តើពាក្យថា "សហករណ៍"នេះមានន័យថា "កង១, កង២, កង៣" ហ្នឹង មែនដែរទេ?

[១៥:១៩:៤៣]

**ឆ៖** បាទ សូមជម្រាបលោកប្រធានថា "សហករណ៍"នេះ នៅក្នុងកាស៊ីនបាយមួយៗ គេប្រើពាក្យថា "សហករណ៍" លោកប្រធានបាទ។ ឧបមាថាសហករណ៍នៅវត្តអង្គពណ្ណរាយ ហ្នឹងគេថាសហករណ៍កង១។ សហករណ៍នៅប៉ែនមាស សហករណ៍កង២។ សហករណ៍នៅខាងអង្គតាសោម គេហៅសហករណ៍កង៣។ បាទ គេប្រើពាក្យហ្នឹងវាពីរពាក្យ។ សហករណ៍មួយ កាស៊ីនមួយ បាទ "កាស៊ីន"

និង "សហករណ៍" ដូចតែគ្នាទេលោកប្រធាន អត់ប្លែកគ្នាប៉ុន្មានទេបាទ។

**ស៖** ចុះពាក្យថាកង កង១, កង២, កង៣ នេះជាគ្រឹស៊ីនមែនទេ?

**ឆ៖** បាទ កាស៊ីនហ្នឹង ពាក្យថាកងហ្នឹងវានៅក្នុងកាស៊ីនហ្នឹងដែរលោកប្រធាន។ ឧបមាថាកង១ហ្នឹង វាមានកាស៊ីននៅខាងវត្តអង្គពណ្ណរាយ គេហៅថាកាស៊ីនរបស់កង១បាទ កាស៊ីនបាយហ្នឹង សហករណ៍ៗកង១ហើយ។ ហើយបើសហករណ៍នៅប៉ែនមាស គេហៅថាសហករណ៍កង២បាទៗ ពន្យល់ប៉ុណ្ណឹងបាន លោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

គុយហ្ស៊ីនៗហ្នឹង រោងបាយហ្នឹងអ្ហែ! និយាយរោងបាយហ្នងទៅហី មិនចាំបាច់និយាយគុយហ្ស៊ីនបកម៉េច អ្នកបកប្រែនេះ? អ្ហាស! ហីពាក្យដូចជាប្លែក ទើបឮប្រើតែម្នាក់ឯង។ អ្ហាស! រោងបាយ ឬក៏គុយហ្ស៊ីន ច្បាស់លាស់? ឬក៏អត់ចេះពាក្យរោងបាយទេ សាក្សី?

[១៥:២១:៤៧]

**លោក ភ្នៅ យ៉ាវ៖**

**ឆ៖** បាទ ខ្ញុំចេះពាក្យរោងបាយលោកប្រធាន។ តែពាក្យគេហៅថា "កាស៊ីនបាយ" លោកប្រធាន ពាក្យគេហៅនៅក្នុងនោះលោកប្រធាន។ បាទ រោងបាយក៏មានដែរ ប៉ុនគេ ពាក្យគេប្រើថាកាស៊ីនៗបាយ បាទ ឬសហករណ៍បាទ សហករណ៍ហ្នឹងបីហ្នឹងគេប្រើដូចគ្នា "រោងបាយ" និង "កាស៊ីនបាយ" និង "សហករណ៍"។ បាទ ពាក្យហ្នឹងវាតែមួយលោកប្រធានបាទ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ដើម្បីបញ្ជាក់ចំណុចនេះឲ្យបានច្បាស់ ខ្ញុំចង់សួរលោកថា តើខុសគ្នាទេ ប្រធានសហករណ៍ ប្រធានកាស៊ីន ឬក៏ប្រធានរោងបាយ មានមនុស្សផ្សេងៗគ្នាទេ ឬក៏ជាមនុស្សតែម្នាក់?

**លោក ភ្នៅ យ៉ាវ៖**

**ឆ៖** បាទ ប្រធានរោងបាយ បើថាប្រាំនាក់ តែប្រាំនាក់ទេលោកប្រធាន អត់មានប្លែកគ្នាទេ។ គឺថាគេ សេដ្ឋកិច្ចគេប្រាំ អ្នកដាំប្រាំ មាន១០នាក់ហ្នឹងទេលោកប្រធាន ហើយរោងបាយមួយហ្នឹងបាទ។

**ស៖** នៅពេលលោកនិយាយអំពីរោងបាយ លោកសំដៅទៅចុងភៅដែរទេ ឬមួយក៏លោករាប់ពីថ្នាក់ដឹកនាំដែលហៅថាប្រធានសហករណ៍ ឬក៏គណៈសហករណ៍។ តើលោកប្រើពាក្យអីនៅក្នុងតំបន់

របស់លោក គេហៅអីទៅ?

**ធ៖** បាទ នៅកន្លែងខ្ញុំបាទ គេប្រើពាក្យថា "រោងបាយ"ដែរ លោកប្រធានបាទ។ ជួនកាលគេហៅ "កាស៊ីនបាយ" ជួនកាលគេហៅ "សហករណ៍" បីមុខហ្នឹង។ គេចង់ហៅអាណាក៏បានដែរ លោកប្រធានបាទ បីមុខហ្នឹង បីឈ្មោះ។

[១៥:២៤:០៥]

**ស៖** បាទ ខ្ញុំយល់អាហ្នឹងមួយៗជំហានហើយ ក៏ប៉ុន្តែនៅពេលដែលលោកលើកឧទាហរណ៍ពីខាងគណៈកម្មការសេដ្ឋកិច្ច ឬក៏អីដែលលោកមានប្រសាសន៍មុនហ្នឹងបន្តិចអំមិញហ្នឹង វាធ្វើឲ្យខ្ញុំច្រឡំថាតើសហករណ៍ ហើយនិងរោងបាយហ្នឹងមានអ្នកដឹកនាំផ្សេងពីគ្នា ឬមួយជាមនុស្សតែម្នាក់? លោកអាចបញ្ជាក់ចំណុចហ្នឹងឲ្យច្បាស់បន្តិចមក។

**ធ៖** បាទ នៅក្នុងរោងបាយមួយហ្នឹង មានប្រធាន អនុប្រធាន និងសមាជិក។ បីនាក់លោកប្រធាន ហើយមានពីរនាក់ទៀតនោះ ហ្នឹងខាងសមាជិកទូទៅ ប្រាំនាក់ហ្នឹង។ ហើយអ្នកបេះបន្លែនោះប្រាំនាក់ទៀត ដើរកាប់ត្នោតដកព្រលឹតហ្នឹងប្រាំនាក់ទៀត ដើរអូសត្រីអូសអីហ្នឹងគ្នាគេប្រាំនាក់ទៀត ហើយនៅក្នុងរោងហ្នឹងប្រាំនាក់។ ដល់ពួកនោះយកអីវ៉ាន់មកយកមកឲ្យអ្នកដាំនៅក្នុងនេះ។ បាទអ៊ីចឹងលោកប្រធាន។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងឯកសារដដែល ត្រង់សំណួរចម្លើយលេខ១៥ ដែលលោកធ្វើការបែងចែកកងតូចៗផ្សេងទៀតដែលមានកងពិសេស កងភ្ជួរប្រុសៗ កងដឹកជញ្ជូន កងដកស្ទូងស្រីៗ កងរទេះជាដើម។ល។ ខ្ញុំចង់សួរថាទាក់ទងទៅនឹងកងតូចៗនេះ វាជាក្រុមសម្រាប់ធ្វើការងារនៅក្នុង -- ការងារជាក់លាក់ ឬមួយក៏ក្នុងក្រុមនីមួយៗហ្នឹងមានផ្សេងៗទៀត ឧទាហរណ៍ថាកងភ្ជួរអ៊ីចឹងមានភ្ជួរបីបួនក្រុមទៀត បីបួនកងទៀត ឬក៏មានតែកងភ្ជួរហ្នឹង គឺមានតែមួយកងហ្នឹងទេនៅក្នុងសហករណ៍នីមួយៗហ្នឹង?

**ធ៖** បាទនៅក្នុងសហករណ៍នីមួយៗហ្នឹងមិនមែនមានតែមួយកងទេលោកប្រធាន មានដល់ប្រាំកង ប្រាំមួយកងនោះ។ ឧបមាថាគេទៅភ្ជួរខាងនេះទៅ មួយកងអ៊ីចឹងទៅ ទៅខាងនោះមួយកង ខាងនេះមួយកងអ៊ីចឹងទៅ។ ដល់ខែរដូវវស្សាឡើងធ្វើតែគ្រប់កងទាំងអស់ហ្នឹង កងប្រាំកងក៏ភ្ជួរ៥ហិកតាដែរលោកប្រធាន។

[១៥:២៧:០៩]

**ស៖** បាទ សូមអរគុណ។ នៅក្នុងកងនីមួយៗកងតូចៗអំមិញដែលលោកមានប្រសាសន៍នេះ ថាតើមានការដឹកនាំយ៉ាងម៉េចដែរក្នុងៗកងនីមួយហ្នឹង លោកអាចចាំបានថាតើ មានសមាសភាពនៃការដឹកនាំក្នុងកងតូចៗហ្នឹងដូចម្ដេចដែរ?

**ឆ៖** បាទ ការដឹកនាំក្នុងកងតូចៗហ្នឹងមានប្រធាន អនុប្រធាន សមាជិកបាទ។ ហើយឧបមាប្រាំនាក់ហ្នឹងប្រធាន អ្នកដឹកនាំភ្ជួរអីចឹង ប៉ុន្តែប្រធានហ្នឹងភ្ជួរដែរណ៎ះ! មិនមែនប្រធានហ្នឹងអត់ធ្វើទេ ភ្ជួរនង្គ័លមួយដូចគ្នាដែរ គោមួយនឹមដូចគ្នា។ បាទ ហើយសមាជិកហ្នឹង អនុប្រធានក៏មាន ប៉ុន្តែប្រធានកងធំគេនោះគេអត់ធ្វើទេ គ្រាន់តែប្រាប់យើងទេ ប៉ុន្តែឲ្យប្រធានតូចៗអ្នកគ្នាប្រាំនាក់ហ្នឹងទទួលខុសត្រូវមួយហិកតា ដី១ហិកតាហ្នឹង ហើយអី១០នាក់ ធ្វើម៉េចឲ្យហើយក្នុងរយៈពេលម៉ោងប្រាំមួយ ដល់ម៉ោងដប់មួយព្រឹកឲ្យហើយ ភ្ជួរ ទាំងភ្ជួរ ទាំងស្ទូង។ បាទ សូមជម្រាបលោកប្រធានប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំ -- ទាក់ទងឯកសារដដែលសូមពិនិត្យមើលសំណួរចម្លើយលេខ ២២ ក្នុងចម្លើយរបស់លោក គឺមានទាក់ទងទៅលើរបបអាហារ។ ចំណុចមួយដែលបានសួររួចហើយ គឺទាំងសហព្រះរាជអាជ្ញាបានលើកពីការហូបចុកមិនគ្រប់គ្រាន់ ដែលមាននៅក្នុងចម្លើយរបស់លោកទី២២ នេះ។ លោកប្រធានទាក់ទងនឹងចំណុចនេះ ខ្ញុំបាទសូមអង្គជំនុំជម្រះមេត្តាបន្ថែមនូវប្រតិចារឹកថតសំឡេងដែលមាននៅក្នុងឯកសារ D232។ មានបន្ទាត់ខាងក្រោម 62R។ បាទ ស្ដាស់(/) ឬ – ខ្ញុំសុំអានឡើងវិញ D232/62R ត្រង់ម៉ោងលេខ ០១:០៥:៤១ ដល់ម៉ោង ០១:០៦:៥៧។

ដើម្បីឲ្យច្បាស់ទាក់ទងនឹងចំណុចនេះ ខ្ញុំចង់សួរលោកលម្អិតទាក់ទងនឹងពេលវេលាថា តើមានភាពខុសគ្នាយ៉ាងដូចម្ដេច នៅពេលដែលលោក -- ទាក់ទងនឹងរបបអាហារ -- នៅពេលដែលលោកធ្វើការ នៅក្នុងកង២ ហើយនិងក្រោយមកលោកទៅធ្វើការនៅក្នុងកងកុមារ។ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ?

**ឆ៖** បាទ សូមជម្រាបលោកប្រធានថា កាលខ្ញុំនៅកង២ ហូបបបរ ដល់មកត្បូងទៅ អត់ហូបបបរទេបាទ ហូបបាយរឹងបាទ។ សូមជម្រាបលោកប្រធានអីចឹង។

[១៥:៣២:១៨]

**ស៖** លោកបានជម្រាបរួចហើយ អំពីសម្ដដែលមានត្រី ហើយដែលមានម្ហូបសាច់គោ ១០ថ្ងៃម្ដង។ លោកអាចបញ្ជាក់ទេថា ម្ហូបហ្នឹងគឺនៅពេលណា? គឺនៅពេលដែលលោកធ្វើការនៅក្នុងកុមារហ្នឹង ឬមួយក៏នៅពេលវេលាផ្សេង? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ខ្ញុំបញ្ជាក់បានលោកប្រធាន។ នៅពេលខ្ញុំនៅកងកុមារហ្នឹង បានគេរៀបចំអ៊ីចឹង ហើយបាទ នៅខាងជើងអត់ទាន់រៀបចំទេ ដល់ខ្ញុំទៅនៅខាងត្បូង នៅបង្រៀនក្មេងបានរៀបចំមាន១០ថ្ងៃ ឲ្យមកផ្ទះម្ដង ហើយ១០ថ្ងៃកាប់ មានគោមានជ្រូកអីឲ្យពួករោងបាយហ្នឹងហូបម្ដងបាទ ១០ថ្ងៃម្ដងៗ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា តើកុមារទទួលរបបអាហារដូចលោកដែរទេ?

**ឆ៖** បាទ កុមារទទួលដូចមនុស្សចាស់ដែរលោកប្រធាន អត់អីទេកុមារ បរិបូររបស់វាដែរ អត់ខ្វះខាតទេលោកប្រធានបាទ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរ។

សូមអរគុណលោកសាក្សី ខ្ញុំអស់សំណួរហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណចំពោះលោក ភ្នៅ យ៉ាវ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សី ក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនូវរឿងក្ដីនេះ ហើយការផ្ដល់សក្ខីកម្មរបស់លោកមកដល់ពេលនេះ ដល់ទីបញ្ចប់ហើយ។ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកធ្វើដំណើរទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ភ្នៅ យ៉ាវ ក្នុងការវិលត្រឡប់ទៅកាន់ទៅលំនៅរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ នាំគាត់ចេញចុះ!

ហើយបង្គាប់ឲ្យអញ្ជើញសាក្សីបន្ទាប់ សាក្សីបម្រុង TCW-807 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

[១៥:៣៦:២៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** សួស្ដីលោកសាក្សី តើលោកឈ្មោះអី?

**លោក សៅ ប៉ាន៖**

**ឆៈ** សូមគោរពលោកប្រធាន ខ្ញុំបាទ ឈ្មោះ សៅ ប៉ាន។

**សៈ** អរគុណលោក សៅ ប៉ាន តើលោកប្រាប់អង្គជំនុំជម្រះបានទេ ថាលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆៈ** ខ្ញុំកើតនៅឆ្នាំ១៩៤៧។

**សៈ** បាទ អរគុណ ហើយស្រុកកំណើតរបស់លោក លោកកើតនៅទីកន្លែងណា លោកចាំទេ?

**ឆៈ** ភូមិត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។

**សៈ** ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆៈ** រស់នៅភូមិត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។

**សៈ** លោកប្រកបមុខរបរធ្វើអីសព្វថ្ងៃនេះ?

**ឆៈ** របរកសិកម្ម។

**សៈ** តើលោកអាចប្រាប់អង្គជំនុំជម្រះបានទេ តើឪពុករបស់លោកឈ្មោះអី? ហើយម្ដាយរបស់លោកគាត់ឈ្មោះអី?

**ឆៈ** ឪពុកឈ្មោះ សៅ លន ម្ដាយ ឈ្មោះ សួន គាន។

**សៈ** អរគុណ ហើយចុះប្រពន្ធរបស់លោក គាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆៈ** ប្រពន្ធឈ្មោះ គល់ គឹមសេង កូនមាន ៨នាក់។

**សៈ** អរគុណ ហើយលោក សៅ ប៉ាន តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេថា នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យពីក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ ថ្ងៃទី០៦ ខែមករាឆ្នាំ៧៩ តើលោករស់នៅឯណា? ហើយលោកធ្វើអ្វី?

[១៥:៣៨:៤៨]

**ឆៈ** ខ្ញុំរស់នៅភូមិត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ តាកែវ។ ធ្វើកសិករ។

**សៈ** អរគុណលោក សៅ ប៉ាន។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការព្រឹកមិញថាតាមសមត្ថភាពដែលលោកអាចដឹងគឺលោក មិនមានឪពុកម្ដាយ បុព្វញាតិ កូន បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធ ត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ ហើយតើ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ពិតដែរទេ?

**ឆ៖** ពិតមែន។

**ស៖** ហើយមុននឹងចូលមកអង្គុយនៅទីនេះ ចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែកនៅពីខាងកើតសាលសវនាការនេះហើយឬនៅ?

**ឆ៖** បាទ ហើយ។

**ស៖** តទៅនេះយើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចក្នុងនាមលោកជាសាក្សី អំពីសិទ្ធិ។ លោក សៅ ប៉ាន ក្នុងនាមលោកជាសាក្សី នៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោក នោះនាំឲ្យលោកត្រូវទទួល -- ប្រឈមនឹងការចោទប្រកាន់។

អំពីករណីយកិច្ច លោក សៅ ប៉ាន ក្នុងនាមលោកជាសាក្សី ត្រូវតែផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនៅចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យឆ្លើយតប ចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ហើយដូចដែលយើងបានប្រាប់លោកអម្បាញ់មិញនេះរួចហើយ។

អំពីករណីយកិច្ច ក្នុងនាមជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នៅព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

លោក សៅ ប៉ាន តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ អំឡុងពេលកន្លងមក? ប្រសិនបើមាន តើធ្វើប៉ុន្មានដង? ធ្វើនៅទីណា ?នៅពេលណា?

[១៥:៤១:៥០]

**លោក សៅ ប៉ាន៖**

**ឆ៖** មានម្តង ធ្វើនៅឃុំត្រាំកក់។

**ស៖** ពីពេលណាលោកចាំទេ? ពីឆ្នាំណា?

**ឆ៖** បាទភ្លេច។

**ស៖** អរគុណ ហើយមុននឹងចូលមកដល់ចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្មកាលពីពេលមុន ដែលលោកអះអាងអំមិញថា បានធ្វើនៅឃុំត្រាំកក់នុង ដែលធ្វើជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យស៊ើបអង្កេតហ្នឹង ដើម្បីរំឭក ការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាន។

**ស៖** អរគុណ ហើយតាមសមត្ថភាពដែលលោកអាចដឹង តើនឹងចងចាំបាន តើលោកអាច បញ្ជាក់បានដែរទេថា កំណត់ហេតុស្ដាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះ ពិតជា ត្រឹមត្រូវ ឬក៏វាស៊ីសង្វាក់គ្នា ស្របទៅនឹងចម្លើយដែលលោកបានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើប អង្កេតកាលពីនៅឃុំត្រាំកក់នោះដែរឬទេ?

**ឆ៖** មែន។

**ប្រធានអង្គជំនុំ៖**

ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមវិធាន ៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំ ជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី សៅ ហ៊ាន ហ្នឹងមុនភាគីដទៃទៀតក្នុង រឿងក្ដី។ សូមអញ្ជើញ!

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម។

[១៥:៤៣:៤៤]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** ជម្រាបសួរលោក សៅ ហ៊ាន។ ថ្ងៃនេះ ខ្ញុំនឹងសួរលោកសំណួរមួយចំនួន អំពីព្រឹត្តិការណ៍ ដែលបានកើតឡើងជាយូរយារមកហើយ ហើយសូមលោកឆ្លើយទៅតាមលទ្ធភាពលោកអាចឆ្លើយបាន តែបើសិនណាលោកមិនចាំទេ សូមជម្រាបជូនតុលាការថា លោកមិនចាំទេ សូមកុំឆ្លើយស្មានៗ។ ហើយ បើសិនជាលោកយល់ថាលោកមិនយល់សំណួរខ្ញុំ សួរខ្ញុំឱ្យសួរឡើងវិញ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ ខ្ញុំនឹងរៀបចំសំណួរតាមរបៀបផ្សេង។ ហើយចំណុចចុងក្រោយ គឺសំណួរខ្ញុំនីមួយៗ គឺខ្ញុំផ្ដោតទៅលើ

ចំណុចជាក់លាក់។ អ៊ីចឹង ខ្ញុំសូមឲ្យលោកមេត្តាផ្តល់ការយកចិត្តទុកដាក់ ទៅនឹងសំណួរនីមួយៗ ឆ្លើយទៅតាមលទ្ធភាពរបស់លោក។ ហើយខ្ញុំនឹងចាប់ផ្តើមសួរសំណួរមួយចំនួនតូច អំពីរយៈពេលមុនឆ្នាំ ១៩៧៥ ហើយសំណួរលម្អិត គឺចន្លោះពីឆ្នាំ១៩៧៥ ទៅ១៩៧៩។ ខ្ញុំសូមចាប់សួរអំពីឆ្នាំ១៩៧០ អំពីការចូលមកដល់ដែលខ្មែរក្រហម -- ពីការចូលមកដល់របស់ពួកខ្មែរក្រហម ក្នុងភូមិស្រុករបស់លោក។ នៅក្នុងចម្លើយលោកគឺ E3/5518 ចម្លើយ៤ ទៅដល់៦ លោកថានៅឆ្នាំ១៩៧០ គឺបានចូលមករៀបចំភូមិនិងឃុំ និងបង្កើតឈ្លបភូមិឃុំដើម្បីគ្រប់គ្រង។ សំណួរទី១ ទាក់ទងទៅនឹងឈ្លប ថាតើកងឈ្លបនេះត្រូវបានបង្កើតតាំងពីពេលណាមកដែរ? ហើយុះ<តើតួនាទីរបស់ពួកគេធ្វើអ្វីដែរ>?

**លោក សៅ ប៊ាន៖**

**ឆ៖** កងឈ្លបបង្កើតពីឆ្នាំ១៩៧១ -- ៧០ ពីអំឡុងឆ្នាំ១៩៧០ ដើម្បីគ្រប់គ្រងភូមិឃុំ។

[១៥:៤៦:១៤]

**ស៖** ចុះចំពោះការរៀបចំភូមិឃុំ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើខ្មែរក្រហមរៀបចំបង្កើតភូមិ ឃុំ ដោយរបៀបណាដែរ?

**ឆ៖** ខ្មែរក្រហមចាប់បង្កើតភូមិឃុំ ដោយដំបូងរៀបភូមិមុន។

**ស៖** ហើយសូមលោកជម្រាបជូនឲ្យបានលម្អិតបន្តិចមក នៅពេលដែលលោកឆ្លើយថាខ្មែរ-ក្រហមបង្កើតភូមិឃុំ សូមរៀបរាប់ឲ្យបានលម្អិតបន្តិចមក។

**ឆ៖** មុនដំបូងខ្មែរក្រហមមកជ្រើសរើស មេភូមិ ប្រធានភូមិ អនុភូមិ សមាជិក បន្ទាប់មកទៀតរៀបចំក្រុមៗសាមគ្គី ធ្វើស្រែប្រវាស់ដៃ។

**ស៖** ហើយសូមលោកនិយាយរៀបរាប់សង្ខេបបន្តិចមក ថាតើ<អ្វីជាក្រុមសាមគ្គី? ហើយ> វាខុសពីឃុំដូចម្តេចដែរ?

**ឆ៖** ភូមិខុសពីឃុំ។ មុនដំបូងរៀបចំភូមិមុន ហើយបានក្រោយមកបានបង្កើតជាឃុំ ព្រោះឃុំកាលនោះខ្ញុំមិនដឹងថានៅត្រង់ណាត្រង់ណាផង។ ស្គាល់តែភូមិមុនឃុំ។ បន្ទាប់ពីមានភូមិឃុំហើយក្រោយ មកបានៗស្គាល់ទីតាំងឃុំ។

**ស៖** ក្នុងចម្លើយលេខ១៤ <នៃកិច្ចសម្ភាសន៍របស់លោក> លោកបាននិយាយដូចតទៅនេះ៖ "ប្រធានភូមិជាអ្នករៀបចំដាក់ផែនការបង្កើតក្រុមសាមគ្គី <ដោយយកប្រជាជននៅក្នុង>ភូមិតែម្តង។ ផែនការនេះចេញមកពីអង្គការ"។ បញ្ចប់ការដកស្រង់។ តើលោកចង់និយាយថាម៉េចដែលថាផែនការ

នោះចេញមកពីអង្គការ ហើយតើអង្គការហ្នឹងមានន័យថាដូចម្ដេចដែរ?

**ឆ៖** ផែនការចេញមកពីអង្គការ។ អង្គការលើខ្ញុំៗបាទអត់ដឹងថានៅត្រង់ណាដែរ អង្គការលើៗ។

**ស៖** តើមានអ្នកណាម្នាក់ដែលធ្លាប់ពន្យល់ប្រាប់លោកថាអង្គការហ្នឹងជាស្អីទេ?

**ឆ៖** អត់ដែលប្រាប់។

[១៥:៤៩:៥០]

**ស៖** នៅក្នុងចម្លើយលេខ១៦ ដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតថា នៅពេលខ្មែរ-ក្រហមមកដល់តំបន់របស់លោក មិនមានសាលារៀន មិនមានគ្រូបង្រៀន មិនមានមន្ទីរពេទ្យ មិនមានវេជ្ជបណ្ឌិតនោះទេ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា សាលារៀន មន្ទីរពេទ្យ វេជ្ជបណ្ឌិត ទាំងអស់ហ្នឹង គឺថាអត់មាន បាត់អស់ តើវា<បាត់អស់ដោយរបៀបណាដែរ>?

**ឆ៖** គ្មានមន្ទីរពេទ្យ គ្មានសាលារៀន ដោយសារគ្រូបង្រៀនរត់ទៅក្នុងលន់នល់ទាំងអស់ ហើយពេទ្យខ្មែរអីបាត់អស់ អត់បានឃើញមានទេ។

**ស៖** នៅក្នុងចម្លើយលេខ១៨ នៃកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត លោកនិយាយអំពីការចាប់ខ្លួនមនុស្ស ហើយថាគេបញ្ជូនអ្នកទាំងនោះទៅឲ្យរៀនសូត្រ <ហើយលោកបាននិយាយថា> គឺអ្នកទាំងនេះគឺជាអ្នកដែលថាចោទប្រកាន់ថាជាអ្នកមានផ្ទះសម្បែងធំ ទ្រព្យសម្បត្តិ <ឬក៏មានដីស្រែច្រើន>។ សូមលោកជម្រាបជូនអង្គជំនុំជម្រះថាហេតុអីបានជាគេត្រូវបញ្ជូនអ្នកមានទ្រព្យសម្បត្តិទាំងអស់ហ្នឹងទៅឲ្យរៀនសូត្រ?

**ឆ៖** អ្នកមានទាំងអស់នេះ គេចង់ផ្ដាច់កម្មសិទ្ធិ កុំឲ្យមានកម្មសិទ្ធិផ្ទាល់ខ្លួនច្រើន។

**ស៖** តើមានអ្នកណាម្នាក់ធ្លាប់ពន្យល់ប្រាប់លោកអំពីមូលហេតុហ្នឹងទេ?

**ឆ៖** គ្មាន។

**ស៖** ឥឡូវនេះ ខ្ញុំផ្ដោតទៅលើអំឡុងពេលចន្លោះពីឆ្នាំ១៩៧៥ ដល់ ៧៩ ជាពិសេសអំឡុងពេលក្រោយការដួល<រលំ>ទីក្រុងភ្នំពេញ នៅក្នុងចម្លើយលេខ២០ លោកនិយាយអំពីការជម្លៀសប្រជាជនចេញ ពីៗទីក្រុង ហើយនិងបានទៅដល់ភូមិស្រុករបស់លោក។ តើលោកអាច<ជម្រាបតុលាការថាលោកបានឃើញ>អ្នកដែលត្រូវគេជម្លៀសមកដល់ស្រុកត្រាំកក់ហ្នឹង <មានចំនួនប៉ុន្មានដែរ>?

**ឆ៖** បាន។ ពេលប្រជាពលរដ្ឋជម្លៀសចេញពីទីក្រុងភ្នំពេញទៅ ខ្ញុំសង្កេតឃើញមានអូសរទេះ

រុញឡាន រុញម៉ូតូ រែកអម្រែកសម្ភារៈតាមខ្លួនតិចតួច។ ពេលមកដល់ភូមិឃុំ ខ្លះមកផ្ទះបងប្អូន ខ្លះមិនស្គាល់ ហ្នឹងរស់នៅតាម ធ្វើរោងតូចតាចអ៊ីចឹងទៅ។

**ស៖** តើលោកអាចប៉ាន់ប្រមាណបានទេថាមានមនុស្សប៉ុន្មាននាក់ មានប្រជាជនប៉ុន្មាននាក់ដែលបានមកដល់ភូមិស្រុករបស់លោកហ្នឹង?

**ឆ៖** ខ្ញុំមិនបានដឹងទេ។

[១៥:៥៣:៣៩]

**ស៖** នៅក្នុងចម្លើយលេខ៣៤ លោកនិយាយអំពីការបែងចែកប្រជាជនទៅតាមប្រភេទផ្សេងៗ នេះគឺជាអ្វីដែលលោកនិយាយ៖ "ប្រជាជនត្រូវបានបែងចែកដូចតទៅ ជាប្រជាជនពេញសិទ្ធិ ត្រៀម និង ផ្ញើ ដោយអង្គការជាអ្នកធ្វើការបែងចែក។ ប្រជាជនពេញសិទ្ធិគឺជាប្រជាជនមូលដ្ឋានដែលមានប្រវត្តិរូបល្អនិងមានកូនចៅធ្វើជាអ្នកតស៊ូ។ ប្រជាជនត្រៀមគឺជាប្រជាជនមូលដ្ឋានដែរ តែមានបងប្អូនឬសាច់ញាតិជាប់និន្នាការជាមួយពួកខ្មាំង គឺសំដៅទៅលើពួកលន់នល់ និង សីហនុ។ ប្រជាជន<បញ្ញើ> គឺជាប្រជាជន១៧មេសា ដែលជម្លៀសចេញពីទីក្រុង"។ បញ្ចប់ការដកស្រង់។ សូមលោកជម្រាបជូនអង្គជំនុំជម្រះថាតើរូបលោកផ្ទាល់ស្ថិតនៅក្នុងប្រភេទមួយណាដែរ? <ហេតុអ្វី?>

**ឆ៖** រូបខ្ញុំផ្ទាល់ស្ថិតនៅក្នុងប្រភេទត្រៀម ដោយសារមានបងប្អូននៅក្នុង លន់ នល់។

**ស៖** ហើយចំណុចមួយដែលលោកនិយាយនៅក្នុងចម្លើយ ខ្ញុំធ្លាប់លើកឡើងគឺថា "អង្គការជាអ្នកធ្វើការបែងចែកនេះ"។ តើធ្វើម៉េចបានជាលោកដឹងថា អង្គការជាអ្នកបែងចែកប្រជាជនទៅជាបីប្រភេទនេះ?

[១៥:៥៥:៣១]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

**លោក សៅ ប៉ាន៖**

**ឆ៖** ខ្ញុំឮសួរប្រជាពលរដ្ឋដែលគេពេញសិទ្ធិនិងមេកងគេនិយាយ។ មានត្រៀម មានផ្ញើ មានពេញសិទ្ធិ។

**ស៖** លោកចាំឈ្មោះប្រធានកងណាម្នាក់ ឬក៏ចាំឈ្មោះប្រធានកងច្រើន ដែល<ពន្យល់លោក អំពីរឿងនេះដែរ ឬទេ>?

**ឆ៖** មានចាំ។ អាចារ្យនាង, ឯក។

**ស៖** តើលោកមាននៅចាំអ្នកណាផ្សេងទៀតក្រៅពីនេះ ដែលពន្យល់លោកអំពីការបែងចែកប្រភេទប្រជាជននេះទេ?

**ឆ៖** ខ្ញុំភ្លេច។

**ស៖** តើលោកអាចជម្រាបបានថាតើគេប្រព្រឹត្តដូចម្ដេចដែរចំពោះប្រជាជនទាំងបីប្រភេទនេះ? មានន័យថា តើមានការប្រព្រឹត្តទៅលើក្រុមមួយប្រសើរជាងក្រុមមួយទៀត ឬក៏យ៉ាងណា?

**ឆ៖** បីប្រភេទនេះ ប្រសើរជាងគេគឺក្រុមពេញសិទ្ធិ។

**ស៖** សូមលោក -- តើលោកអាចរៀបរាប់លម្អិតបន្តិចបានទេ អំពីស្ថានភាពមកលើក្រុមនីមួយៗ លោកនិយាយអំពីរបបអាហារ ឬក៏និយាយអំពីជម្រកស្នាក់អាស្រ័យ ឬក៏និយាយអំពីពេលម៉ោងការងារ<? ហើយជាពិសេស> តើការប្រព្រឹត្ត<ចំពោះប្រជាជនពេញសិទ្ធិ គឺមានលក្ខណៈល្អប្រសើរដែរឬទេ>?

**ឆ៖** ចំណុចទាំងនេះ -- សូមម្ដងទៀត។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាអន្តរជាតិ គប្បីអង្កន់នូវសំណួរខ្លីៗទៅទំនងជាអាចឆ្លើយរួច បើសិនជាលោកតាំងសំណួរបែបអត្ថាធិប្បាយប្រហែលជាសាក្សីហ្នឹងមិនមានសមត្ថភាពពេញលេញ និងបរិបូរក្នុងការឆ្លើយតបនឹងសំណួរបែបនេះបានទេ។

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកប្រធាន។

[១៥:៥៩:០២]

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** លោក សៅ ប៊ាន តើលោកអាចជម្រាបបានទេ ថាតើប្រជាជនពេញសិទ្ធិហ្នឹងគេទទួលអាហារបានរបៀបណាដែរ? ប៉ុនណាដែរបើប្រៀបធៀបទៅនឹងប្រភេទ<ក្រុម>ផ្សេង<>?

**លោក សៅ ប៊ាន៖**

**ឆ៖** ការហូបអាហារសហករណ៍តែមួយ អ្នកពេញសិទ្ធិ ក៏ដូចអ្នកមិនពេញសិទ្ធិដែរ។

**ស៖** ចុះពេលម៉ោងការងារ ហើយនិងស្ថានភាពការងារសម្រាប់ប្រជាជនពេញសិទ្ធិយ៉ាងដូច

ម្តេចដែរ បើប្រៀបធៀបទៅនឹងក្រុមផ្សេងទៀត?

**ឆ៖** ក្នុងការងារធ្វើ អ្នកពេញសិទ្ធិច្រើនតែធ្វើមេពួក មេក្រុមអី ធ្វើការស្មើៗគ្នាដូចគ្នា។ ចំពោះអ្នកប្រធានក៏ធ្វើដូចគ្នា មានអ្នកពេញសិទ្ធិគ្រប់គ្រងតាមពួក។

**ស៖** ឥឡូវនេះ ខ្ញុំសុំចូលទៅបញ្ហាប្រវត្តិរូបរបស់ប្រជាជនថ្មីដែលជម្លៀសចេញពីទីក្រុង។ នៅក្នុងចម្លើយលេខ២២ លោកត្រូវបានគេសួរដូចតទៅនេះ សូមដកស្រង់៖ “ភ្លាមៗក្រោយពីប្រជាជននោះមកដល់ <តើ>ពួកគេ<មានបានធ្វើប្រវត្តិរូប ឬក៏>ធ្វើការសម្រិតសម្រាំងប្រវត្តិរូប <ដែរ ឬទេ?>”។ ហើយនេះគឺជាចម្លើយរបស់លោកគឺថា លោកថា៖ “បាទគឺមាន។ គេដើរធ្វើការស្រាវជ្រាវដើម្បីឲ្យដឹងថា អ្នកណាខ្លះធ្វើគ្រូ ទាហាន ឬកម្មករ។ ចំពោះអ្នកណាដែលគេដឹងថាជាទាហាន ឬគ្រូ អ្នកទាំងនោះត្រូវបានគេចាប់ខ្លួនយកទៅបាត់រហូត”។ បញ្ចប់ការដកស្រង់។ តើលោកអាចជម្រាបបានទេ ថាតើលោកនិយាយសំដៅទៅ<អ្នកណា នៅពេលដែលលោកនិយាយថា “ពួកគេ” ធ្វើការស្រាវជ្រាវរក> អ្នកណាដែល<ធ្លាប់ធ្វើជា>ទាហាន ជាគ្រូ<>?

**ឆ៖** ខ្ញុំបានឃើញដោយសារបងខ្ញុំម្នាក់ឈ្មោះ លន់ ហម។ ពេលមកផ្ទះ មេភូមិ មេក្រុមគេ ដើរតាមផ្ទះស៊ើបអង្កេតមើលមកដល់ៗមានប៉ុន្មាននាក់ៗ អ៊ីចឹងនៅតាមផ្ទះនីមួយៗដែលមានបងប្អូនម៉ែឪ។ ក្រោយមកគេក៏នាំបាត់ទៅ។

**ស៖** លោកចាំឈ្មោះប្រធានភូមិ ប្រធានក្រុម ដែលធ្វើការស្រាវជ្រាវហ្នឹងទេ?

**ឆ៖** ចាំ។

**ស៖** ឈ្មោះអ្វីខ្លះដែរលោក?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗឆ្លើយតប។

**លោក សៅ ប៉ាន៖**

**ឆ៖** ឈ្មោះតាឯក, អាចារ្យនាង។

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** នៅក្នុងចម្លើយបន្ទាប់របស់លោកគឺចម្លើយលេខ<២៣>លោកនិយាយអំពីការចាប់ខ្លួន និងការបាត់ខ្លួនបងបង្កើតរបស់លោកឈ្មោះ លន់ ហម <ជាទាហាន>។ តើលោកអាចជម្រាប<យើងថានៅពេលណាដែលបងប្រុសរបស់លោកត្រូវបានចាប់ខ្លួន>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាន។ ក្រោយពេលបងខ្ញុំឈ្មោះ លន់ ហម មកដល់ផ្ទះ មេភូមិគេមកស៊ើបអង្កេតរយៈកាលបីបួនថ្ងៃ ក្រោយមកបានមានឈ្លបគេមកនាំយកទៅ។

**ស៖** លោកមានចាំឈ្មោះ<ឈ្លបណាម្នាក់>ដែលមកនាំខ្លួនបងប្រុសរបស់លោកទេ?

**ឆ៖** ឈ្មោះ ប៉ែន មេក្រុម, តាឯក និងថែមមេក្រុមមួយទៀត ឈ្មោះតាឡុញ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសហព្រះរាជអាជ្ញារង ហើយឥឡូវ -- បាទ សវនាការថ្ងៃនេះដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ចាប់ផ្ដើមពីប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី សៅ ហ៊ាន ហើយសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមកាលវេលាដែលបានកំណត់នេះ។

ហើយអង្គជំនុំជម្រះសូមអរគុណ លោក សៅ ហ៊ាន ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សី នៅពេលនេះមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនាពេលនេះ លោកអាចវិលត្រឡប់ទៅកាន់ទីស្នាក់ កន្លែងដែលលោកស្នាក់នៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក សៅ ហ៊ាន វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ និងសូមឲ្យគាត់ -- សូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប ខៀវ សំផន និង នួន ជា ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៦នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*